

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត

- ប្រវត្តិសាស្ត្រកម្ពុជាបែបឧបមា
- មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧១នាក់ នៅភូមិបាក់នឹម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨២ ខែមិថុនា ឆ្នាំ២០២៣

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨២ ខែមិថុនា ឆ្នាំ២០២៣



ប្រជាជនកម្ពុជាកំពុងធ្វើដំណើរត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មាតិកា

## សំបុត្រ

◆ ប្រវត្តិសាស្ត្រកម្ពុជាបែបខុបមា ............... ១

## ផ្នែកឯកសារ

◆ សៀង ហឺ៖ អតីតវេជ្ជបណ្ឌិត នៅពេទ្យរុស្ស៊ី ... ៤

## ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

◆ មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតនៅភូមិបាក់នឹម.... ៧
◆ រឿងរ៉ាវជីវិតរបស់ស្ត្រីនៅក្នុងសហគមន៍បន្ទាប់ពីរបបខ្មែរក្រហម និងបម្រែបម្រួល....... ១២
◆ រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំចាយមារ ............... ២១
◆ ទីតាំងប្រវត្តិសាស្ត្រយោធាថ្មីនឹងត្រូវបានសាងសង់ជាមួយនឹងការពង្រីកការសិក្សា .... ២៧
◆ មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជុំក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាដែលធ្វើការនៅតំបន់ដាច់...... ២៩
◆ រឿងរ៉ាវរបស់ជនពិការក្នុងរបបខ្មែរក្រហម .... ៣៣
◆ សិស្សមកពីសាលាអង្គការតារាម៉ាណាដែលមានជីវភាពខ្វះខាត ទស្សនកិច្ច ........... ៣៦
◆ ចាន់ ដាន៖ ពិការជើងដោយសារជាន់... ៣៨
◆ ដាង ទឹម៖ កងការពារស្ថានទូតអេហ្ស៊ីប.... ៤០
◆ ប៉ក់ សារ៉ន៖ អតីតយោធាខ្មែរក្រហម .... ៤១

## ផ្នែកវេទិកាពិភាក្សាសាធារណៈ

◆ ក្រុមប្រឹក្សាយុវជនកាយរិទ្ធកាកបាទក្រហម និង ស.ស.យ.ក ស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះធំ.....៤៣
◆ យុវជនជំនាន់ក្រោយយល់ដឹងកាន់តែច្បាស់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ .......... ៤៧
◆ ទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាព........ ៥០
◆ សិស្សវិទ្យាល័យបឹងព្រះសិក្សាអំពី «ទំនាក់ទំនងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ».. ៥២
◆ សិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុនសែនសង្កើបសិក្សាអំពី «ប្រវត្តិសាស្ត្រកម្ពុជា .......... ៥៥

## ផ្នែកស្រាវជ្រាវរកគ្រួសារ

◆ **«ទួលពិឃាដ»** (ត) ......................... ៥៩

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥ព.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, ដារ៉ារដ្ឋ មេត្តា, គីម សុវណ្ណដានី, សាំង ចាន់ធូ, សាន ធីតា, អឿន ពណ្ណរាយ, សោម ប៊ុនថន, ធី គីមហុង, ចាន់ណារិទ្ធ, ឈុំ រ៉ា, ភា រស្មី, សួត វិចិត្រ, ទូច វណ្ណេត និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ប្រវត្តិសាស្ត្រកម្ពុជាបែបឧបមា

**ឆាំង យុ**



(ពីឆ្វេងទៅស្តាំ) សម្តេច ជា ស៊ីម, សម្តេច ហេង សំរិន និងសម្តេច ហ៊ុន សែន អបអរខួបអនុស្សាវរីយ៍នៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ២ ធ្នូ នៅខាងមុខអតីតគុកសម្ងាត់របស់ខ្មែរក្រហម គឺមន្ទីរសន្តិសុខ ស-២១ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។ ប្រភព៖ សារព័ត៌មានប្រេហ្សញូវ/មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រវត្តិសាស្ត្រកម្ពុជាបែបឧបមា៖ ប្រសិនបើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ពុំបានភៀសខ្លួនចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៧? ប្រសិនបើគ្មានកងកម្លាំងប្រឆាំងនឹងរបបខ្មែរក្រហមកើតមានឡើង? ហើយប្រសិនបើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ពុំបានបង្កើត ឬអនុវត្តគោលនយោបាយ ឈ្នះ ឈ្នះ?

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ ប្រជាជនកម្ពុជា បានប្រារព្ធទិវានៃការចងចាំ ដែលត្រូវបានអនុម័តជាថ្ងៃឈប់សម្រាកជាតិកាលពីឆ្នាំ២០១៨។ ថ្ងៃឈប់សម្រាកនេះ ប្រារព្ធឡើងដើម្បីរំឭកការចងចាំជាសាធារណៈអំពីរបបប្រល័យពូជសាសន៍ដែលកើតមាននៅក្នុងប្រទេសកម្ពុជា, ផលប៉ះពាល់យ៉ាងដំណំបន្សល់ទុកពីរបបនេះចំពោះប្រជាជនកម្ពុជា និងអន្តរកាលរបស់ប្រទេសកម្ពុជារួចផុតពីភាពព្រឺព្រួចនៃរបបខ្មែរក្រហម ឈានទៅកាន់យុគសម័យសន្តិភាព, ការជាសះស្បើយ និងការផ្សះផ្សា។ តួអង្គដ៏លេចធ្លោនៅក្នុងអន្តរកាលដ៏លំបាកលំបិននេះ គឺសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ សម្តេចតេជោ ដែលដើមដំបូងឡើយជាសមាជិកនៃរបបខ្មែរក្រហម ក៏ប៉ុន្តែក្រោយមកមានសេចក្តី

ស្រងាកចិត្តយ៉ាងខ្លាំងចំពោះរបបនេះ។ សម្តេចតេជោបានដឹកនាំកងកម្លាំងប្រឆាំងមួយក្រុម ដោយទទួលបានជំនួយពីរដ្ឋាភិបាលវៀតណាម ហើយបានយកឈ្នះលើរបបប្រល័យពូជសាសន៍ ប៉ុល ពត។

ការពិតនិងប្រវត្តិសាស្ត្រ គឺមិនអាចក្លែងបន្លំបានទេ ក៏ប៉ុន្តែភាពត្រឹមត្រូវនៃតថភាពជាក់ស្តែងអាចនឹងបំភ័ន្តតាមរយៈទំនោរនយោបាយ ដែលបង្កជាភាពខុសពីការពិតនៃតថភាពជាក់ស្តែងនោះ។ នៅក្នុងអត្ថបទខ្លីមួយនេះ ខ្ញុំបានចោទជាសំណួរថាតើតួនាទីប្រវត្តិសាស្ត្ររបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងការប្រយុទ្ធប្រឆាំងជាមួយនឹងខ្មែរក្រហម បានធ្លាក់ទៅជាជនរងគ្រោះនៃទំនោរនយោបាយដោយផ្អែកលើតថភាពជាក់ស្តែង ឬយ៉ាងណា?

ប្រវត្តិសាស្ត្របែបខបមា គឺជាជំពូកនៃប្រវត្តិសាស្ត្រដែលប្រមើមើលនិងប្រឌិតឡើង ដោយព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយឬច្រើនដែលបានកើតមានឡើងខុសពីព្រឹត្តិការណ៍ពិតជាក់ស្តែង។ ប្រវត្តិសាស្ត្របែបខបមាផ្តល់នូវគោលគំនិតដ៏សំខាន់ដើម្បីពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា និងប្រវត្តិសាស្ត្រនៃដំណើរតស៊ូរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុនសែនក្នុងការប្រឆាំងនឹងខ្មែរក្រហម។

នៅក្នុងវប្បធម៌លោកខាងលិច មានឧទាហរណ៍ជាច្រើនស្តីអំពីប្រវត្តិសាស្ត្របែបខបមា ឬការប្រឌិតឡើងនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ។ "The Man in the High Castle" និពន្ធដោយ ហ្វីលីព ខេ. ឌីក (Philip K. Dick) គឺជាឧទាហរណ៍មួយសម្រាប់អ្នកអាន ក្នុងការត្រិះរិះពិចារណាថាតើពិភពលោកនឹងទៅជាយ៉ាងណា ប្រសិនបើមហាអំណាចអ័ក្ស (Axis Powers) បានយកឈ្នះលើសង្គ្រាមលោកលើកទី២។ ប្រវត្តិសាស្ត្របែបខបមា ចោទជាសំណួរដែលបណ្តុះផ្នត់គំនិតចំពោះប្រវត្តិសាស្ត្រពិត ថាតើប្រសិនបើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រកើតឡើងក្នុងស្ថានភាពផ្សេង តើមានលទ្ធផលយ៉ាងដូចម្តេចទៅវិញ។ ប្រវត្តិសាស្ត្របែបខបមា គឺពិតជាចាំបាច់ចំពោះការយល់ដឹងអំពីប្រវត្តិសាស្ត្រពិត ពីព្រោះថាប្រវត្តិសាស្ត្របែបខបមា ជំរុញឲ្យយើងគិតពិចារណាដោយល្អិតល្អន់លើសពីការពិត, ចោទជាសំណួរនិងគោលគំនិតក្នុងការពិចារណា និងសន្មតថាតើតថភាពជាក់ស្តែងរបស់យើងសព្វថ្ងៃនឹងទៅជាយ៉ាងណា ប្រសិនបើព្រឹត្តិការណ៍ប្រវត្តិសាស្ត្របានប្រព្រឹត្តទៅខុសពីការពិត។

ពុំទាន់មានប្រវត្តិសាស្ត្របែបខបមាណាមួយត្រូវបាននិពន្ធឡើងអំពីប្រទេសកម្ពុជាស្ថិតនៅក្រោមរបបខ្មែរក្រហមនៅឡើយទេ។ ប្រសិនបើមានប្រវត្តិសាស្ត្របែបខបមាសម្រាប់កម្ពុជា នោះគឺពិតជាផ្តល់ជាអត្ថប្រយោជន៍សម្រាប់ការត្រិះរិះពិចារណាថាតើប្រទេសកម្ពុជានឹងក្លាយទៅជាយ៉ាងណា ប្រសិនបើព្រឹត្តិការណ៍ពាក់ព័ន្ធទៅនឹងការផ្តួលរំលំ និងការបំផ្លាញចលនាខ្មែរក្រហម ពុំមានវត្តមានឡើង ឬកើតមានឡើងក្នុងស្ថានភាពមួយផ្សេងទៅវិញ។

ការពិភាក្សាវែកញែកយ៉ាងល្អិតល្អន់អំពីប្រវត្តិសាស្ត្របែបខបមា អាចជំរុញឲ្យមានសំណួរសំខាន់ៗជាច្រើន។ ជាឧទាហរណ៍៖ ប្រសិនបើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ពុំបានភៀសខ្លួនចេញពីប្រទេសកម្ពុជានៅក្នុងឆ្នាំ១៩៧៧? ប្រសិនបើគ្មានកងកម្លាំងប្រឆាំងនឹងរបបខ្មែរក្រហមកើតមានឡើង? ហើយប្រសិនបើសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ពុំបានបង្កើត ឬអនុវត្តគោលនយោបាយ ឈ្នះ ឈ្នះ?

សំណួរទាំងអស់ខាងលើ បណ្តុះការគិតសម្រាប់បុគ្គល ឲ្យពិចារណាថាតើ របបខ្មែរក្រហម អាចបន្តអាយុកាលរបស់ខ្លួនបានយូរជាងការជាក់ស្តែង ទាំងផ្នែកយោធានិងផ្នែកនយោបាយដែរឬទេ។ ប្រសិនបើចលនាខ្មែរក្រហមនៅតែបន្តមានវត្តមាន តើនឹងមានឥទ្ធិពលអ្វីខ្លះកើតឡើងចំពោះសុខមាលភាពទូទៅ និងស្ថានការណ៍របស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន? តើប្រទេសកម្ពុជា ឬតំបន់អាស៊ីអាគ្នេយ៍ មានស្ថានភាពយ៉ាងណា លើការអភិវឌ្ឍសេដ្ឋកិច្ច សន្តិភាព និងស្ថិរភាព ប្រសិនបើស្ថានការណ៍ក្នុងអតីតកាលត្រូវបានដោះស្រាយខុសពីនេះ? ដោយពិចារណាទៅលើការសន្មតខាងលើ យើងអាចនឹងលើកឡើងជាចម្ងល់មួយថា៖ តើប្រជាជនចំនួនរាប់ពាន់ ឬរាប់លាននាក់

ទៀត ត្រូវរងទុក្ខវេទនា និងបាត់បង់ជីវិតប៉ុណ្ណាដែរ ប្រសិនបើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ កើតមានឡើងក្នុងទម្រង់មួយផ្សេងទៀត? តើមានបេក្ខភាពដទៃទៀតដែលមានសមត្ថភាពនិងមានការប្តេជ្ញា ដូចសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងនាមជាអ្នកដឹកនាំដ៏ឈ្លាសវៃមួយរូប ក្នុងការផ្តួលរំលំរបបខ្មែរក្រហមឬទេ?

ពិតប្រាកដណាស់ មិនមែនមនុស្សគ្រប់គ្នាអាចផ្តល់សេចក្តីសន្និដ្ឋានដូចៗគ្នាចំពោះសំណួរខាងលើទេ ហើយមនុស្សគ្រប់គ្នាក៏មិនចាំបាច់ត្រូវតែឆ្លើយតបដូចៗគ្នាដែរ។ គិតគូរអំពីប្រវត្តិសាស្ត្របែបឧបមា គឺមិនមែនជាការលន់តួការពារចំពោះរាជរដ្ឋាភិបាលបច្ចុប្បន្នឬថ្នាក់ដឹកនាំសព្វថ្ងៃនោះទេ ក៏ប៉ុន្តែយើងត្រូវទទួលស្គាល់អំពីគុណសម្បត្តិដែលត្រូវទទួលស្គាល់។ ការផ្តួលរំលំនិងការបំផ្លាញចលនាខ្មែរក្រហម ស្ថិតក្រោមឥទ្ធិពលនៃកត្តាជាច្រើន ក៏ប៉ុន្តែកត្តាគន្លឹះដ៏ចាំបាច់បំផុតមួយគឺ រាជរដ្ឋាភិបាលថ្មីមួយ ដែលស្ថិតនៅក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ តាមទ្រឹស្តី ប្រសិនបើប្រជាជនកម្ពុជានិងប្រទេសកម្ពុជា ស្ថិតនៅក្នុងប្រវត្តិសាស្ត្របែបឧបមាពោលគឺក្រោមការដឹកនាំនៃរដ្ឋាភិបាលដទៃ ប្រជាជនកម្ពុជាអាចនឹងមានភាពប្រសើរជាងនេះ។ តាមការពិតទៅ ប្រជាជនកម្ពុជាអាចនឹងរស់នៅដោយលំបាកលំបិនទៅវិញទេ។

អនាគតរបស់ប្រទេសកម្ពុជា មិនមែនពឹងផ្អែកតែទៅលើការទទួលយកជារួមចំពោះប្រវត្តិសាស្ត្រតែប៉ុណ្ណោះទេ ក៏ប៉ុន្តែអាស្រ័យទៅលើការប្តេជ្ញារបស់យើងចំពោះការចោទជាសំណួរ និងឆ្លើយតបចំពោះសំណួរពិបាកៗ ទោះបីជាចម្លើយទាំងនោះអាចនឹងមិនបម្រើចំពោះអត្ថប្រយោជន៍ឬទំនោរនយោបាយយ៉ាងណាក្តី។

## ឆាំង យុ
## អ្នករស់រានមានជីវិតម្នាក់ពីរបបខ្មែរក្រហម និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

បេសកកម្មរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺដើម្បីចងក្រង និងអភិរក្សប្រវត្តិសាស្ត្ររបបខ្មែរក្រហមសម្រាប់មនុស្សជំនាន់ក្រោយ ព្រមទាំងប្រមូលផ្តុំនិងរៀបចំព័ត៌មាន ដែលអាចបម្រើជាភស្តុតាងសក្តានុពលចំពោះដំណើរការផ្លូវច្បាប់ក្នុងការកាត់ទោសលើឧក្រិដ្ឋកម្មខ្មែរក្រហម។ កម្មវត្ថុខាងលើទាំងពីរ តំណាងឲ្យតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការលើកកម្ពស់ការចងចាំ និងយុត្តិធម៌ ដែលជាមូលដ្ឋានដ៏ចាំបាច់សម្រាប់នីតិរដ្ឋ និងការផ្សះផ្សាយ៉ាងពិតប្រាកដមួយនៅក្នុងប្រទេសកម្ពុជា។



សកម្មភាពសម្តេច ហ៊ុន សែន ចុះជួបប្រជាជនរស់នៅតំបន់កោះថ្ម នៅអំឡុងពេលនៃការប្រារព្ធមីទ្ទីញនៃការបង្កើត "រណសិរ្សសាមគ្គី សង្គ្រោះជាតិកម្ពុជា" នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨ នៅភូមិដើមឈូ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សៀង ហ៊ី ៖ អតីតវេជ្ជបណ្ឌិត នៅពេទ្យរុស្ស៊ី

**ដារ៉ារដ្ឋ មេត្តា**



គិលានដ្ឋាននៅភូមិភាគបូព៌ា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សៀង ហ៊ី អាយុ៣៧ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧) មានស្រុកកំណើតនៅភូមិកំពង់ព្រះ ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង។ នៅក្នុងឆ្នាំ១៩៤៨ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាកំពង់ព្រះ រហូតដល់ឆ្នាំ១៩៥៣ ខ្ញុំបានរៀនបន្តនៅអនុវិទ្យាល័យបាត់ដំបង។ ក្រោយមកឆ្នាំ១៩៥៩ ខ្ញុំផ្លាស់មករៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងក្រុងភ្នំពេញរហូតដល់ថ្នាក់បញ្ចប់។

នៅក្នុងឆ្នាំ១៩៦០ ខ្ញុំរៀនមុខវិជ្ជាពេទ្យ នៅមហាវិទ្យាល័យ វេជ្ជសាស្ត្រភ្នំពេញ។ នៅក្នុងឆ្នាំ១៩៦១ ខ្ញុំចូលក្នុងសមាគមនិស្សិតពេទ្យ ដែលមានឈ្មោះ ហែម បូរី គឺជានិស្សិតពេទ្យ គឺជាប្រធាន។ តាមរយៈសមាគមនេះ ខ្ញុំបានចូលជា សេ.អ៊ី.អា ដោយមានអ្នកនាំចូលឈ្មោះ ហែម បូរី និងមានអ្នកទទួលស្គាល់ជនជាតិបារាំង ឈ្មោះ សៀ ” គឺជានាយកមហាវិទ្យាល័យវេជ្ជសាស្ត្រ។ អ្នកចូលជាមួយខ្ញុំកាលនោះមានឈ្មោះ ឆែម ចំរូម គឺជានិស្សិតពេទ្យដែរ។ ភារកិច្ច សេ.អ៊ី.អា គឺឃោសនាបំផុសនិស្សិតពេទ្យ និងប្រជាជនមិនឲ្យចូលខ្មែរក្រហម, ត្រូវកសាងកម្លាំង សេ.អ៊ី.អា ក្នុងចំណោមនិស្សិតពេទ្យ, តាមដានខ្មែរក្រហមក្នុងចំណោមនិស្សិតពេទ្យ និងប្រជាជន។ ក្រោយមកខ្ញុំនិង ឆែម ចំរូម កសាងកម្លាំងបានមួយចំនួនរួមមាន៖ ដេក សោម គឺជាវេជ្ជបណ្ឌិតពេទ្យធំភ្នំពេញ, កែម ឆោម វេជ្ជបណ្ឌិតពេទ្យធំប៉ៃលិន, អ៊ាប

ប៉េងសែ វេជ្ជបណ្ឌិត ខាងភ្នែកពេទ្យអង្គឌួង, តាន់ បេង គួន គឺជាពេទ្យរបបសាធារណរដ្ឋ, តាន់ គឹម ឈូ គឺជាសាស្ត្រាចារ្យសាលាច្បាប់, កែវ សំបាត់ ឯកទេសធ្មេញនៅពេទ្យរុស្ស៊ី។

នៅក្នុងឆ្នាំ១៩៧១ ខ្ញុំប្រឡងជាប់ជាវេជ្ជបណ្ឌិត ហើយចេញទៅធ្វើការនៅពេទ្យ សុធាវង់ ឯកទេសខាងជំងឺសើស្បែក។ ពេលនោះ ឆែម ចំរួម បានទៅប្រទេសបារាំង ចំណែកខ្ញុំនៅបន្តការទាក់ទងជាមួយ ហែម បូរី។ នៅក្នុងឆ្នាំ១៩៧៣ ហែម បូរី នាំខ្ញុំទៅទាក់ទងជាមួយឈ្មោះ ហ៊ុង គុងហោ គឺជាវេជ្ជបណ្ឌិតនៅពេទ្យរុស្ស៊ី។ ក្រោយមកខ្ញុំផ្លាស់ទៅពេទ្យរុស្ស៊ី ហើយខ្ញុំបានទាក់ទងជាប់ជាមួយឈ្មោះ កែវ សំបាត់ គឺជាខ្សែដែលខ្ញុំកសាងបានពីមុន។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំដាច់ការទាក់ទងខ្សែរយៈរបស់ខ្ញុំដោយសារខ្មែរក្រហមជម្លៀសប្រជាជនចេញពីផ្ទះសម្បែង ហើយខ្ញុំទៅនៅខាងតាខ្មៅ ខេត្តកណ្ដាល។ នៅខែសីហា ឆ្នាំ១៩៧៥ អង្គការជម្លៀសខ្ញុំបន្តទៅនៅភូមិពង្រ ឃុំប៉ោយចារ ស្រុកភ្នំស្រុក (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) តំបន់៥។ រហូតដល់ខែធ្នូ ឆ្នាំ១៩៧៥ ដដែល អង្គការបានហៅខ្ញុំទៅរៀននយោបាយរយៈពេល៣ថ្ងៃ នៅស្រុកភ្នំស្រុក ក្នុងការរៀននោះ អង្គការប្រមូលអ្នករដ្ឋការចាស់ និងបញ្ញវន្ត។ បន្ទាប់មក អង្គការបានបញ្ជូនក្រុមខ្ញុំមកដាក់នៅមន្ទីរឃុំឃាំង បាត់ដំបង អស់រយៈពេល៤ខែ។ នៅពេលខ្ញុំនៅកន្លែងឃុំឃាំង ខ្ញុំបានជួបឈ្មោះ កែវ សំបាត់ ហើយទាក់ទងខ្សែផ្សេងទៀតមាន កង ចក់ គឺជាទាហានស័ក្តិ៥, ឈួន ស្វាង គឺជានិស្សិតពេទ្យ, លី ប៉ូ គឺជាវេជ្ជបណ្ឌិត, លី ដាវី គឺជានិស្សិតថ្នាក់បញ្ចប់, វ៉ាន់ ខាន់ទឿង គឺជាជាងសំណង់, ម៉ូវ ឯកទេសអគ្គិសនី, ផល់ លីវុធ អ្នកចែកថ្នាំពេទ្យសម្រាប់រដ្ឋ និង សេង គឺជាសាស្ត្រាចារ្យ។

នៅខែមេសា ឆ្នាំ១៩៧៦ អង្គការយកក្រុមខ្ញុំទៅដាក់ក្នុងឃុំតាម៉ឹន ស្រុកសង្កែ តំបន់៣។ ពេលនោះ អង្គការចែកក្រុមខ្ញុំទៅតាមភូមិ រួមមាន៖ កង ចក់ នៅកងពលតូចលេខ១០ សហករណ៍ភូមិប៉ោយសំរោង ឃុំតាម៉ឹន, ឈួន ស្វាង, លី ដាវីន នៅកងពលតូចលេខ២ សហករណ៍ភូមិប៉ោយសំរោង ឃុំតាម៉ឹន, វ៉ាន់ ខាន់ទឿង នៅកងពលតូចលេខ៣ សហករណ៍ភូមិប៉ោយសំរោង ឃុំតាម៉ឹន, ម៉ូវ នៅកងពលតូចលេខ៧ សហករណ៍ភូមិប៉ោយសំរោង ឃុំតាម៉ឹន, ផល់ លីវុធ នៅកងពលតូចលេខ៨ សហករណ៍ភូមិប៉ោយសំរោង ឃុំតាម៉ឹន, កែវ សំបាត់, លី ប៉ូ និង សេង នៅភូមិគៀនកេះ ស្រុកបវេល។ ខ្ញុំនៅក្នុងកងពលលេខ១២ ខាងផ្នែកដាំបន្លែ។ នៅខែមិថុនា និង ខែកក្កដា ឆ្នាំ១៩៧៦ ខ្ញុំមានការទាក់ទងជាមួយឈ្មោះ លី អតីតគ្រូបង្រៀននៅក្នុងភូមិប៉ោយសំរោង ដែលក្រោយរំដោះទទួលបង្រៀនកុមារ។ មុនដំបូង លី ចេះតែមកសួរខ្ញុំរឿងថ្នាំ និងជំងឺ រហូតដល់ទុកចិត្តគ្នាហើយ លី ប្រាប់ពីកងទ័ពនៅព្រៃនាមក្រោមដែលមានសញ្ញាពស់វែក, ឈ្មោះ ឡឹក សំអឿន ស័ក្តិ៥ នៅបាត់ដំបង ដឹកនាំកម្លាំងចំនួន៥០០នាក់ នៅក្នុងព្រៃនាមជួរទន្លេសាបតំបន់៣។ លី ឲ្យខ្ញុំកសាងកម្លាំង ធ្វើសកម្មភាពលួចស្បៀងផ្ដល់ទៅឲ្យក្រុមលាក់ខ្លួននៅក្នុងព្រៃនាម។ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៦ ខ្ញុំរួមជាមួយឈ្មោះ សន និង ខន លួចអង្ករចំនួន៤០គីឡូអំបិលចំនួន១បាវរបស់កងអនុសេនាតូច១២ សហករណ៍ភូមិប៉ោយសំរោងយកទៅឲ្យឈ្មោះ លី ហើយ លី យកទៅឲ្យបក្ខពួកនៅព្រៃនាម។

នៅខែមករា ឆ្នាំ១៩៧៧ លី ហៅខ្ញុំទៅប្រជុំទទួលផែនការនៅវិហារប៉ោយសំរោង ពីឈ្មោះ ម៉ាក់ គឺជាប្រធានសហករណ៍ភូមិប៉ោយសំរោង ឃុំតាម៉ឹន។ អ្នកដែលចូលរួមប្រជុំមាន៖ ១) ផ្លែក គឺជាប្រធានកងតូចលេខ១០, ទៀង អតីតធ្វើស្រែ, គ្រឿត គឺជាប្រធានកងធំលេខ៣ សហករណ៍ប៉ោយសំរោង, គ្រៀល ប្រជាជនថ្មី និង ភៀ ប្រជាជនថ្មីប្រធានកងតូចលេខ៦។ ខ្លឹមសារប្រជុំចែកភារកិច្ចអនុវត្ត រួមមាន៖ ផ្លែកកសាងកម្លាំងប្រជាជន បំផ្លាញសម្ភារកសិកម្ម លួចស្បៀងប្រគល់ឲ្យឈ្មោះ លី, គ្រឿត និងឈ្មោះ ភៀ, ចំណែកខ្ញុំ គឺឃោសនាបំផុសប្រជាជនពីរបបចាស់។ ផ្លែកខាងយកស្បៀងទៅព្រៃនាមមានផ្លែក, ទៀង និង គ្រៀល។ នៅពេលចេញពីប្រជុំវិញ ខ្ញុំរួម

ជាមួយ ឈ្មោះ សាន យកផ្លែត្រឡាចចំនួន៦០ផ្លែ និង ល្ពៅចំនួន៥០ផ្លែ ទៅឲ្យឈ្មោះ គ្រៀល ដោយយក លេសថាយកទៅឲ្យសេដ្ឋកិច្ចដើម្បីកុំឲ្យប្រជាជនដឹង ក្នុងការបញ្ចេញទៅឲ្យពួកចោរព្រៃ។

នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ខ្ញុំរួមជាមួយឈ្មោះ សន, ហ៊ីន លួចអង្ករពីសេដ្ឋកិច្ច ចំនួនកន្លះបាវឆ្នូតទៅ ឲ្យ ភឿ ទុកឲ្យឈ្មោះ ផ្លែក និង ឈ្មោះ ទៀង ដឹកទៅឲ្យ ពួកចោរព្រៃ។ ក្រោយមកខ្ញុំ,គៀត, ភឿ លួចស្រូវដែល បោករួច នៅលានក្រោយភូមិចំនួន១០បាវ។ នៅខែ មីនា ឆ្នាំ១៩៧៧ ខ្ញុំចូលរួមជាមួយឈ្មោះ ហ៊ីន ទៅ អប់រំបានឈ្មោះ សៀង គឺជាអតីតជាងកាត់សក់ ដោយ បំផុសពីរបបចាស់រស់នៅសុខស្រួល ទាំងរបបអាហារ។ បន្ទាប់ពីខ្ញុំអប់រំ សៀង បានហើយ ខ្ញុំបានឃោសនា បំផុសប្រជាជនកសាងកម្លាំងប្រឆាំងបដិវត្តន៍។ ក្រោយ មក គ្រៀល ហៅខ្ញុំទៅប្រជុំដែលអ្នកចូលរួម មាន ដូចទៅ សន គឺជាវប្បធម៌ភូមិ បច្ចុប្បន្នកងតូច១២ សហករណ៍ភូមិប៉ោយសំរោង, យឿម គឺជាវប្បធម៌ភូមិ បច្ចុប្បន្នកងតូច១២ សហករណ៍ភូមិប៉ោយសំរោង, ភឿ គឺជាប្រធានកងតូចលេខ១៦ សហករណ៍ភូមិប៉ោយ សំរោង, លី វប្បធម៌ភូមិចាប់, ខន គឺជាប្រជាជនថ្មី នៅ កងតូចលេខ១១ កងធំលេខ២ សហករណ៍ប៉ោយសំរោង។ ផែនការគឺកសាងកម្លាំងឲ្យបានច្រើន, លួចស្បៀង ត្រៀមយកទៅឲ្យបក្ខពួកនៅព្រៃនាម ដែលមាន ឈ្មោះ ឡឹក សំអឿន គឺជាអ្នកដឹកនាំ និងវាយបដិវត្តន៍ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ខាងមុខ។ ក្រោយពីប្រជុំ ចប់ យើងបែកមុខសញ្ញាគ្នាអនុវត្តផែនការ។

ក្រោយមកអង្គការចាប់ តាម៉ាក់ គឺជាប្រធាន សហករណ៍ភូមិប៉ោយសំរោង, ឈ្មោះ គ្រៀត, ឈ្មោះ គ្រៀល និង ចាប់ខ្សែរបស់ខ្ញុំមួយចំនួនជាបន្តបន្ទាប់។ ក្រោយមក ភឿ ឲ្យខ្ញុំផ្អាកសកម្មភាពដោយចាំស្តាប់ សភាពការណ៍របស់អង្គការ។ នៅខែកក្កដា ឆ្នាំ១៩៧៧ ភឿ ហៅខ្ញុំទៅប្រជុំដោយអ្នកចូលរួមមានឈ្មោះ សន, យឿម និង ហ៊ីន នៅកងតូចលេខ១១២ សហករណ៍ប៉ោយ សំរោង។ ផែនការគឺឲ្យបក្ខពួកខ្ញុំធ្វើសកម្មភាពបំផ្លាញ និងលួចស្បៀង, រៀបចំកម្លាំងសម្រាប់ទាក់ទង ទៅក្រុមនៅក្នុងព្រៃដែលមានឈ្មោះ ឡឹក សំអឿន គឺជាអ្នកដឹកនាំ ហើយអ្នកដែលទាក់ទងទៅបក្ខពួក នៅក្នុងព្រៃមានឈ្មោះ សន, យឿម, ផន និង ហ៊ីន។ ក្រោយពីប្រជុំហើយ ខ្ញុំចូលរួមជាមួយ សាន, ប៉ុញ និង លឿង លួចអង្ករក្នុងកងពលតូចលេខ១១២ ចំនួន២បាវ, អំបិលចំនួន៣០គីឡូ យកទៅឲ្យ ភឿ ដើម្បីបញ្ជូនឲ្យពួក ចោរព្រៃ។ ខ្ញុំធ្វើសកម្មភាពរហូតដល់អង្គការចាប់ខ្លួន ខ្ញុំនៅថ្ងៃទី៩ ខែសីហា ឆ្នាំ១៩៧៧។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយ សារភាពឯកសារJ០០៣០៣។ រាល់ចម្លើយសារភាព របស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាង ធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើង មិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ សៀង ហ៊ី ពិតឬយ៉ាងណានោះទេ?**



សំបុត្រអនុញ្ញាតឲ្យអ្នកជំងឺចេញពីមន្ទីរពេទ្យ នៅភូមិភាគបូព៌ា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាព ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន៧១នាក់ នៅភូមិបាក់នឹម

***គីម សុវណ្ណដានី***



មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧១នាក់ នៅភូមិបាក់នឹម រយៈពេល៣ថ្ងៃជាប់គ្នា គឺចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



នារដូវវស្សាក្នុងភូមិបាក់នឹម ដែលមានជួរភ្នំព័ទ្ធជុំវិញ បានរំលេចឡើងនូវទេសភាពពណ៌បៃតងស្រស់ ដែលជាសញ្ញាបញ្ជាក់ពីរដូវធ្វើស្រែចម្ការបានមកដល់ហើយ។ ប្រជាជនប្រមាណ៩៥ភាគរយរស់នៅភូមិបាក់នឹម មានមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត។ ដោយឡែកការថែទាំសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹមក៏ជាការចាំបាច់ក្នុងរដូវភ្លៀងធ្លាក់ ដោយសារការផ្លាស់ប្តូរអាកាសធាតុ និងវ័យកាន់តែចាស់ជរារបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលងាយនឹងទទួលផលប៉ះពាល់ដល់សុខភាព។ ដូច្នេះក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន៣នាក់ អមជាមួយវេជ្ជបណ្ឌិត ដេមី រេយស៍ គឺជាជនជាតិហ្វីលីពីន, វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន ដែលមានឯកទេសជំងឺទឹកនោមផ្អែម និងជំងឺលើសឈាម និងលោកស្រី អ៊ូ បញ្ញា គិលានុបដ្ឋាយិកា បានចុះទៅដល់មូលដ្ឋានដើម្បីពិនិត្យ



មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧១នាក់ នៅភូមិបាក់នឹម រយៈពេល៣ថ្ងៃជាប់គ្នា គឺចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សុខភាពបឋមដល់អ្នករស់រានមានជីវិតពីរបបខ្មែរ ដែលរស់នៅភូមិបាក់នឹមចំនួន៧១នាក់ក្នុងរយៈពេល ៣ថ្ងៃជាប់គ្នា គឺចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣។

នៅថ្ងៃដំបូង ការពិនិត្យសុខភាពចាប់ផ្តើមតាំងពីរសៀលថ្ងៃទី១៩ ដោយវេជ្ជបណ្ឌិត ដេមី រេយេស៍ ដោយធ្វើការពន្យល់ពីលទ្ធផលពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧ នាក់ ដែលបានទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យអេខេព្រីមមៀម នៅទីក្រុងភ្នំពេញ កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ កន្លងមក។ លទ្ធផលពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតចំនួន៧ នាក់ បានបង្ហាញថា មានអ្នកជំងឺ៣នាក់ ដែលមានជំងឺរលាកថ្លើមប្រភេទសេ(C) និងអ្នកជំងឺ១នាក់ មានជំងឺរលាកថ្លើមប្រភេទបេ(B)។ ចំណែកអ្នកជំងឺ៤នាក់ដែលមានរកឃើញជំងឺរលាកថ្លើមប្រភេទអា(A) វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន បានលើកឡើងថា «ដោយសារកត្តារស់នៅ និងប្រើប្រាស់ទឹកមិនស្អាត និងខ្វះអនាម័យ ទើបប្រជាជនប្រហែល ៩០ភាគរយដែលរស់នៅភូមិបាក់នឹម ត្រូវបានរកឃើញជំងឺថ្លើមប្រភេទ (A)»។ ចំពោះអ្នកជំងឺថ្លើមប្រភេទ បេ និងជំងឺថ្លើមប្រភេទ សេ វេជ្ជបណ្ឌិត បានណែនាំឲ្យអ្នកជំងឺទៅជួបប្រឹក្សាជាមួយវេជ្ជបណ្ឌិតឯកទេសជំងឺរលាកថ្លើមនៅតាមមន្ទីរពេទ្យខេត្ត ឬនៅទីក្រុងភ្នំពេញ ទើបអ្នកជំងឺអាចព្យាបាលបានត្រឹមត្រូវ និងមិនខាតបង់នូវថវិកា ទិញថ្នាំដែលមិនចំគោលដៅ។

បន្ទាប់មក លោកស្រីគិលានុបដ្ឋាយិកា អ៊ូ បញ្ញា ចាប់ផ្តើមវាស់សម្ពាធឈាមដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣២នាក់ គឺជាក្រុមទី១ ដែលត្រូវជួបពិគ្រោះជាមួយវេជ្ជបណ្ឌិតនៅថ្ងៃបន្ទាប់ ប៉ុន្តែដោយសារតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមានអាយុច្រើន និងមានបញ្ហាសុខភាព វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន ក៏សម្រេចចិត្តពិនិត្យ និងពិគ្រោះជំងឺនៅរសៀលថ្ងៃដដែលនេះតែម្តង។ មានអ្នកជំងឺ៥ នាក់ ដែលបានណែនាំឲ្យធ្វើការពិនិត្យចង្វាក់បេះដូងដោយម៉ាស៊ីនECG ដើម្បីឲ្យដឹងច្បាស់ថាអ្នកជំងឺពិតជាមានបញ្ហាបេះដូងមែន ឬមិនមែន ព្រោះយោងតាមការវាស់សម្ពាធឈាម និងការពិគ្រោះជំងឺ វេជ្ជបណ្ឌិតរកឃើញថាមានសញ្ញានៃ



ជំងឺបេះដូងៗ ក្រោយពីបានពិនិត្យ និងពិគ្រោះជំងឺរួចរាល់ មានតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ២ នាក់ប៉ុណ្ណោះដែលមានសុខភាពល្អ ប៉ុន្តែក៏ត្រូវត្រឡប់មកពិនិត្យមើលជាតិស្ករនៅក្នុងឈាមនាថ្ងៃបន្ទាប់ៗ ការពិនិត្យសុខភាពចាប់ផ្តើមម្តងទៀត នៅម៉ោង ៨ ព្រឹក ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ដោយមានការពិនិត្យជាតិស្ករក្នុងឈាមជូនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន៣២នាក់ ដែលមានអ្នកជំងឺ៣នាក់មានសញ្ញាណនៃជំងឺទឹកនោមផ្អែម គឺ៖

១) ហាន ចំរើន ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិស្ករក្នុងឈាម ១៦១

២) អ៊ុន នូ ភេទស្រី អាយុ ៧១ឆ្នាំ ជាតិស្ករក្នុងឈាម ១៣០

៣) ខ្វាត គៀន ភេទស្រី អាយុ ៧៥ឆ្នាំ ជាតិស្ករក្នុងឈាម ១៨០

វេជ្ជបណ្ឌិត ឡាវ ហ៊ាវ៉ាន ដែលមានឯកទេសជំងឺទឹកនោមផ្អែម បានណែនាំឲ្យអ្នកជំងឺដែលមានសញ្ញាណនៃជំងឺទឹកនោមផ្អែមទៅមន្ទីរពេទ្យបង្អែក



មជ្ឈមណ្ឌលឯកសារកម្ពុជាចុះពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៧១នាក់ នៅភូមិបាក់នឹម រយៈពេល៣ថ្ងៃជាប់គ្នា គឺចាប់ពីថ្ងៃទី១៩ ដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីធ្វើការពិនិត្យរោគវិនិច្ឆ័យបន្ថែម ដូចជា ការរាប់គ្រាប់ឈាម (CBC), ការពិនិត្យមុខងារតម្រងនោម (Creatinine), ការពិនិត្យមុខងារថ្លើម (Transaminase), ការពិនិត្យជាតិស្ករគោងគ្រាប់ឈាម (HbA1C), ការពិនិត្យកម្រិតខ្លាញ់អាក្រក់ (LDL) មុននឹងទទួលការព្យាបាល ព្រោះការប្រើប្រាស់ថ្នាំទឹកនោមផ្អែម អាច

មានផលប៉ះពាល់ដល់សរីរាង្គផ្សេងៗ។

ដោយឡែក សែម គុន្ធា មានបញ្ហាហើមត្របកភ្នែក រមាស់ភ្នែក និងហៀរទឹកភ្នែក វេជ្ជបណ្ឌិត ឡាវ ហាភាន ណែនាំឲ្យទៅជួបវេជ្ជបណ្ឌិតជំនាញនៅមន្ទីរខេត្តតាកែវ ដែលមានផ្តល់ការពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃ។

ស៊ិន ណែត មានអាយុ ៤៧ឆ្នាំ ពិនិត្យឃើញសារជាតិស្ករក្នុងឈាម ៥៤៨ វេជ្ជបណ្ឌិត ឡាវ ហាភាន បានណែនាំឲ្យទៅមន្ទីរពេទ្យបង្អែកភ្លាមៗ ព្រោះជាករណីត្រូវការសង្គ្រោះបន្ទាន់បើពុំដូច្នេះទេអ្នកជំងឺអាចនឹងប៉ះពាល់ដល់អាយុជីវិត។ លោកពូពយ អ៊ូច មេភូមិបាក់នឹម បានជួយពន្យល់បន្ថែមពីកត្តាហានិភ័យពីការឡើងសារធាតុស្ករក្នុងឈាមខ្ពស់ដោយលើកពីករណីផ្ទាល់ខ្លួនរបស់លោកដែលធ្លាប់ឆ្លងកាត់កន្លងមក និងបានប្រាប់ដល់ ស៊ិន ណែតឲ្យប្រើប្រាស់សេវាធ្វើដំណើរសាធារណៈដោយឥតគិតថ្លៃ ដែលឧបត្ថម្ភដោយមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីដើមខែមេសា ឆ្នាំ ២០២៣កន្លងមក ដើម្បីទៅទទួលការព្យាបាលឲ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាពនៅមន្ទីរពេទ្យបង្អែកក្នុងស្រុកជុំគិរី និងស្រុកឈូក ខេត្តកំពត។

ពេលរសៀលថ្ងៃដដែល ក្រុមទី២ ដែលមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន ៣២នាក់ទៀតបានមកទទួលការពិនិត្យសុខភាព ដូចក្រុមទី១ដែរ ក្នុងនោះមាននាយទាហានចំនួន ១៧ នាក់ ដែលបម្រើការងារនៅកងវរសេនាតូច ៣១២។ ការពិនិត្យសុខភាពដំណើរការដូចក្រុមទី១ គឺលោកស្រីគិលានុបដ្ឋាយិកា អ៊ូច បញ្ញា ចាប់ផ្តើមវាស់សម្ពាធឈាមជូនអ្នករស់រានមានជីវិតទាំង៣២នាក់ និងធ្វើការពិនិត្យចង្វាក់បេះដូងដោយម៉ាស៊ីន ECG ក្នុងករណីដែលមានសង្ស័យថាមានជំងឺបេះដូង ដោយមានការពិនិត្យ និងពិគ្រោះជំងឺដោយវេជ្ជបណ្ឌិត ឡាវ ហាភាន ក្នុងនោះមានអ្នកជំងឺ៥នាក់ ដែលស្នើឲ្យធ្វើការពិនិត្យសង្វាក់បេះដូងដោយម៉ាស៊ីន ECG និងរកឃើញសញ្ញាណនៃជំងឺបេះដូង។

នៅម៉ោង៨ព្រឹកថ្ងៃបន្ទាប់ គឺថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្រុមទី២ បានមកជួបជុំគ្នាម្តងទៀតដើម្បីពិនិត្យជាតិស្ករក្នុងឈាម ក្នុងនោះមានអ្នកជំងឺ ៣នាក់ដែលមានសញ្ញាណនៃជំងឺទឹកនោមផ្អែម គឺ៖

១) ស្រី សារ៉ាន់ ភេទស្រី អាយុ ៤១ឆ្នាំ ជាតិស្ករក្នុងឈាម ១៥៦

២) រីក ប៉ាក់ ភេទប្រុស អាយុ ៥៨ឆ្នាំ ជាតិស្ករក្នុងឈាម ១៤៣

៣) ញ៉ា ចាន់ថា ភេទប្រុស អាយុ ២១ ឆ្នាំ ជាតិស្ករក្នុងឈាម ១៥៨

វេជ្ជបណ្ឌិត ឡាវ ហាភាន បានណែនាំឲ្យអ្នកជំងឺដែលមានសញ្ញាណនៃជំងឺទឹកនោមផ្អែមឲ្យទៅមន្ទីរពេទ្យបង្អែកដើម្បីធ្វើការពិនិត្យរោគវិនិច្ឆ័យបន្ថែម មុននឹងទទួលការព្យាបាលដូចក្រុមទី១ដែរ។

ព្រឹកថ្ងៃដដែលនេះក៏មានការចូលរួមចុះសួរសុខទុក្ខពីឯកអគ្គរដ្ឋទូតហ្វីលីពីនដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមកទទួលសេវាពិនិត្យ និងពិគ្រោះជំងឺនៅភូមិបាក់នឹម ដោយវេជ្ជបណ្ឌិតជនជាតិហ្វីលីពីន វេជ្ជបណ្ឌិត ដេមី រេយេស៍ ឯកទេសវះកាត់មហារីក។ តាមការពិនិត្យ និងពិគ្រោះជំងឺ វេជ្ជបណ្ឌិត ដេមី រេយេស៍ បានរកឃើញអ្នកជំងឺ ៣នាក់ ដែលចាំបាច់ត្រូវទៅទទួលការពិនិត្យ និងព្យាបាលបន្ថែមនៅទីក្រុងភ្នំពេញ រួមមាន៖

១) ជ្រីវណ្ណា ភេទស្រី អាយុ ៦១ឆ្នាំ មានសម្ពាធឈាមឡើងខ្ពស់ ដែលបានទទួលការសង្គ្រោះដោយវេជ្ជបណ្ឌិត ដេមី រេយេស៍ និងពិនិត្យចង្វាក់បេះដូងដោយម៉ាស៊ីន ECG រកឃើញមានជំងឺបេះដូងដែលតម្រូវឲ្យអ្នកជំងឺទៅពិនិត្យអេកូទស្សន៍បេះដូងបន្ថែម មុននឹងទទួលការព្យាបាលឲ្យបានត្រឹមត្រូវ។

២ ឡុង សារ៉េត ភេទស្រី អាយុ ៥២ឆ្នាំ វេជ្ជបណ្ឌិត ដេមី រេយេស៍ ណែនាំឲ្យប្រើប្រាស់ថ្នាំចាក់ដើម្បីឲ្យម្រាមដៃអាចធ្វើចលនាឡើងវិញបាន ព្រោះ

បើមិនដូច្នេះទេ ម្រាមដៃនឹងរីងស្វិតសរសៃបណ្តាលឲ្យមានពិការភាពនាពេលអនាគត។

៣) ទន់ អៀច ភេទប្រុស អាយុ ៦១ឆ្នាំ មានជំងឺសើស្បែកពុំរ៉ៃនៅកដើងខាងស្តាំ វេជ្ជបណ្ឌិត ដេមីរេយស៍ បានណែនាំឲ្យធ្វើការពិនិត្យសាច់ដើងស្វែងរកមេរោគ ឬបាក់តេរីដែលបង្កដល់ជំងឺសើស្បែកនេះ នៅទីក្រុងភ្នំពេញ ដើម្បីទទួលការព្យាបាលឲ្យបានទាន់ពេលវេលា និងត្រឹមត្រូវ។

តាមការសង្កេតរបស់វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន បានឲ្យដឹងថា ក្នុងការពិនិត្យសុខភាពជូនប្រជាជនរយៈពេល ៣ថ្ងៃកន្លងមកនេះ ក្នុងចំណោមអ្នករស់រានមានជីវិតទាំង៧១នាក់ ភាគច្រើនមានជំងឺលើសឈាម ជំងឺសន្លាក់ និងជំងឺបន្ទាប់បន្សំមានជំងឺក្រពះពោះវៀន ជំងឺសើស្បែក ជំងឺទឹកនោមផ្អែម និងជំងឺស្លាប់មួយចំហៀងខ្លួន៤ករណី ហើយករណីស្លាប់មួយចំហៀងខ្លួនដែលកើតឡើងលើអ្នកជំងឺដែលមានវ័យក្មេង ក្នុងអាយុ ៣០ឆ្នាំឡើង មាន២ករណី ដែលជាករណីកម្រ។ វេជ្ជបណ្ឌិតបានបន្តថា ប្រជាជនក្នុងភូមិបាក់នឹម ខ្វះការយល់ដឹងពីបញ្ហាសុខភាពខ្លាំង ដូច្នេះគួរតែបន្តមានការអប់រំសុខភាព អប់រំពីការធ្វើអនាម័យ អប់រំពីការថែទាំសុខភាព ដើម្បីកុំឲ្យអ្នកជំងឺមានការវិវឌ្ឍន៍ទៅរកជំងឺពុំរ៉ៃ (ជំងឺទឹកនោមផ្អែម និងជំងឺលើសឈាម) អប់រំអំពីផលប៉ះពាល់សុខភាពនៃការជក់បារី (ពូៗ និងបងប្អូនប្រុសៗ) និងការពិសាគ្រឿងស្រវឹង, អប់រំពីរបបអាហារដើម្បីឲ្យជៀសឆ្ងាយពីជំងឺផ្សេងៗទៀត។ ដោយឡែកជំងឺសន្លាក់ភាគច្រើនកើតលើវ័យចាស់ និងជាមនុស្សស្រី អាចដោយសារកត្តាអ័រម៉ូន កត្តាអស់រដូវដែលធ្វើឲ្យការផលិតសារជាតិកាល់ស្យូមបានទាប និងការធ្វើការការងារធ្ងន់ពេលនៅវ័យក្មេងក្នុងរបបខ្មែរក្រហមដែរ។ វេជ្ជបណ្ឌិត ឡាវ ហាវ៉ាន ផ្តល់អនុសាសន៍បន្ថែមទៅលើការចេញវេជ្ជបញ្ជាដល់អ្នកជំងឺ ដែលមានការពិបាកក្នុងការស្វែងរកទិញថ្នាំ ជាពិសេសថ្នាំដែលបានចេញដោយវេជ្ជបណ្ឌិតជនជាតិបរទេស។ ដូច្នេះ មជ្ឈមណ្ឌលឯកសារកម្ពុជា គួរតែស្វែងរកមន្ទីរពេទ្យដៃគូ ឬស្វែងរកទីតាំងឱសថស្ថានដែលមានថ្នាំល្អ និងមានជំនាញច្បាស់លាស់ ដើម្បីអាចផ្តល់ជាព័ត៌មានដល់អ្នកជំងឺឲ្យទៅទិញថ្នាំបានត្រឹមត្រូវ ព្រោះមានករណីដែលអ្នកជំងឺទៅទិញថ្នាំដែលមិនត្រឹមត្រូវតាមវេជ្ជបញ្ជា ដូច្នេះអ្នកជំងឺត្រូវខាតបង់ទាំងថវិកាទិញថ្នាំ ថវិកាធ្វើដំណើរ និងពេលវេលាបន្ថែមទៀត ដោយពុំបានព្យាបាលត្រឹមត្រូវ និងធ្វើឲ្យប៉ះពាល់ដល់សុខភាពបន្ថែមទៀត។

ការពិនិត្យសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅភូមិបាក់នឹម គឺជាការពិនិត្យសុខភាពនៃក្រុមចុងក្រោយដែលមានចំនួនសរុប១៦៩ នាក់ដែលបានទទួលការពិនិត្យ និងពិគ្រោះជំងឺកន្លងមកចំនួន៤លើក គឺលើកទី១ ចំនួន ៤៣នាក់ ពីថ្ងៃទី១៧-១៨ ខែមីនា ឆ្នាំ២០២៣, លើកទី២ ចំនួន ៤១នាក់ ពីថ្ងៃទី២៥-២៦ ខែមីនា ឆ្នាំ២០២៣, និងលើកទី៣ និងទី៤ ចំនួន ៧១នាក់ ពីថ្ងៃទី១៩-២១ ខែមិថុនា ឆ្នាំ២០២៣។ បើតាមការសង្កេតអ្នកភូមិបាក់នឹម ពិតជាត្រូវការចាំបាច់នូវការអប់រំបន្ថែមពីការថែទាំសុខភាព ផលប៉ះពាល់ដល់សុខភាពដោយការជក់បារី ការពិសាគ្រឿងស្រវឹង និងរបបអាហារប្រចាំថ្ងៃ ដែលជាបញ្ហាចម្បងនៃការឈានដល់ការកើតជំងឺពុំរ៉ៃ (ជំងឺទឹកនោមផ្អែម និងជំងឺលើសឈាម) ដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅភូមិបាក់នឹមនេះ។

ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងរៀបចំវេទិកាពិភាក្សាអំពីកូនសៀវភៅស្តីអំពីព័ត៌មានពីការថែទាំសុខភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបន្ថែមទៀតនាពេលអនាគត ព្រោះការយល់ដឹងពីការថែទាំសុខភាព អាចជួយកាត់បន្ថយដល់ការចំណាយថវិកាបន្ថែមលើការព្យាបាល និងការធ្វើដំណើរទៅទទួលការព្យាបាល ដែលជាកត្តាជួយឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម មានជីវភាពប្រសើរ និងមានសុខភាពល្អ។

# រឿងរ៉ាវជីវិតរបស់ស្ត្រីនៅក្នុងសហគមន៍ បន្ទាប់ពីរបបខ្មែរក្រហម និងបម្រែបម្រួលអាកាសធាតុក្នុងជីវភាពប្រចាំថ្ងៃ

*សាំង ចាន់ធូ*



សហគមន៍នេសាទរបស់ជនជាតិចាមនៅស្រុកកោះសូទិន ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ចន្លោះពីថ្ងៃទី១៤ ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាស្ត្រីចំនួន១១នាក់មកពីសហគមន៍កោះសូទិន និងកំពង់ចាម ចូលរួមកិច្ចការងារស្រាវជ្រាវអំពីបម្រែបម្រួលអាកាសធាតុ និងការរស់នៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានជួប និងចែករំលែកក្រុមការងារស្រាវជ្រាវដឹកនាំដោយ ព្រះអង្គម្ចាស់ក្សត្រី នរោត្តម កែវប៉ូនីតា រស្មី ទាក់ទងនឹងបទពិសោធន៍ក្នុងរបបខ្មែរក្រហម ការប្រកបរបរចិញ្ចឹមជីវិត និងការយល់ឃើញអំពីផលប៉ះពាល់អំពីបម្រែបម្រួលអាកាសធាតុដល់ជីវភាពរបស់ខ្លួន។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីសហគមន៍កោះសូទិន ដែលជាជនជាតិចាម និងខ្មែរ បានលើកឡើងអំពីការបាត់បង់សមាជិកគ្រួសារ និងបទពិសោធន៍ក្នុងរបបខ្មែរក្រហម ទាក់ទងការនេសាទត្រី និងការដាំដុះដំណាំ។ ចំណែកឯ

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីសហគមន៍កោះសូទិនផ្សេងទៀតបាននិយាយអំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម និងការធ្វើស្រែ ដាំបន្លែ។

## ញឹម ចាន់ថា



ញឹម ចាន់ថា ភេទស្រី អាយុ៦៤ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអ្នកដាំពោតរស់នៅភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម រៀបរាប់អំពីប្រវត្តិរបស់ខ្លួនថា «ខ្ញុំរៀបការប្តីឈ្មោះ ហ៊ាប ផល្លា ខ្ញុំមានកូនប្រុសស្រីសរុបចំនួន៣នាក់ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ឪពុកខ្ញុំឈ្មោះ ញឹម ឆុននិងម្តាយឈ្មោះ ហ៊ី ហ៊ឹម។ ខ្ញុំគឺជាកូនទី២ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៥នាក់។ ខ្ញុំកើតនៅភូមិទី១២ ឃុំកោះសូទិន ស្រុកកោះសូទិននេះតែម្តង។ នៅពីវ័យក្មេង ខ្ញុំទៅរៀននៅសាលាបឋមសិក្សាចុងកោះបានថ្នាក់ទី៩សង្គមចាស់។ ខ្ញុំបានឈប់រៀនមកជួយធ្វើការជាមួយឪពុកម្តាយដោយសារជីវភាពលំបាក។ បន្ទាប់ពីមានការធ្វើរដ្ឋប្រហាររបស់លន់ នល់នៅឆ្នាំ១៩៧០ អ្នកភូមិជាច្រើនបានចូលរួមបាតុកម្ម ដង្ហែទៅទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧២ ចាប់តាំងពីមានវត្តមានកងទ័ពរំដោះខ្មែរក្រហមចូលនៅក្នុងភូមិ ទាហានលន់ នល់ បានបើកការបាញ់ប្រហារ និងផ្លោងគ្រាប់បែកពីភ្នំប្រុសនិងការទម្លាក់គ្រាប់បែក។ នៅឆ្នាំ១៩៧៣ ក្រុមគ្រួសាររបស់ខ្ញុំរត់គេចខ្លួនទៅរស់នៅខាងត្រើយម្ខាងជីហែរមួយរយៈ។ នៅឆ្នាំ១៩៧៤ និងដើមឆ្នាំ១៩៧៥ ខ្ញុំបានវិលត្រឡប់មកស្រុកកំណើតធ្វើការនៅកងប្រវាស់ដៃ ដូចជាជួយច្រូតស្រូវ និងប្រមូលផលដំណាំផ្សេងៗមកចែកគ្នាហូប។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមចាប់ផ្តើមបង្កើតជាសហករណ៍ និងចាត់តាំងឲ្យធ្វើការនៅកងចល័ត នៅតាមការដ្ឋានលើកទំនប់នៅឆ្នុកទ្រ គ្រពាំងទា ត្នោត អូររាំងឪ។ ខ្ញុំត្រូវងើបពីម៉ោង៥ និងទៅប្រជុំជួររយៈពេលកន្លះម៉ោង តាមការចាត់ចែងឲ្យទៅធ្វើការតាមគោលដៅរបស់ខ្មែរក្រហមដាក់ឲ្យ។ ខ្ញុំធ្វើការពីម៉ោង៦ព្រឹកដល់ម៉ោង១១ ទើបឈប់សម្រាកហូបបបរ។ ខ្ញុំបន្តធ្វើការទៀតពីម៉ោង១ដល់ម៉ោង៥ល្ងាច។ នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅកងចល័តរែកដី និងលើកទំនប់ពីកន្លែងមួយរួចទៅកន្លែងមួយទៀត។ នៅពេលនោះអង្គការបានរៀបការឲ្យយុវជននិងយុវនារីនៅកងចល័ត ដោយចាប់គូដែលមានចំនួន៤៣គូ ហើយនៅក្នុងនោះមានខ្ញុំម្នាក់ដែរ។ ខ្ញុំបន្តធ្វើការងារនៅតាមការដ្ឋានរហូតដល់ពេលមានកងទ័ពរណសិរ្ស សាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមកដល់រំដោះប្រជាជនចេញពីរបបខ្មែរក្រហមថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបខ្ញុំវិលត្រឡប់មកស្រុកកំណើតវិញ»។

## ភួង ស្រ៊ន់



ភួង ស្រ៊ន់ ភេទស្រី អាយុ៥៥ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអ្នកដាំបន្លែរស់នៅភូមិដំបងដែក ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម បាននិយាយរៀបរាប់អំពីការចងចាំពីកុមារភាពរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមថា «ខ្ញុំកើតនៅឆ្នាំ១៩៦៩ នៅភូមិដំបងដែក ឃុំកោះរកា ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំរៀបការជាមួយប្តីឈ្មោះ ទូច វ៉ាន់ និង មានកូនប្រុសស្រីទាំងអស់ចំនួន៤នាក់។ ខ្ញុំមានឪពុកឈ្មោះ ភួង ផន និងម្តាយឈ្មោះ ផ្លុក លី។ ខ្ញុំមានបងប្អូនប្រុសស្រីទាំងអស់ចំនួន

៦នាក់។ កាលពីវ័យកុមារ ខ្ញុំរៀនសូត្រត្រឹមថ្នាក់ទី៩ចាស់នៅសាលាបឋមសិក្សាដំបងដែក។ ក្រោយមកទៀត ខ្ញុំឈប់រៀនពីព្រោះឪពុកម្តាយមានជីវភាពខ្វះខាត។ បន្ទាប់ពីបានឈប់រៀន ខ្ញុំមកជួយលក់ទឹកអំពៅឪពុកម្តាយ ដើម្បីយកកម្រៃផ្គត់ផ្គង់ភាពខ្វះខាតនៅក្នុងគ្រួសារ។ ដោយសារកាលនោះខ្ញុំនៅវ័យក្មេង ដូច្នេះខ្ញុំនៅចងចាំហេតុការណ៍បន្តិចបន្តួចប៉ុណ្ណោះអំពីសង្គ្រាម និងរបបខ្មែរក្រហម ៖

- នៅឆ្នាំ១៩៧៣ សង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើង និងមានការបាញ់ផ្លោង ការទម្លាក់គ្រាប់បែកបណ្តាលឲ្យផ្ទះរបស់អ្នកភូមិឆេះ។ គ្រួសារខ្ញុំបានរត់ចេញពីភូមិតាមរទេះគោទៅដល់ភូមិថ្មីក្រោម ដែលជាតំបន់រំដោះរបស់ខ្មែរក្រហម។
- នៅឆ្នាំ១៩៧៥ គ្រួសារខ្ញុំវិលត្រឡប់មកនៅក្នុងភូមិវិញ។ នៅចុងឆ្នាំ១៩៧៥ ឪពុកម្តាយរបស់ខ្ញុំ ត្រូវបានចាត់តាំងធ្វើការនៅកងចល័តក្នុងសហករណ៍។ បងប្អូនរបស់ខ្ញុំត្រូវទៅធ្វើការនៅតាមកងចល័តរៀងៗខ្លួន។ ចំណែកឯខ្ញុំត្រូវចូលធ្វើការនៅកងកុមារ គឺដើរកាត់ស្លឹកឈើ និងរើសអាចម៍គោធ្វើជីដាក់ស្រែ។ មិនយូរប៉ុន្មានឪពុករបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ និងស្លាប់ដោយសារតែការហូបអាហារមិនគ្រប់គ្រាន់ និងគ្មានថ្នាំព្យាបាល។
- នៅឆ្នាំ១៩៧៦ ភូមិដំបងដែកត្រូវបានទឹកជំនន់ជន់លិច ដូច្នេះគ្រួសាររបស់ខ្ញុំត្រូវបានបញ្ជូនទៅភូមិទួលស្រែ។
- នៅឆ្នាំ១៩៧៧ ម្តាយ និងបងប្អូនរបស់ខ្ញុំ ត្រូវបានចាត់តាំងឲ្យទៅ កាប់ឆ្ការព្រៃដើម្បីពង្រីកផ្ទៃដីដាំដុះស្រូវ និងភ្ជួររាស់ដីដាំស្រូវ។ បន្ទាប់ពីប្រមូលផលស្រូវរួចរាល់ គ្រួសារខ្ញុំត្រូវបានបញ្ជូនមករស់នៅក្នុងភូមិវិញ។
- នៅឆ្នាំ១៩៧៨ គ្រួសារខ្ញុំត្រូវបានផ្លាស់ឲ្យទៅរស់នៅ និងលើកទំនប់ព្រែកជីក អស់រយៈពេល៣ខែ។
- នៅឆ្នាំ១៩៧៩ ខណៈពេលដែលគ្រួសារខ្ញុំធ្វើការនៅការដ្ឋានទំនប់ព្រែកជីក កងទ័ពរណសិរ្សសង្គ្រោះជាតិកម្ពុជាចូលមកដល់។ នៅពេលនោះ គ្រួសាររបស់ខ្ញុំរួចផុតពីសេចក្តីស្លាប់ និងធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃ»។

## ប៊ួន ឈុនឡោម



ប៊ួន ឈុនឡោម ភេទស្រី អាយុ៦៦ឆ្នាំ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអ្នកត្បាញក្រមា និងសំពត់សូត្រខ្មែររំឭកអំពីសាវតារ និងរឿងរ៉ាវរបស់ខ្លួនដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហមដូចតទៅ «ខ្ញុំឈ្មោះ ប៊ួន ឈុនឡោម អាយុ៦៦ឆ្នាំ ភេទស្រី មុខរបរកសិករ បច្ចុប្បន្នរស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ ប៊ួន ស្រេង និងម្តាយឈ្មោះ អេង។ ខ្ញុំមានបងប្អូនប្រុសស្រីទាំងអស់ចំនួន៦នាក់ ប្រុស១នាក់ និងស្រី៥នាក់។ ខ្ញុំកើតនៅភូមិចំការសាមសិបតែម្តង។ កាលនៅវ័យកុមារ ខ្ញុំរៀនសូត្រត្រឹមថ្នាក់ទី៧ចាស់នៅសាលាបឋមសិក្សាគគរ។ ក្រោយមកទៀត ខ្ញុំឈប់រៀនដោយសារតែខ្ញុំត្រូវទៅរៀនបន្តនៅវិទ្យាល័យស្ថិតនៅទីរួមខេត្តកំពង់ចាម ហើយឪពុកម្តាយមានការព្រួយបារម្ភ។ នៅពេលឈប់រៀន ខ្ញុំមកជួយការងារឪពុកម្តាយនៅផ្ទះវិញ។ ខ្ញុំត្បាញក្រមាដើម្បីលក់សម្រាប់ជីវភាពប្រចាំថ្ងៃ។ ពេលនោះគឺឆ្នាំ១៩៦៩ បងប្រុសរបស់ខ្ញុំម្នាក់បន្តការសិក្សានៅទីរួមខេត្តកំពង់ចាម ដោយបានសុំវត្តស្នាក់អាស្រ័យ។ ក្រោយមកខ្ញុំឃើញអ្នកភូមិចូលរួមធ្វើបាតុកម្មប្រឆាំងការធ្វើរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ ក្នុងអំឡុងពេលធ្វើបាតុកម្ម ក៏មានការបង្ក្រាបបែបហិង្សាកើតមានឡើង និងបន្តរហូតដល់មានការផ្ទុះអាវុធប្រឆាំងនឹងអ្នកចូលរួមធ្វើបាតុកម្ម។ ឪពុករបស់ខ្ញុំក៏ចូលរួមធ្វើបាតុកម្មដែរ។ សំណាងល្អ គាត់មិនរងរបួស

ប្រគ្រោះថ្នាក់ ព្រោះគាត់មានតួនាទីជាអ្នកយកជំនួយស្បៀងអាហារចែកជូនដល់បាតុករ។ បាតុកម្មនោះមានរយៈពេលមួយសប្តាហ៍។

នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមប្រដាប់ដោយអាវុធគ្រប់ដៃចូលមកស្នាក់អាស្រ័យក្នុងភូមិ។ កងទ័ពរំដោះខ្មែរក្រហមដាក់គោលដៅចូលវាយរំដោះយកទីរួមខេត្តកំពង់ចាម។ កងទ័ពរំដោះខ្មែរក្រហម និងទាហានលន់ នល់ ប្រយុទ្ធតទល់គ្នាជាច្រើនសមរភូមិ។ ប៉ុន្តែនៅពេលនោះ កងទ័ពរំដោះខ្មែរក្រហមទទួលបរាជ័យ និងដកទ័ពទៅតំបន់រំដោះរបស់ខ្លួនស្ថិតនៅត្រើយម្ខាងនៃទន្លេមេគង្គ។ បន្ទាប់មកយន្តហោះរបស់ទាហានលន់ នល់ បើកការវាយប្រហារតាមផ្លូវអាកាស ដោយបានទម្លាក់គ្រាប់បែកនៅភូមិរបស់ខ្ញុំ។ ដោយមានការភ័យខ្លាចពីសុវត្ថិភាព ឪពុកម្តាយរបស់ខ្ញុំនាំកូនៗរត់ចេញពីភូមិទៅស្នាក់នៅត្រើយម្ខាងទន្លេរហូតទៅដល់ភូមិសាស្ត្រដីហែ។ ផ្ទះរបស់ខ្ញុំត្រូវបានទាហាន លន់ នល់ ប្រើប្រាស់ជាមន្ទីរពេទ្យព្យាបាលទាហានរបួសនៅក្នុងសមរភូមិ។ នៅកន្លែងភៀសខ្លួន គ្រួសាររបស់ខ្ញុំធ្វើចម្ការ និងបន្តស្នាក់នៅរហូតដល់ចុងឆ្នាំ១៩៧៤។ ក្រោយមកគ្រួសាររបស់ខ្ញុំវិលត្រឡប់មកភូមិ និងមករស់នៅផ្ទះវិញ ព្រោះទាហាន លន់ នល់ ដកកម្លាំងមកទីរួមខេត្តកំពង់ចាមចេញវិញ។ នៅភូមិរបស់ខ្ញុំ មានប្រធានភូមិឈ្មោះ វ៉ាត។ នៅឆ្នាំ១៩៧៥ ទីរួមខេត្តកំពង់ចាមត្រូវបានធ្លាក់នៅក្រោមការគ្រប់គ្រងរបស់កងទ័ពរំដោះខ្មែរក្រហម។ នៅអំឡុងពេលនោះ ខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្តកំពង់ចាម។ ប្រជាជនជម្លៀសទាំងនោះដើរឆ្លងកាត់ភូមិចំការសាមសិបដើម្បីវិលត្រឡប់មកទៅភូមិកំណើតរៀងៗខ្លួន ដោយសារការបង្ខំជាពិសេសគឺប្រជាជនថ្មីមកពីភ្នំពេញ។ ការជម្លៀសប្រជាជនមានរយៈពេល១ខែ ទើបមានសភាពស្ងប់ស្ងាត់វិញ។ ស្ថានភាពនៅក្នុងភូមិចំការសាមសិបចាប់ផ្តើមផ្លាស់ប្តូរបន្តិចម្តងៗ ពីព្រោះអង្គការបង្កើតសហករណ៍ដែលមានគ្រួសារសរុបប្រមាណ១៤គ្រួសារ។

នៅឆ្នាំ១៩៧៦ ខ្ញុំមានអាយុ២០ឆ្នាំ និងត្រូវបានបញ្ជូនឲ្យទៅធ្វើការងារនៅកងចល័តស្រុកដើម្បីលើកទំនប់ នៅតំបន់២២។ ក្រោយមកទៀត ខ្ញុំត្រូវបានផ្លាស់ទៅលើកទំនប់នៅភូមិសាស្ត្រព្រៃឈរ។ សមមិត្ត ទីន និងសមមិត្ត ស៊ីម គឺជាប្រធានក្តាប់រួមនៅកងចល័ត។ នៅពេលនោះ ប្អូនស្រីរបស់ខ្ញុំមានអាយុត្រឹមតែ១២ឆ្នាំតែប៉ុណ្ណោះ និងត្រូវបានបញ្ជូនទៅលើកទំនប់ជាមួយខ្ញុំដែរ។ ការលើកទំនប់វិញគឺមានរយៈពេល៦ខែ ចំណែកការធ្វើស្រែវិញគឺមានរយៈពេល៦ខែដូចគ្នាដែរ។ កងចល័តស្រុកកំពង់សៀម ត្រូវបានបែងចែកជាក្រុមដែលមានសមាជិកប្រមាណ១៥នាក់។ សមមិត្ត ថា ណាត គឺជាប្រធានក្រុម។ នៅកងចល័ត ខ្ញុំត្រូវក្រោកនៅម៉ោង៣:០០ ទៀបភ្លឺដើម្បីចូលរួមប្រជុំអំពីការដាក់ផែនការ។ រហូតម៉ោង៤:០០ព្រឹក ខ្ញុំទៅធ្វើការនៅតាមការដ្ឋានរហូតដល់ម៉ោង១២ថ្ងៃត្រង់។ ខ្ញុំទទួលបានបបររាវ។ លុះដល់ម៉ោង១២:៣០ ខ្ញុំត្រូវចូលធ្វើការរហូតដល់ម៉ោង៦ល្ងាចទើបឈប់សម្រាក។ សម្ភារសម្រាប់លើកទំនប់គឺរួមមាន ចប បង្គី ដែលត្រូវបានដឹកចេញពីរោងជាង។ ក្រុមរបស់ខ្ញុំជីកដី និងរែកដីបណ្តោយ ៥០ម៉ែត្រ។ ការកាប់ដីត្រូវបានដាក់ផែនការកំណត់គឺមួយក្រុមតូច ដែលមានសមាជិក៣នាក់ ត្រូវជីកដី៩ម៉ែត្រគុបក្នុងមួយថ្ងៃ។ កងចល័តបុរសប្រចាំស្រុកកំពង់សៀម គឺគ្រប់គ្រងដោយប្រធានឈ្មោះ សមមិត្ត យុទ្ធ។ នៅក្នុងក្រុមរបស់ខ្ញុំមានលាយឡំគ្នារវាងប្រជាជនមូលដ្ឋាន និងប្រជាជនថ្មីដែលជម្លៀសមកពីភ្នំពេញ ប៉ុន្តែប្រជាជនថ្មីបានបាត់ខ្លួនជាបន្តបន្ទាប់ដោយមិនដឹងមូលហេតុ។

បន្ទាប់មក ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅកងចល័តនៅការដ្ឋាន រពាក់ ទ្រា និងរអាង ជាដើម។ នៅឆ្នាំ១៩៧៧ ឪពុករបស់ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចាប់ខ្លួនយកទៅសម្លាប់ ក្រោមមូលហេតុដើម្បីដកអ្នកចាស់ដាក់អ្នកថ្មី រឺមានន័យថា «បោសសម្អាតអ្នកចាស់ដាក់អ្នកថ្មី»។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានកំណត់

កម្មាភិបាលមូលដ្ឋានក្នុងភូមិភាគបូព៌ា សាច់ញាតិរបស់កម្មាភិបាលមូលដ្ឋាន ប្រជាជនប្រព្រឹត្តខុសឆ្គង និងជនជាតិភាគតិចខ្មែរឥស្លាមដើម្បីចាប់ខ្លួនយកទៅសម្លាប់ចោល។ នៅចុងឆ្នាំ១៩៧៨ មានការផ្ទុះអាវុធ ហើយនៅដើមឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានចូលមករំដោះប្រជាជនកម្ពុជា។ ខ្ញុំរួចផុតពីសេចក្តីស្លាប់ និងជួបជុំគ្រួសារ។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងត្បាញក្រមាលក់ដើម្បីជីវភាពប្រចាំថ្ងៃ»។

## ម៉ៅ វណ្ណា



ម៉ៅ វណ្ណា គឺអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអតីតនាយកសាលាបឋមសិក្សាវត្តទីប្រជុំ និងជាអ្នកដាំពោត បានចែករំលែកអំពីប្រវត្តិរបស់ខ្លួនថា «ខ្ញុំឈ្មោះ ម៉ៅ វណ្ណា ភេទស្រី អាយុ៦២ឆ្នាំ រស់នៅក្នុងភូមិទី៨ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ សុខ ង៉ុយ និងមានកូនប្រុសស្រីចំនួន៣នាក់។ ខ្ញុំគឺជាអតីតនាយកសាលាបឋមសិក្សាទីប្រជុំ ដែលស្ថិតនៅភូមិទី៨នេះ។ ខ្ញុំមានឪពុកឈ្មោះ ម៉ៅ លាងគ្រី ដែលជាគ្រូបង្រៀននៅវិទ្យាល័យជម្ពូវ័ន និងម្តាយឈ្មោះ ម៉ៅ សុផល គឺជាមេផ្ទះ។ ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមសម្លាប់ គឺនៅសល់តែខ្ញុំនិងប្អូនម្នាក់ប៉ុណ្ណោះដែលរួចរស់ជីវិត។

នៅវ័យកុមារ ខ្ញុំចូលរៀននៅសាលាបឋមសិក្សាចុងកោះរហូតដល់ថ្នាក់ទី៧ចាស់។ ក្រោយមកទៀតកងទ័ពរំដោះខ្មែរក្រហមបានចូលមកដល់ និងបានស្នាក់នៅក្រោមផ្ទះរបស់អ្នកភូមិទី៨។

នៅចុងឆ្នាំ១៩៧០ និងដើមឆ្នាំ១៩៧១ សង្គ្រាមរវាង ទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានផ្ទុះឡើងជាច្រើនសមរភូមិនៅស្រុកកោះសូទិន។ ចាប់ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៣ ទាហាន លន់ នល់ បានបើកការវាយប្រហារទៅលើកងទ័ពរំដោះខ្មែរក្រហមដែលឈរជើងនៅក្នុងស្រុកកោះសូទិនកាន់តែខ្លាំងឡើងៗ។ ដោយមានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់ខ្ញុំឪពុកម្តាយខ្ញុំបានមកយកខ្ញុំទៅរស់នៅជាមួយគាត់នៅជាយក្រុងភ្នំពេញវិញ។

ខ្ញុំបានចូលរៀនបន្តនៅសាលាបឋមសិក្សាជម្ពូវ័នរហូតដល់ថ្នាក់ទី៤។ នៅដើមឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំបានទទួលដំណឹងថាកងទ័ពខ្មែរក្រហមបានចូលមកកៀកទីក្រុងភ្នំពេញហើយ។ នៅពេលនោះ ឪពុករបស់ខ្ញុំបានប្រាប់ម្តាយខ្ញុំឲ្យនាំកូនៗចូលក្នុងក្រុងភ្នំពេញ និងទៅស្នាក់នៅផ្ទះម្តុំទួលស្វាយព្រៃបណ្តោះអាសន្ន។ ចំណែកឯ ឪពុករបស់ខ្ញុំជិះកង់មកតាមក្រោយ។ បន្ទាប់ពីស្នាក់នៅមិនបានប៉ុន្មានថ្ងៃ ទីក្រុងភ្នំពេញត្រូវបានកងទ័ពរំដោះខ្មែរក្រហមវាយបែក និងគ្រប់គ្រង។ គ្រួសាររបស់ខ្ញុំគឺស្ថិតនៅក្នុងចំណោមគ្រួសាររាប់ពាន់ផ្សេងទៀតដែលត្រូវបានខ្មែរក្រហមជម្លៀសដោយបង្ខំចេញពីទីក្រុងភ្នំពេញ។ ឪពុកម្តាយរបស់ខ្ញុំសម្រេចចិត្តនាំកូនៗត្រឡប់មកភូមិកំណើតនៅកោះសូទិន ដើម្បីរស់នៅជាមួយយាយរបស់ខ្ញុំវិញ។ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរជាច្រើនថ្ងៃទើបមកដល់ភូមិ។

បន្ទាប់ពីមកដល់ភូមិវិញ គ្រួសាររបស់ខ្ញុំត្រូវបានប្រជាជនមូលដ្ឋានហៅថាប្រជាជន១៧មេសា ព្រោះមានប្រវត្តិរូបធ្លាប់ធ្វើជាគ្រូបង្រៀននៅក្នុងរបបចាស់។ ក្រោយមក ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅការដ្ឋានភូមិតាណុង គឺជាកន្លែងប្រមូលផ្តុំប្រជាជនដែលជាប់និន្នាការជាមួយរបប លន់ នល់ ដើម្បីលត់ដំខ្លួន។ នៅពេលនោះ ខ្ញុំមិនបានទៅនៅជាមួយឪពុកម្តាយ និងបងប្អូនទេពីព្រោះយាយរបស់ខ្ញុំបានប្រាប់មេភូមិថា ខ្ញុំគឺជាអ្នកមូលដ្ឋានចាស់។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងកងចល័តនារី គឺធ្វើស្រែ វែកដី និងលើកទំនប់។ នៅឆ្នាំ១៩៧៧ កងចល័តនារីរបស់ខ្ញុំត្រូវបានផ្លាស់ទីកន្លែងធ្វើការទៅការដ្ឋានផ្ទៃត្រ ដែលនៅទីកន្លែង

នោះខ្ញុំស្ទើរតែត្រូវបានចាប់យកទៅសម្លាប់ និងជាកន្លែងដែលខ្ញុំឃើញផ្ទាល់ភ្នែកពីទុក្ខវេទនារបស់គ្រួសារខ្ញុំ។ ខ្ញុំតែងតែលួចទៅជួបឪពុកម្តាយរបស់ខ្ញុំក្នុងស្ថានភាពស្លុតស្លាំង និងភិតភ័យ។ ខ្ញុំបានត្រឹមតែសួរសុខទុក្ខ និងមិនអាចធ្វើអ្វីបានលើសពីនេះទេ។ ចំណែកឯកងចល័តនារីរបស់ខ្ញុំវិញត្រូវទៅជីកដីវែកដី និងធ្វើស្រែគ្មានពេលសម្រាក និងគ្មានអាហារហូបគ្រប់គ្រាន់។ កងចល័តនារីកន្លែងខ្ញុំធ្វើការ មានសមាជិកមិត្តនារីទាំងអស់៩៧ នាក់។

នៅឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីបានចូលមកដល់ និងចាប់ផ្តើមចាប់កម្មាភិបាលមូលដ្ឋាននិងប្រធានកងយកទៅសម្លាប់ចោល។ កម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីក៏ចាប់ផ្តើមស្រាវជ្រាវប្រវត្តិរូបប្រជាជន១៧ មេសា។ នៅពេលនោះ កងចល័តនារីនៅសេសសល់ប្រហែល៦០នាក់ប៉ុណ្ណោះ។

នៅយប់មួយ ប្រធានកងចល័តនារីឈ្មោះ ស្រ៉ាង បានដើរស្រង់ឈ្មោះអ្នកដែលមានប្រវត្តិជាប្រជាជន ១៧ មេសា។ ខ្ញុំដឹងថា ប្រជាជន១៧ មេសា នៅពេលនោះគឺត្រូវបានស្រង់ឈ្មោះបានចំនួន១៣នាក់ រួមទាំងឈ្មោះរបស់ខ្ញុំផងដែរ។ ប៉ុន្តែមិត្តនារី ស្រ៉ាង ដែលជាអតីតមិត្តរៀនថ្នាក់ទី១១ នៅសាលាបឋមសិក្សាចុងកោះជាមួយគ្នាស្គាល់ខ្ញុំ និងមិនបានហៅខ្ញុំដើម្បីរៀបចំបាយពោតដើម្បីយកទៅសម្លាប់ចោលនោះទេ។ ចំណែកឯ អ្នក១២នាក់ផ្សេងទៀតត្រូវបានមិត្តនារី ស្រ៉ាង ប្រាប់ឲ្យរៀបចំបាយពោត និងហៅទៅតាមគាត់។ នៅយប់ដដែល ប្រជាជន ១៧ មេសា បានងើបអង្គុយ និងពិភាក្សាគ្នាអំពីការរៀបចំបាយ និងការផ្លាស់ទៅកន្លែងផ្សេងទៀត។ នៅពេលនោះ មិត្ត ថាច ដែលរៀនបានខ្ពង់ខ្ពស់ និងចប់ថ្នាក់មហាវិទ្យាល័យ និយាយទៅកាន់អ្នកទាំងអស់គ្នាថា «កុំទៅបារម្ភពេក ខ្មែរក្រហមមិនដែលសាហាវជាងហ៊ីត្លែរនោះទេ»។ ការលើកឡើងរបស់មិត្ត ថាច នៅពេលនោះ គឺគាត់មិនជឿថា ខ្មែរក្រហមសម្លាប់ខ្មែរនោះទេ។ ប៉ុន្តែអ្វីដែលមិត្ត ថាច និយាយនោះគ្រាន់តែជាការយល់ខុស។ ខ្មែរក្រហមបានបណ្តើរអ្នកទាំង១២នាក់ដែលត្រូវបានស្រង់ឈ្មោះ និងប្រាប់ឲ្យរៀបចំបាយ ហើយយកទៅសម្លាប់ចោលយ៉ាងព្រៃផ្សៃក្បែរការដ្ឋានដែលខ្ញុំ និងអ្នកផ្សេងទៀតកំពុងធ្វើការ។

នៅឆ្នាំ១៩៧៨ ខ្ញុំទទួលបានដំណឹងថាឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់ និងទម្លាក់ចូលក្នុងទន្លេ ពីព្រោះតែជាប់ប្រវត្តិជាប្រជាជន ១៧ មេសា។ ខ្ញុំបានវិលត្រឡប់មកភូមិទី៨វិញ ដើម្បីរស់នៅជាមួយយាយរបស់ខ្ញុំ និងប្អូនម្នាក់ដែលរួចផុតពីការសម្លាប់នៅពេលនោះ។ នៅឆ្នាំ១៩៨០ ខ្ញុំបានបង្រៀនកូនអ្នកភូមិនៅសាលាបឋមសិក្សាទីប្រជុំ និងក្រោយមកទៀតទទួលតួនាទីជានាយកសាលា។ បន្ទាប់ពីខ្ញុំចូលចូលនិវត្តន៍ ខ្ញុំលក់នំ និងអាហារនៅក្នុងសាលា និងបន្តបង្រៀនកូនអ្នកភូមិក្នុងតួនាទីជាគ្រូកិច្ចសន្យា»។

## ម៉ាត់ គីទី



ម៉ាត់ គីរី ភេទស្រី គឺអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអ្នកនេសាទត្រីរស់នៅភូមិទី ១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម បានចែករំលែកអំពីប្រវត្តិរបស់ខ្លួនថា «ខ្ញុំឈ្មោះ ម៉ាត់ រី អាយុ ៦២ឆ្នាំ ប្រកបរបរធ្វើស្រែចម្ការ និងនេសាទត្រី។ ខ្ញុំរៀបការប្តីឈ្មោះ ស្មាន និងមានកូនសរុបចំនួន៤នាក់ គឺប្រុស២នាក់និងស្រី២នាក់។ ឪពុករបស់ខ្ញុំឈ្មោះ ម៉ាត់ និងម្តាយឈ្មោះ ឡិ។ ខ្ញុំគឺជាកូនទី៥ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៩ នាក់។ ខ្ញុំកើតនៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន នេះតែម្តង។ កាលពីក្មេង ខ្ញុំចូលរៀននៅសាលាបឋមសិក្សាចុងកោះបានត្រឹមថ្នាក់ទី១។

នៅឆ្នាំ១៩៧១ ខ្ញុំបានឈប់រៀន ដោយមាន

ការប្រយុទ្ធគ្នារវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ សង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើងៗ រហូតដល់ឆ្នាំ១៩៧៣។ នៅឆ្នាំ១៩៧៤ ឪពុកម្តាយរបស់ខ្ញុំបាននាំកូនៗរត់ភៀសខ្លួនទៅស្នាក់នៅម្តុំមហាលាភ និងបន្ទាប់មកបានវិលត្រឡប់មករស់នៅភូមិកំណើតវិញ។

នៅឆ្នាំ១៩៧៥ ឪពុកម្តាយខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅកងប្រវាស់ដៃ ដើម្បីជួយប្រូតស្រូវ និងប្រមូលផលដំណាំផ្សេងៗមកចែកគ្នាហូប។ នៅឆ្នាំ១៩៧៦ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង ដោយជិះស្រឡាង២ជាន់ ដែលពោរពេញទៅដោយប្រជាជនជម្លៀស។ គ្រួសារខ្ញុំបានទៅដល់ឃ្លាំងស្បែក និងត្រូវបានដាក់ឲ្យជិះឡានបន្តរហូតដល់ស្ថានីយរទេះភ្លើង។ គ្រួសាររបស់ខ្ញុំបានឡើងជិះរទេះភ្លើងរហូតមកដល់ខេត្តបាត់ដំបង។ នៅពេលនោះ ម្តាយខ្ញុំបានសួរខ្មែរក្រហមថា តើមកដល់កន្លែងហើយឬនៅ? ខ្មែរក្រហមបានប្រាប់ថា មិនទាន់ដល់កន្លែងទេ គឺត្រូវជិះរទេះគោទៅស្រះកែវបន្តទៀត។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅកងចល័តដែលមានទិសដៅដក និងរែកសំណាបឲ្យអ្នកស្ទូង។ ខ្ញុំអាណិតប្អូនរបស់ខ្ញុំខ្លាំងណាស់ ព្រោះប្អូនរបស់ខ្ញុំបានស្លាប់ដោយសារតែជំងឺ និងការអត់ឃ្លាន។ ខ្ញុំធ្វើការនៅការដ្ឋានបឹងពើតនៅខេត្តបាត់ដំបង។ បឹងនោះគឺធំណាស់ដែលមើលទៅវាលល្ហល្ហាច។ សមាជិកគ្រួសាររបស់ខ្ញុំជាច្រើននាក់បានស្លាប់បាត់បង់ជីវិតនៅពេលនោះ។ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់ និងនៅតែនឹករឭកសមាជិកគ្រួសារជាទីស្រឡាញ់ជានិច្ច»។

## ណៃ ស៊ីមអួន



ណៃ ស៊ីមអួន ភេទស្រី នៅរស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអ្នកនេសាទត្រី រៀបរាប់ថា «ខ្ញុំឈ្មោះ ណៃ ស៊ីមអួន អាយុ៥៥ឆ្នាំ រស់នៅក្នុងភូមិទី១២ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ ហៀង ផា។ ខ្ញុំមានកូនប្រុសស្រីចំនួនបីនាក់ ស្រីពីរនាក់និងប្រុសម្នាក់។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ។ ឪពុកខ្ញុំឈ្មោះ ណៃ ផន់ និងម្តាយឈ្មោះ ឌុច ឈុនឌី។ ខ្ញុំមានបងប្អូនចំនួន៦នាក់ ប្រុស២ និងស្រី៤ ហើយខ្ញុំគឺជាកូនទី៦។ នៅពីក្មេងខ្ញុំមិនបានរៀនសូត្រទេ ដោយសារប្រទេសកើតមានសង្គ្រាម។ នៅក្នុងរបបលន់ នល់ ម្តាយរបស់ខ្ញុំនាំកូនៗរត់ចូលរណ្តៅត្រង់សេ នៅពេលស្ងប់ទើបនាំកូនចៅចេញពីរណ្តៅវិញ។ នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងកងកុមារដើរកាត់ផ្ទី លើកអាចម៍គោនៅតាមផ្ទះរបស់អ្នកភូមិ។ ខ្ញុំត្រូវក្រោកពីម៉ោង៣ទៀបភ្លឺ ដោយមានគ្រូនៅជាមួយចាំដាស់ឲ្យក្រោកទៅសែងអាចម៍គោ។ ពេលនោះខ្ញុំ និងស្រីៗកាន់បង្គី ចំណែកប្រុសៗគឺជាអ្នកកើបអាចម៍គោដាក់បង្គីឲ្យខ្ញុំយកទៅចាក់គរទុក។ ខ្ញុំត្រូវរស់នៅបែកម្តាយ ព្រោះម្តាយត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅឆ្ងាយ។ ឪពុកខ្ញុំធ្វើការខាងសិប្បកម្មនៅក្នុងភូមិ បងរបស់ខ្ញុំធ្វើការនៅតាមកងចល័ត។

ថ្ងៃខ្លះខ្ញុំក្រោកនៅម៉ោង៤ទៀបភ្លឺទៅប្រជុំជួរនៅរោងបាយដែលមានសមាជិកចំនួន៥០ ទៅ៦០នាក់។ ប្រធានកងជ្រើសរើសសមាជិក្រុម១០នាក់ទៅបូកអាចម៍គោនៅក្នុងភូមិដាក់រទេះ ហើយខ្ញុំគឺជាអ្នករុញរទេះយកអាចម៍គោចាក់ក្នុងរណ្តៅ។ នៅម៉ោង៨ព្រឹក ខ្ញុំត្រូវចេញទៅកាប់ដើមទន្ទ្រានខែត្រក្នុងព្រៃយកមកចិញ្ច្រាំដាក់ក្នុងរណ្តៅអាចម៍គោរហូតដល់ម៉ោង១១ថ្ងៃត្រង់ទើបឈប់ហូបបបរ។ បន្ទាប់មក ប្រធានកងចាត់តាំងឲ្យខ្ញុំទៅលើកទំនប់នៅមុខសាលាឃុំកោះសូទិនជីកប្រឡាយ និងលើកភ្លឺស្រែ។ ខ្ញុំបានបន្តធ្វើការនៅការដ្ឋាននេះរហូតដល់ពេលដែលមានកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយចូលមកដល់រំដោះប្រជាជនចេញពី

ការកាប់សម្លាប់របស់ខ្មែរក្រហម។ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់ និងត្រឡប់មករស់នៅជាមួយក្រុមគ្រួសារវិញ»។

## គុង ស៊ីថាត



គុង ស៊ីថាត ភេទស្រី គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ សព្វថ្ងៃ ស៊ីថាត ធ្វើចម្ការ និងលក់នំខ្មែរ បានរៀបរាប់រឿងរ៉ាវរបស់ខ្លួនដែលបានឆ្លងកាត់របបខ្មែរក្រហមថា «ខ្ញុំឈ្មោះ គុង ស៊ីថាត អាយុ៦៨ឆ្នាំ រស់នៅភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ ខ្ញុំគឺជាអតីតពិធីការសិល្បៈសម្តែងខ្មែរក្រហម និងអតីតគ្រូបង្រៀនថ្នាក់ទី១នៅក្នុងរបបខ្មែរក្រហម។ ខ្ញុំមានឪពុកឈ្មោះ លេង វ៉ន និងម្តាយឈ្មោះ ប៉ាច សែអេង។ ខ្ញុំគឺជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីទាំងអស់ចំនួន៤នាក់។ ខ្ញុំបានរៀនសូត្រដល់ថ្នាក់ទី៧ ចាស់នៅសាលាបឋមសិក្សាកំពង់ក្របី។ បន្ទាប់ពីបានបញ្ចប់ថ្នាក់ទី៧ ខ្ញុំបានបន្តការសិក្សានៅអនុវិទ្យាល័យព្រះសីហនុ នៅទីរួមខេត្តកំពង់ចាមនៅដើមឆ្នាំ១៩៧០។ ខ្ញុំបានស្នាក់នៅជាមួយអ្នកគ្រូបង្រៀននៅក្នុងថ្នាក់ដែលមានផ្ទះនៅក្បែរមាត់ទន្លេ។ រយៈពេល៣ខែដំបូង ខ្ញុំបានឃើញការធ្វើបាតុកម្មដង្ហែតាមដងផ្លូវ និងក្រោយមកទៀតរដ្ឋប្រហារ លន់ នល់ បានកើតឡើង។ ខ្ញុំបានរៀននៅថ្នាក់អនុវិទ្យាល័យព្រះសីហនុ អស់រយៈពេល៦ខែ។ ដោយព្រួយបារម្ភពីសុវត្ថិភាពឪពុករបស់ខ្ញុំបានឡើងទៅយកខ្ញុំមកនៅភូមិវិញ។ ខ្ញុំនិងឪពុកបានដើរពេញមួយថ្ងៃ ចេញពីទីរួមខេត្តកំពង់ចាម រហូតមកដល់ភូមិចំការសាមសិប។

នៅឆ្នាំ១៩៧១ កងទ័ពរំដោះខ្មែរក្រហមប្រហែល ១០នាក់បានចូលមកដល់ភូមិរបស់ខ្ញុំដើម្បីប្រកាសប្រាប់អ្នកភូមិឲ្យចូលរួមជាមួយបដិវត្តន៍ និងការពារទឹកដី។ នៅពេលនោះ ទាហានលន់ នល់ ត្រូវបានបញ្ជូនមកដើម្បីវាយបណ្តេញកងទ័ពរំដោះខ្មែរក្រហមចេញពីភូមិ។ ទាហានលន់ នល់ បានដាក់កម្លាំងឈរជើងនៅបន្ទាយទាហានចំការគយ ស្ថិតនៅភូមិកំពង់ក្របី។ ចាប់ពីឆ្នាំ១៩៧២ដល់ឆ្នាំ១៩៧៣ ទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមបានប្រយុទ្ធគ្នាជាច្រើនសមរភូមិ។ នៅឆ្នាំ១៩៧២ ភូមិរបស់ខ្ញុំត្រូវបានកងទ័ពរំដោះខ្មែរក្រហមរំដោះ និងកាន់កាប់។ នៅពេលនោះ ខ្ញុំបានចូលបម្រើនៅក្នុងកងសិល្បៈឃុំដែលមានសមមិត្ត ហ៊ាន គឺជាប្រធាន។ នៅឆ្នាំ១៩៧៥ ខ្ញុំបានជួបជាមួយឪពុកមាឈ្មោះ ចេក ជឿន ដែលជាមេភូមិមាន់ហើរ។ សមមិត្ត ជឿន បានរៀបចំផ្ទះឈើរបស់អ្នកភូមិចំនួន៣ខ្នង ដើម្បីប្រើប្រាស់ជាថ្នាក់រៀន និងកន្លែងស្នាក់នៅ គឺ ផ្ទះទី១ សម្រាប់បង្រៀនថ្នាក់ទី១, ផ្ទះទី២ គឺសម្រាប់បង្រៀនថ្នាក់ទី២ និងផ្ទះទី៣ គឺសម្រាប់បង្រៀនថ្នាក់ទី៣។ ទីកន្លែងបង្រៀនគឺធ្វើឡើងនៅក្រោមផ្ទះ ចំណែកឯទីកន្លែងស្នាក់នៅគឺនៅលើផ្ទះ។ ខ្ញុំគឺត្រូវបង្រៀនថ្នាក់ទី១ ដែលមានកូនប្រជាជនមូលដ្ឋានចន្លោះពី៦ទៅ១០នាក់។ ខ្ញុំបានបង្រៀនអក្សរខ្មែរនៅពេលព្រឹក និងលេខនៅពេលរសៀល។ នៅពេលសម្រាកថ្ងៃត្រង់ ខ្ញុំនិងកូនសិស្សបានទៅរោងបាយសហករណ៍រួមដើម្បីហូបបាយ។ បន្ទាប់ពីបង្រៀនចប់ ខ្ញុំបានដឹកនាំកូនសិស្សថ្នាក់ទី១ទៅដាំដំណាំ និងដើរប្រមូលលាមកសត្វមកធ្វើជី។ ខ្ញុំបានបង្រៀនកូនសិស្សរាល់ថ្ងៃ។

នៅចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ កម្មាភិបាលខ្មែរក្រហមភូមិភាគនិរតីបានមកដល់ និងបានចាប់ផ្តើមចាប់ខ្លួនកម្មាភិបាលខ្មែរក្រហមមូលដ្ឋានដើម្បីយកទៅសម្លាប់ចោល។ ឪពុកមារបស់ខ្ញុំសមមិត្ត ជឿន ក៏ត្រូវបានកម្មាភិបាលខ្មែរក្រហមមកពីភូមិភាគនិរតីចាប់យកទៅសម្លាប់ចោលទាំងគ្រួសារដែរ។ នៅពេលនោះ ខ្ញុំពិតជាភ័យតក់ស្លុតខ្លាំងណាស់ទាក់ទងនឹងការចាប់យកទៅសម្លាប់ចោល។ បន្ទាប់ពីខ្ញុំត្រូវបានដោះលែងមកវិញ ខ្ញុំបានបង្រៀនកូនសិស្ស

ដូចធម្មតា ប៉ុន្តែសមមិត្តនារីឈ្មោះ សេរី យុទ្ធ ដែលជាមេភូមិមកពីភូមិភាគនិរតីបានមកពិនិត្យការបង្រៀនរបស់ខ្ញុំជារឿយ និងបាននិយាយគំរាមកំហែងខ្ញុំគ្រប់ពេលវេលា។ នៅចុងឆ្នាំ១៩៧៧ សមមិត្តនារី យុទ្ធ បានយកខ្ញុំធ្វើជាជំនួយការដើម្បីធ្វើបញ្ជី និងកត់ត្រាផ្សេងៗ។ ខ្ញុំបានធ្វើបញ្ជីឈ្មោះប្រជាជននៅក្នុងភូមិមាន់ហើរ ដោយបានប្រើប្រាស់គំរូបញ្ជីចាស់ ប៉ុន្តែខ្ញុំមិនបានដឹងថាតើបញ្ជីនោះយកទៅប្រើប្រាស់ដើម្បីអ្វីនោះទេ។ ខ្ញុំបានសរសេរលិខិតអំពីការអនុញ្ញាតផ្លាស់ប្តូរមូលដ្ឋានរស់នៅ។ នៅពេលនោះ ខ្ញុំបានសរសេរ និងបានអានឲ្យសមមិត្តនារី យុទ្ធ ដើម្បីរកចំណុចកែតម្រូវ។ បន្ទាប់មក ខ្ញុំបានសរសេរតាមអ្វីដែលសមមិត្តយុទ្ធបាននិយាយកែតម្រូវ។ នៅពេលដែលខ្ញុំបានសរសេរលិខិតចំនួន៨-១០ច្បាប់ សមមិត្តយុទ្ធបានបោះត្រាលើលិខិតទាំងនេះដើម្បីបង្ហាញអំពីការអនុញ្ញាតផ្លាស់ប្តូរមូលដ្ឋានរស់នៅ។ ខ្ញុំបានដឹងមុនថា មុននិងក្រោយកម្មាភិបាលភូមិភាគនិរតីនឹងយកខ្ញុំទៅសម្លាប់ចោល ដូច្នេះខ្ញុំបានលួចលិខិតមួយច្បាប់ និងបានរត់ចេញពីភូមិមាន់ហើរមកកាន់ភូមិចំការសាមសិបវិញ។ នៅពេលដែលខ្ញុំមកដល់ភូមិកំណើតវិញ ខ្ញុំបានបង្ហាញលិខិតមានត្រាឈ្មោះ សេរី យុទ្ធ ដល់មេភូមិនៅមូលដ្ឋានទើបមេភូមិអនុញ្ញាតឲ្យខ្ញុំរស់នៅ។ ខ្ញុំបានរួចផុតពីការកាប់សម្លាប់នៅក្នុងរបបខ្មែរក្រហម និងប្រកបរបរកសិកម្ម»។



ចន្លោះពីថ្ងៃទី១៤ ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាស្ត្រីចំនួន ១១នាក់មកពីសហគមន៍កោះសូទិន និងកំពង់ចាម ចូលរួមកិច្ចការងារស្រាវជ្រាវអំពីបម្រែបម្រួលអាកាសធាតុ និងការរស់នៅរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានជួបជាមួយក្រុមការងារស្រាវជ្រាវដឹកនាំដោយ ព្រះអង្គម្ចាស់ក្សត្រីនរោត្តម កែវប៉ូនីតា រស្មី ចែករំលែកបទពិសោធន៍ក្នុងរបបខ្មែរក្រហម ការប្រកបរបរចិញ្ចឹមជីវិត និងការយល់ឃើញអំពីផលប៉ះពាល់អំពីបម្រែបម្រួលអាកាសធាតុដល់ជីវភាពរបស់ខ្លួន។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )



# រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅស្រុកកំចាយមារ

*សាន ធីតា និង អឿន ពណ្ណរាយ*

អ្នកស្ម័គ្រចិត្តកម្ពុជា នៅខេត្តព្រៃវែង ចំនួនពីររូបគឺ សាន ធីតា និង អឿន ពណ្ណរាយ បានជួបនិងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចំនួន១៤នាក់ក្នុងចំណោមនោះមានប្រុសចំនួន២នាក់ និងស្រីចំនួន១២នាក់ រស់នៅស្រុកកំចាយមារ បានចែករំលែករឿងរ៉ាវដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម។ ខាងក្រោមនេះគឺជារឿងរ៉ាវសង្ខេប ៖

### ១) កែវ ជន់



ខ្ញុំឈ្មោះ កែវ ជន់ ភេទស្រី អាយុ៧០ឆ្នាំ គឺជាកសិករ បច្ចុប្បន្នរស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំមានកូនចំនួន៦នាក់។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំជួបការលំបាកយ៉ាងខ្លាំង។ ខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើការងារហួសកម្លាំង។ ខ្ញុំមិនដែលហូបបានឆ្អែតទេ គឺពេលព្រឹកខ្ញុំទទួលបានរបបបាយមួយកូនចាន និងពេលល្ងាចខ្ញុំហូបតែបបរ។ ខ្ញុំមានតួនាទីជាសមាជិកក្រុម ដូច្នេះខ្ញុំធ្វើតាមតែមេក្រុមបញ្ជាមក ប្រសិនបើខ្ញុំប្រកែកតវ៉ា នឹងត្រូវយកទៅកសាងមិនខាន ហើយអ្នកដែលយកទៅកសាងហើយគឺកម្រឃើញត្រឡប់មកវិញណាស់។ ការងារដែលខ្ញុំធ្វើមានដូចជា ស្ទូង ដក ច្រូតស្រូវ បោកកណ្តាប់ក្នុងម្នាក់ចំនួន២០០កណ្តាប់។ ខ្ញុំបោកកណ្តាប់ទាំងយប់ រហូតរួចរាល់ទើបអង្គការឲ្យមកផ្ទះវិញ។ សព្វថ្ងៃខ្ញុំរស់នៅម្នាក់ឯង ហើយខ្ញុំពេញចិត្តនឹងការរស់នៅរាល់ថ្ងៃ ព្រោះមានសេរីភាព។

### ២) កែវ យ៉ុន



ខ្ញុំឈ្មោះ កែវ យ៉ុន ភេទស្រី អាយុ៧២ឆ្នាំ គឺជាកសិករ បច្ចុប្បន្នរស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំមានកូនចំនួន២នាក់ក្នុងនោះមានម្នាក់ទៅធ្វើការនៅប្រទេសថៃ និងម្នាក់ទៀតធ្វើការនៅស្រុកកំចាយមារ។ នៅក្នុងរបបខ្មែរក្រហមខ្ញុំជួបការលំបាកយ៉ាងខ្លាំង ព្រោះអង្គការប្រើខ្ញុំឲ្យធ្វើពលកម្មធ្ងន់ធ្ងរដូចសត្វធាតុ។ ការហូបចុករបស់ខ្ញុំ មិនឆ្អែតទេ គឺពេលព្រឹកហូបបាយ១កូនចាន និងពេលល្ងាចហូបបបរ។ ពេលអង្គការចាត់តាំងខ្ញុំឲ្យធ្វើការងារអ្វី គឺខ្ញុំត្រូវតែធ្វើតាមបញ្ជារបស់អង្គការ ប្រសិនបើខ្ញុំប្រកែកអង្គការនឹងយកខ្ញុំទៅកសាងមិនខាន។ ការងារដែលខ្ញុំធ្វើគឺស្ទូងស្រូវ ជីកប្រឡាយប្រវែង១៥ម៉ែត្រ រហូតរួចរាល់ទើបត្រឡប់មកផ្ទះវិញ។ សព្វថ្ងៃខ្ញុំរស់នៅជាមួយកូន។

## ៣) អុត សារុំ



ខ្ញុំឈ្មោះ អុត សារុំ អាយុ៥៩ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ សម័យខ្មែរក្រហម ខ្ញុំមានអាយុប្រមាណ១១ឆ្នាំ និងមានបងប្អូនចំនួន៧ នាក់។ ក្រោយឆ្នាំ១៩៧៥ ឪពុកខ្ញុំត្រូវបានចោទប្រកាន់ជាខ្មែរស និងត្រូវបានចាប់ខ្លួនហើយមិនឃើញវិលត្រឡប់មកផ្ទះទេ។ នៅសម័យនោះ ទោះបីខ្ញុំនៅវ័យក្មេង ប៉ុន្តែអង្គការប្រើខ្ញុំឲ្យធ្វើការដូចមនុស្សធំៗ។ ចំណែកការហូបចុកគឺមិនគ្រប់គ្រាន់ទេ ព្រោះមួយថ្ងៃអង្គការឲ្យហូបតែពីរពេល គឺនៅវេលាម៉ោង១១ព្រឹក ហូបបាយ និងពេលល្ងាចហូបបបរ។ ការងារដែលខ្ញុំធ្វើមានដូចជា ស្ទូងស្រូវ កាប់ឆ្ការព្រៃ និងជីកប្រឡាយ។ ខ្ញុំសូមផ្តាំឲ្យក្មេងជំនាន់ក្រោយ ត្រូវខិតខំរៀនសូត្រ ការពារកុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។ សព្វថ្ងៃខ្ញុំពេញចិត្តការរស់នៅប្រចាំថ្ងៃរបស់ខ្ញុំព្រោះប្រទេសជាតិមានការអភិវឌ្ឍន៍ និងមានសេរីភាព។

## ៤) សាយ សី



ខ្ញុំឈ្មោះ សាយ សី ភេទប្រុស អាយុ៦៨ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ខ្ញុំមានអាយុប្រមាណ៨ឆ្នាំ។ ខ្ញុំរៀននៅសាលាបឋមនៅឡើយ។ លុះឆ្នាំ១៩៧០ ខ្ញុំឃើញប្រជាជនធ្វើបាតុកម្មប្រឆាំងរបបលន់ នល់។ ខ្ញុំមិនបានរៀនបន្តទេដោយសារតែសម័យនោះកើតមានសង្គ្រាម។ យើងរត់គេចពីការទម្លាក់គ្រាប់បែក ហើយការទម្លាក់គ្រាប់នោះបណ្តាលឲ្យដាច់ស្ពានដៅរីស្ថិតនៅក្បែរផ្ទះរបស់ខ្ញុំ។ នៅពេលរបបខ្មែរក្រហមឡើងគ្រប់គ្រងអំណាច ខ្ញុំមានអាយុប្រមាណជាង១០ឆ្នាំ។ ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យចូលក្នុងកងកុមារឈានមុខ ដោយអង្គការឲ្យខ្ញុំធ្វើការងារជាក្រុមៗ បន្ទាប់មក អង្គការប្រើខ្ញុំឲ្យជញ្ជូនខ្សាច់និងគ្រួស យកមកធ្វើស្ថានីយស្តុកទឹក។ ខ្ញុំត្រូវបានអង្គការដេញចាប់ម្តង ក្រោយមកអង្គការស្រាវជ្រាវអំពីប្រវត្តិរូបរបស់ខ្ញុំដឹងថា ខ្ញុំគឺជាអ្នកដឹកជញ្ជូនគ្រួស និងខ្សាច់យកមកធ្វើស្ថានីយ៍ក៏ដោះលែងវិញ។ មួយរយៈក្រោយមក យោធាខ្មែរក្រហមតាមចាប់ខ្ញុំ និងក្រុមរបស់ខ្ញុំនៅម្តុំចុងអង្គ្រង និងថ្នល់ទទឹង ស្ថិតនៅខាងកើតស្វងម្តងទៀត។ យោធាខ្មែរក្រហមដេញបាញ់ខ្ញុំ ខណៈនោះខ្ញុំក៏រត់ចូលព្រៃនៅចុងឆ្នាំ១៩៧៨។ ខ្ញុំនិងក្រុមបានរត់ភៀសខ្លួនទៅប្រទេសវៀតណាម ប៉ុន្តែមិនបានសម្រេចដោយសារយោធាខ្មែរក្រហមបានរារាំងផ្លូវ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមបានដួលរលំ ទើបខ្ញុំវិលត្រឡប់មកផ្ទះវិញ ព្រោះនឹករឭកបងប្អូននិងឪពុកម្តាយ។

## ៥) សាម សារុំ



ខ្ញុំឈ្មោះ សាម សារុំ ភេទស្រី អាយុ៧៨ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំមានកូនចំនួន៤នាក់ ក្នុងនោះម្នាក់ធ្វើការនៅប៉ោយប៉ែត និងម្នាក់ទៀតធ្វើការនៅរាជធានីភ្នំពេញ ចំណែកពីរនាក់ទៀតធ្វើការនៅប្រទេសចិន និងថៃ។ នៅរបបខ្មែរក្រហម ខ្ញុំជួបការលំបាកយ៉ាងខ្លាំងដោយសារខ្មែរក្រហម

ប្រើខ្ញុំឲ្យធ្វើការហួសកម្លាំង និងធ្វើការដូចសត្វធាតុនៅកងចល័ត។ ខ្ញុំមិនដែលបានហូបឆ្អែតទេ អាហារពេលព្រឹកគឺហូបបាយនៅម៉ោង១១ ហើយពេលល្ងាចគឺហូបបបរ។ នៅក្នុងសម័យនោះ ប្រសិនបើនរណាម្នាក់ប្រកែកតវ៉ាជាមួយបទបញ្ជារបស់ខ្មែរក្រហម អ្នកនោះនឹងត្រូវបានខ្មែរក្រហមយកទៅកសាង ហើយកម្រឃើញវិលត្រឡប់មកវិញណាស់។ ចំណែកការងារដែលខ្ញុំធ្វើមានដូចជា ស្ទូងស្រូវ កិនស្រូវ ច្រូតស្រូវ និងបោកកណ្តាប់ ដោយបោកក្នុងម្នាក់ឲ្យបានចំនួន៣០០កណ្តាប់ ទើបអាចត្រឡប់មកផ្ទះវិញ។ នៅសម័យនោះខ្ញុំបែកបាក់បងប្អូនចំនួន២នាក់ ដោយបងរបស់ខ្ញុំម្នាក់គឺជាទាហាន។ ខ្ញុំសំណូមពរឲ្យក្មេងជំនាន់ក្រោយការពារកុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។

## ៦) ហាំ គុន



ខ្ញុំឈ្មោះ ហាំ គុន ភេទស្រី អាយុ៧១ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំធ្វើការងារនៅកងចល័តនៅក្នុងរបបខ្មែរក្រហម។ បន្ទាប់មក ខ្មែរក្រហមចាត់តាំងខ្ញុំ និងសមាជិកក្រុមទាំងអស់ឲ្យទៅកាប់ឆ្ការនិងរានព្រៃដាំស្រូវ និងដំណាំ។ ប្តីរបស់ខ្ញុំត្រូវអង្គការយកទៅកសាងនៅក្នុងរបបខ្មែរក្រហម។ នៅសម័យនោះ ការហូបចុកប្រចាំថ្ងៃរបស់ខ្ញុំដែលបានគ្រប់គ្រាន់ទេខុសពីពេលបច្ចុប្បន្នដែលខ្ញុំរស់នៅដោយសុភមង្គល ហូបចុកគ្រប់គ្រាន់ ហើយពេលឈឺមានថ្នាំសង្កូវព្យាបាល។

## ៧) សោម ធឿន

ខ្ញុំឈ្មោះ សោម ធឿន ភេទប្រុស អាយុ៥៥ឆ្នាំ គឺជាកសិករ បច្ចុប្បន្នខ្ញុំរស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ នៅសម័យខ្មែរក្រហមខ្ញុំនៅកងកុមារ និងជួបការលំបាកយ៉ាងខ្លាំង។ ការហូបចុកក្នុងមួយថ្ងៃពីរពេលគឺនៅពេលព្រឹកហូបបាយនៅម៉ោង១១ និងពេលល្ងាចហូបបបរជាមួយសម្លម្ជូរ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំចូលបម្រើកងទ័ពនៅឆ្នាំ១៩៨៦ក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយត្រូវបញ្ជូនឲ្យទៅហ្វឹកហាត់នៅប្រទេសវៀតណាមមួយរយៈ។ នៅពេលត្រឡប់មកវិញ ខ្ញុំត្រូវបានចាត់តាំងឲ្យចូលកងអា-៣ ឡើងទៅវាយតទល់ជាមួយខ្មែរក្រហម។ សព្វថ្ងៃប្រទេសយើងរីកចម្រើនមិនមានសង្គ្រាម ហើយប្រជាជនរស់នៅជួបជុំបងប្អូន។ ខ្ញុំសូមឲ្យក្មេងជំនាន់ក្រោយខិតខំរៀនសូត្រ ដើម្បីការពារកុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញ។

## ៨) គង់ សាន



ខ្ញុំឈ្មោះ គង់ សាន ភេទស្រី អាយុ៧៤ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ នៅក្នុងរបបសង្គមរាស្ត្រនិយម ខ្ញុំជួបគ្រោះថ្នាក់ចរាចរណ៍បណ្តាលឲ្យខ្ញុំមិនសូវចងចាំ។ នៅក្នុងរបប លន់ នល់ ខ្ញុំក៏មិនចងចាំច្រើនដែរ។ មកដល់របបខ្មែរក្រហម ខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើការងារគ្មានពេលសម្រាកឡើយ ចំណែកការហូបចុករបស់ខ្ញុំគឺមិនដែលបានហូបឆ្អែតទេ ព្រោះក្នុងមួយថ្ងៃហូបតែពីរពេលគឺព្រឹកម៉ោង១១ហូបបាយ និងពេលល្ងាចហូបបបរ។ ក្រោយមក ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យបើកឡានដឹកស្បៀង។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានផ្លាស់ខ្ញុំមកនៅកងស្ទូង និងដកសំណាបវិញ។ រាល់ថ្ងៃប្រធានកងដាស់ខ្ញុំឲ្យក្រោកនៅវេលាម៉ោង៣ទៀបភ្លឺដើម្បី

ទៅស្ទូង ហើយម៉ោង១១ព្រឹកទើបឈប់សម្រាកហូបបាយ។ ក្នុងមួយថ្ងៃខ្ញុំនិងសមាជិកកង៥នាក់ទៀតត្រូវស្ទូងឲ្យហើយក្នុងទំហំដីមួយហិកតា។ ប្រសិនបើមិនហើយ ប្រយ័ត្នយ៉ាវ ខ្មែរក្រហមនឹងយកកងរបស់ខ្ញុំទៅកសាងមិនខាន ឡើយ។ ផុតពីរដូវស្ទូងដក ខ្មែរក្រហមចាត់តាំងខ្ញុំទៅលើកភ្លឺប្រឡាយ ហើយខ្ញុំក៏ត្រូវក្រោកនៅវេលាម៉ោង៣ទៀបភ្លឺដែរ។ នៅពេលកំពុងធ្វើការងារ ហើយយើងធ្វើឲ្យរបូតចបបន្តិ ដងរែកពីដៃ ខ្មែរក្រហមនឹងស្តីបន្ទោស ហើយចោទយើងថា មិនពេញចិត្តនឹងការងារ។ ខ្ញុំធ្វើការនៅកងចល័តរហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ សព្វថ្ងៃខ្ញុំមានកូនចំនួន៨នាក់ ហើយខ្ញុំសប្បាយចិត្ត ព្រោះស្រុកទេសមិនមានសង្គ្រាម និងមានសិទ្ធិសេរីភាព។

## ៩) ជា ថា



ខ្ញុំឈ្មោះ ជា ថា ភេទស្រី អាយុ៦០ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំជួបការលំបាកយ៉ាងខ្លាំង ព្រោះខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើពលកម្មលើសកម្លាំង។ ការហូបចុករបស់ខ្ញុំមិនបានគ្រប់គ្រាន់ទេគឺក្នុងមួយថ្ងៃ ខ្មែរក្រហមឲ្យខ្ញុំហូបពីរពេលប៉ុណ្ណោះ គឺពេលព្រឹកនៅម៉ោង១១ និងពេលល្ងាចនៅម៉ោង៥ ដោយមានតែបបរលាយជាមួយសម្លម្ជូរដើមចេក។ ប្រសិនបើមានអ្នកប្រកែក មិនធ្វើតាមការចាត់តាំងរបស់ខ្មែរក្រហម ខ្មែរក្រហមនឹងយកទៅកសាងមិនខាន។ ចំពោះអ្នកមកធ្វើការងារយឺតក៏ត្រូវបានខ្មែរក្រហមយកទៅកសាងលើកទី១ និងលើកទី២ ដោយលើកលែងទោសឲ្យ ប៉ុន្តែបើមានលើកទី៣គឺត្រូវមានទោស និងយកទៅវាយសម្លាប់ចោលមិនខាន។ ការងារដែលខ្ញុំធ្វើនៅសម័យនោះ មានដូចជា ស្ទូងស្រូវ ដកសំណាប ជីកប្រឡាយ និងលើកទំនប់។ ប្រធានកងប្រើខ្ញុំឲ្យស្ទូងស្រូវ១ហិកតាឲ្យហើយក្នុងមួយថ្ងៃ ចំណែកការងារជីកប្រឡាយគឺខ្ញុំត្រូវប្រើកម្លាំងខ្លាំងហើយប្រសិនបើខ្ញុំធ្វើឲ្យធ្លាក់របស់របរប្រើប្រាស់ត្រូវអង្គការស្តីបន្ទោស ឬចោទថាខ្ញុំមិនពេញចិត្តនឹងការងារ។ ខ្ញុំធ្វើការងារតាមការកំណត់របស់ប្រធានកងឲ្យរួចរាល់ ទើបខ្ញុំអាចត្រឡប់មកផ្ទះវិញ។ ខ្ញុំសំណូមពរឲ្យក្មេងជំនាន់ក្រោយខិតខំរៀនសូត្រ ដើម្បីកុំឲ្យជួបការលំបាកដូចខ្ញុំ។ សព្វថ្ងៃខ្ញុំរស់នៅជាមួយគ្រួសារ និងកូនទាំង២នាក់។

## ១០) ជីន យ៉ា



ខ្ញុំឈ្មោះ ជីនយ៉ា ភេទស្រី អាយុ៦៦ឆ្នាំ គឺជាកសិករ បច្ចុប្បន្នខ្ញុំរស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៥នាក់។ នៅក្នុងរបបសង្គមរាស្ត្រនិយម ខ្ញុំនៅក្មេង និងមិនសូវចាំទេ។ ចូលដល់របប លន់ នល់ ខ្ញុំមានអាយុ១៣ឆ្នាំ ខ្ញុំចងចាំបានបន្តិចបន្តួចប៉ុណ្ណោះ។ រហូតដល់របបរបបខ្មែរក្រហមខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំមានវ័យជំទង់។ ថ្ងៃមួយខ្មែរក្រហមចាប់ឪពុកខ្ញុំយកទៅសម្លាប់ចោលដោយចោទគាត់ថា ខ្មែរស។ ពេលនោះខ្ញុំជួបការលំបាកខ្លាំង ព្រោះការហូបចុកមិនដែលបានឆ្អែតទេ។ ក្នុងមួយថ្ងៃអង្គការឲ្យខ្ញុំហូបពីរពេលគឺពេលព្រឹកនៅម៉ោង១១ និង ពេលល្ងាចនៅម៉ោង៥ ដោយ ហូបបបរសជាមួយសម្លត្រកួននិងសម្លម្ជូរ។ ការងាររបស់ខ្ញុំនៅក្នុងសម័យនោះ រួមមាន ដក ស្ទូង ច្រូតស្រូវ និងបោកបែនស្រូវ។ ពេលនោះ ខ្ញុំត្រូវស្ទូងស្រូវ១ហិកតាជាមួយសមាជិក៨នាក់ ធ្វើយ៉ាងណាឲ្យរួចរាល់ក្នុងមួយព្រឹក។ ប្រសិនបើសមាជិក

៨នាក់ធ្វើមិនហើយ ត្រូវដកសមាជិក២នាក់ចេញ គឺទុកតែគ្នា៦នាក់ ហើយបើនៅតែមិនហើយគឺអង្គការយកទៅកសាងមិនខាន។ នៅរដូវប្រាំង ប្រធានកងបញ្ជូនខ្ញុំឲ្យទៅលើកទំនប់ និងជីកប្រឡាយ។ នៅពេលជីកប្រឡាយ ខ្ញុំទទួលបានរបបអាហារបាយមួយដុំ។

## ១១) ឈៀង ញ៉



ខ្ញុំឈ្មោះ ឈៀង ញ៉ ភេទស្រី អាយុ៦០ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ សព្វថ្ងៃខ្ញុំរស់នៅជាមួយប្អូនរបស់ខ្ញុំ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំមានអាយុប្រហែល៨ឆ្នាំ។ នៅពេលព្រឹកខ្ញុំត្រូវកើបអាចម៍គោ ក្របីរួចហើយទៅរៀន លុះប្រហែលម៉ោង៨ មេក្រុមឲ្យទៅឃ្វាលគោ និងក្របី។ បន្ទាប់ពីឃ្វាលគោ និងក្របី ប្រធានកងប្រើខ្ញុំឲ្យរែកទឹកដាក់ពាងដើម្បីឲ្យកុមារនៅក្នុងកងប្រើប្រាស់។ ការរែកទឹកគឺគ្មានការកំណត់ទេ គឺរែកជាមួយក្រុមកុមារ។ អ្វីដែលខ្ញុំគិតថាលំបាកជាងគេគឺការហូបចុក ដោយសារខ្ញុំនៅក្មេងហើយត្រូវការហូបច្រើន។ រាល់ថ្ងៃខ្ញុំទទួលរបបអាហារពីរពេល។ នៅពេលព្រឹក ខាងចុងភៅនៅផ្ទះបាយរួមបានរែកបបរមកចែកឲ្យកុមារហូបនៅវេលាប្រហែលម៉ោង១១ បន្ទាប់ពីហូបរួច កុមារត្រូវចេញទៅឃ្វាលគោក្របីនៅវាលស្រែ។ ពេលនោះខ្ញុំត្រូវបែកពីឪពុកម្តាយ និងបងប្អូនព្រោះត្រូវទៅធ្វើការផ្សេងៗតាមតួនាទីរៀងៗខ្លួន។ ខ្ញុំធ្លាប់យំដោយសារការនឹករឭកឪពុកម្តាយ បងប្អូន ហើយខ្ញុំតែងតែរង់ចាំមើលផ្លូវឪពុកម្តាយរបស់ខ្ញុំ។ ខ្ញុំមិនដែលបានឃើញឪពុករបស់ខ្ញុំ ព្រោះឪពុកខ្ញុំត្រូវបានខ្មែរក្រហមប្រើឲ្យទៅកាប់គាស់រានព្រៃនៅតំបន់ឆ្ងាយៗ។ ចំណែកម្តាយ ខ្ញុំបានជួបគាត់ញឹកញាប់ដោយសារខ្មែរក្រហមប្រើម្តាយខ្ញុំឲ្យមកយករបស់របរពីក្នុងភូមិ។ ចំណែកប្អូនខ្ញុំនៅពេលនោះនៅតូចៗ ដូច្នេះខ្មែរប្រមូលទៅដាក់នៅកងកុមារដែលមានចាស់ៗនៅថែទាំ ដូច្នេះខ្ញុំមិនដែលបានជួបប្អូនទេ។ ជួនកាលម្តាយរបស់ខ្ញុំបានយកប្អូនរបស់ខ្ញុំទៅតាមនៅពេលគាត់ចេញទៅស្ទូង។ ក្រោយមកប្រធានកងប្រើខ្ញុំឲ្យទៅរែកដី និងលើកទំនប់រយៈពេលពីរខែ។ ការរែកដីគឺលំបាកណាស់សម្រាប់ខ្ញុំដោយសារខ្ញុំនៅក្មេង ប៉ុន្តែក្រោយមក ប្រធានកងចាត់តាំងខ្ញុំមករៀនវិញ។ នៅពេលយប់ប្រធានកងប្រើខ្ញុំឲ្យជាន់អង្ករ ដើម្បីផ្តល់ឲ្យសហករណ៍យកទៅដាំបាយហូប។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានមករស់នៅជួបជុំឪពុកម្តាយនិងប្អូនវិញ។ ខ្ញុំរស់នៅជុំគ្នាមិនបានប៉ុន្មានផង ឪពុករបស់ខ្ញុំក៏ស្លាប់។

## ១២) ញូង យួង



ខ្ញុំឈ្មោះ ញូង យួង ភេទស្រី អាយុ៧៣ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ នៅក្នុងរបបលន់ នល់ ខ្ញុំរស់នៅជុំគ្នា លុះក្រោយមកក៏មានការទម្លាក់គ្រាប់បែកពេលខ្ញុំកំពុងស្ទូងស្រូវនៅវាលស្រែ។ នៅពេលរបបខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំហូបពុំដែលឆ្អែតទេ គឺហូបតែបបរប៉ុណ្ណោះ។ សម័យនោះខ្មែរក្រហមបានរៀបការឲ្យខ្ញុំ គឺមិនបានចេញពីការស្រឡាញ់ពេញចិត្តរបស់ខ្ញុំឡើយ។ ប្តីរបស់ខ្ញុំគឺជាគ្រូបង្រៀន ហើយខ្ញុំមានកូនស្រីម្នាក់។ កូនរបស់ខ្ញុំនៅតូច ហេតុនេះប្រធានកងឲ្យខ្ញុំនៅផ្ទះបុកអង្ករ ស្ទូង ដក ច្រូតស្រូវ និងធ្វើជី។ លុះពេលយប់ប្រធានកងប្រើខ្ញុំឲ្យរែកកណ្តាប់ ប៉ុន្តែខ្ញុំមិនបានចេញទៅជីកប្រឡាយដូចសមាជិកកងចល័តដទៃទេ។ រឿងរ៉ាវដែលខ្ញុំចងចាំ

មិនភ្លេចគឺហូបមិនឆ្អែត និងធ្វើការគ្មានពេលសម្រាក។

## ១៣) សូ សុភាព



ខ្ញុំឈ្មោះ សូ សុភាព ភេទស្រី អាយុ៦៦ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំបានរៀនដល់ថ្នាក់ទី៧ ពីសង្គមចាស់។ ខ្ញុំចាំថា ក្នុងរបបសាធារណរដ្ឋខ្មែរ ឬរបប លន់ នល់ មានការទម្លាក់គ្រាប់បែកនៅម្តុំភូមិអូរចិញ្ចៀន ពេលខ្ញុំកំពុងស្ទូងនៅវាលស្រែ។ ពេលនោះខ្ញុំនិងគ្រួសារ ព្រមទាំងកសិករដទៃទៀតបានរត់ចូលពួនក្នុងដីបូកមួយក្បែរនោះ។ សំណាងល្អរបស់ខ្ញុំនិងកសិករដទៃទៀតដែលមិនត្រូវអំបែងគ្រាប់។ រាល់ពេលដែលយើងឃើញយន្តហោះ ហោះកាត់ គឺយើងនាំគ្នារកកន្លែងពួនព្រោះខ្លាចយន្តហោះទម្លាក់គ្រាប់ត្រូវ ហើយពេលខ្លះខ្ញុំពួនចំកន្លែងដែលមានសត្វពស់មានពិសទៀតផង។ នៅពេលខ្មែរក្រហមឡើងកាន់អំណាច ខ្ញុំមានអាយុ១៨ឆ្នាំ។ ខ្ញុំមានតួនាទីជាអ្នកដើរបេះបន្លែ។ ខ្ញុំធ្លាប់លួចស្តាប់ខ្មែរក្រហមជជែកគ្នា ទាក់ទងនឹងការវាយប្រហារ ឬសម្លាប់មនុស្សចាស់ ដោយបានប្រើពាក្យថាគឺបណ្តាលមកពីក្រុម «ចលនាខ្មែរស» ប៉ុន្តែខ្ញុំមិនដឹងពីអត្ថន័យពាក្យនេះទេ។ ដំបូងខ្ញុំទទួលបានរបបអាហារ២ពេល ក្រោយមកខ្ញុំទទួលបានរបប៣ពេល គឺពេលព្រឹកទទួលបានបាយដំណើបម្នាក់១ដុំ ចំណែកពេលថ្ងៃនិងល្ងាចបាយជាមួយសម្លទំពាំងឬព្រលិត។ កាលនោះបងប្អូនរបស់ខ្ញុំនៅតូចៗនៅកងកុមារ គឺមានតែខ្ញុំដែលពេញកម្លាំងធ្វើការនៅកងចល័ត។ ខ្ញុំចាំថាពេលនោះឪពុករបស់ខ្ញុំឈឺ ហើយខ្មែរក្រហមលើកគាត់ដាក់លើរទេះសេះដឹកយកទៅព្យាបាល ព្រោះគាត់មានជំងឺស្ពឹក។

## ១៤) អ៊ី យ៉ាត



ខ្ញុំឈ្មោះ អ៊ី យ៉ាត ភេទស្រី អាយុ៧០ឆ្នាំ គឺជាកសិករ រស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្ត ព្រៃវែង។ នៅក្នុងរបប លន់ នល់ ខ្ញុំមានអាយុ១៧ឆ្នាំ ពេលនោះប្រទេសជាតិចាប់ផ្តើមមានសង្គ្រាម។ នៅខែមេសា ឆ្នាំ១៩៧៥ ស្រាប់តែកងទ័ពខ្មែរក្រហមចូលមកដល់ភូមិ។ សម័យនោះ ខ្ញុំធ្វើការនៅកងចល័ត។ ខ្មែរក្រហមចែករបបអាហារឲ្យខ្ញុំដោយពេលព្រឹកឲ្យបាយដំណើប១ដុំ លុះពេលល្ងាចហូបបបរ។ ខ្ញុំឃ្លានយ៉ាងខ្លាំង ប៉ុន្តែមិនហ៊ានតវ៉ាឡើយ ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល។ ខ្ញុំរស់នៅ និងធ្វើការផ្សារទាំងបន្ទំ។ សព្វថ្ងៃប្រជាជនរស់នៅបានប្រសើរ និងអាចប្រកបរបររកស៊ីដោយខ្លួនឯងបាន។ បច្ចុប្បន្ន ខ្ញុំរស់នៅជាមួយចៅចំនួន២នាក់។ ខ្ញុំសូមផ្តាំទៅក្មេងជំនាន់ក្រោយឲ្យខិតខំប្រឹងប្រែងសិក្សារៀនសូត្រដើម្បីខ្លួនឯង ក្រុមគ្រួសារ និងសង្គមជាតិ និងសូមកុំប្រើប្រាស់គ្រឿងញៀន ដែលសង្គមស្អប់ខ្ពើម។



ទិត្យ ច្រឹប ភេទស្រី អាយុ៥៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បច្ចុប្បន្នរស់នៅភូមិថ្នល់កែង ឃុំស្មោងខាងជើង ស្រុកកំចាយមារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទីតាំងប្រវត្តិសាស្ត្រយោធាថ្មីនឹងត្រូវបានសាងសង់ជាមួយនឹងការពង្រីកការសិក្សាបន្ថែមអំពីប្រវត្តិសាស្ត្រសម័យ លន់ នល់

សោម ប៊ុនថន



រាប់ពីស្តាំមកឆ្វេង៖ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងឧត្តមសេនីយ៍ឯក ណឹម សុម៉ាវត្តី ចូលរួមខួបអនុស្សាវរីយ៍លើកទី៤៦ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យ ពូជសាសន៍ ប៉ុល ពត "២០ មិថុនា ១៩៧៧-២០ មិថុនា ២០២៣" ក្រោមអធិបតីភាពសម្តេចតេជោ ហ៊ុន សែន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅសុន្ទរកថាស្វាគមន៍ សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងជាប្រធានគណៈកម្មការសាងសង់វិមានឈ្នះ ឈ្នះ ថ្លែងក្នុងពិធីខួបអនុស្សាវរីយ៍ លើកទី៤៦ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត "២០ មិថុនា ១៩៧៧-២០ មិថុនា ២០២៣" ដែលសម្តេចតេជោ ហ៊ុន សែន ចាប់ផ្តើមធ្វើដំណើរទៅ ប្រទេសវៀតណាម ដំណើរការឈានទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត រួមជាមួយនឹងកងកម្លាំងស្ម័គ្រចិត្តវៀតណាម ដើម្បីសង្គ្រោះប្រជាជនកម្ពុជាចេញពីវិនាសកម្ម និងមហន្ត-រាយនៃរបបខ្មែរក្រហម។ សម្តេចពិជ័យសេនា ទៀ បាញ់ បានលើកឡើងថា ប្រវត្តិនៃដំណើរជីវិតរបស់សម្តេចតេជោ ហ៊ុនសែននិងការបង្កើតកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ព្រមទាំងការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាមិនត្រឹមតែជាការចាប់ផ្តើមនៃប្រវត្តិសាស្ត្រសង្គ្រោះប្រទេស ចេញពីរបបប្រល័យពូជសាសន៍ប៉ុណ្ណោះទេ វាគឺជាការចាប់ផ្តើមនៃប្រវត្តិ-សាស្ត្រកងយោធពលខេមរភូមិន្ទ និងប្រទេសកម្ពុជាដ៏ទំនើបនេះផងដែរ។

ចាប់តាំងពីឆ្នាំ២០១៣មកក្រសួងការពារជាតិបាន

និងកំពុងស្រាវជ្រាវប្រវត្តិសាស្ត្រនេះ មិនត្រឹម តែក្នុងបរិបទនៃការរក្សាអតីតកាលប៉ុណ្ណោះទេ ប៉ុន្តែថែម ទាំងឈ្វេងយល់ពីប្រវត្តិសាស្ត្រការពារជាតិរបស់កម្ពុជាទៅអនាគតផងដែរ ព្រោះថាការយល់ដឹង ការរៀបចំផែនការ និងធានាកិច្ចការពារជាតិនៃប្រជាជាតិទំនើបទាំងអស់ ទាមទារឲ្យមានការសិក្សាអំពីអតីតកាល។

នៅក្នុងឱកាសនោះ សម្តេចពិជ័យសេនា ទៀ បាញ់ បានស្នើសុំពីសម្តេច តេជោ ហ៊ុន សែន ដូចខាងក្រោម៖

១. ស្នើសុំសម្តេចតេជោ ផ្តល់នូវការបញ្ជាក់អះអាងអំពីព្រឹត្តិការណ៍សំខាន់ៗ ក្នុងដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យ ពូជសាសន៍ ប៉ុល ពត "២០ មិថុនា ១៩៧៧" ដើម្បីសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាចេញពីវិនាសកម្ម និងមហន្តរាយនៃរបបខ្មែរក្រហម និងនយោបាយ ឈ្នះ ឈ្នះ

២. ស្នើសុំការអនុម័តការចេញអនុក្រឹត្យស្តីពីការរៀបចំតំបន់ប្រវត្តិសាស្ត្រយោធា

៣. ស្នើសុំបង្កើតច្បាប់ស្តីពីប្រវត្តិសាស្ត្រយោធា ដើម្បីការពារ អភិរក្ស អភិវឌ្ឍន៍តឹកតាងប្រវត្តិសាស្ត្រនានា

៤. ស្នើសុំអនុសាសន៍ចំពោះការកសាងស្តូបតេជោសន្តិភាព នៅតាមបណ្តាខេត្តនានា។

៥. ស្នើសុំអនុសាសន៍ចំពោះការរៀបចំតំបន់មរតកប្រវត្តិសាស្ត្រយោធាតេជោ នៅយោធភូមិភាគ ទី១, ទី២ និងយោធភូមិភាគពិសេស តាមជាក់ស្តែង។

នៅក្នុងឱកាសនោះ សម្តេចតេជោ ហ៊ុន សែន បានឯកភាពនឹងការស្នើសុំខាងលើ ប៉ុន្តែទាក់ទងនឹងការស្នើបង្កើតច្បាប់ស្តីពីប្រវត្តិសាស្ត្រយោធា សម្តេចបានស្នើឲ្យមានការពិភាក្សាជាមួយក្រុមអ្នកច្បាប់បន្ថែមទៀត។ សម្តេចតេជោ ហ៊ុន សែន ក៏ជំរុញឲ្យមានការពង្រីកការសិក្សាអំពីមូលហេតុ និងដំណើរដើមទងនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសម័យលន់ នល់ ដែរ។




កងកម្លាំងប្រដាប់អាវុធ មន្ត្រីស៊ីវិល ស្ថាប័នឯកជន និងអង្គការសង្គមស៊ីវិល ចូលរួមខួបអនុស្សាវរីយ៍ លើកទី៤៦ ទិវានៃការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យ ពូជសាសន៍ ប៉ុល ពត "២០ មិថុនា ១៩៧៧-២០ មិថុនា ២០២៣" ក្រោមអធិបតីភាព សម្តេច តេជោ ហ៊ុន សែន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជុំក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាដែលធ្វើការនៅតំបន់ដាច់ស្រយាលនៅប្រទេសកម្ពុជា

*ជាវ៉ុវដ្ឋ មេត្តា*





មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជុំក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាដែលធ្វើការនៅតំបន់ដាច់ស្រយាលនៅប្រទេសកម្ពុជា រយៈពេលពីរថ្ងៃ គឺថ្ងៃទី២៦ និង ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ នៅការិយាល័យកណ្ដាលនៅទីក្រុងភ្នំពេញ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជាមួយអ្នកស្ម័គ្រចិត្តកម្ពុជាចំនួន៦៨នាក់ ដែលកំពុងធ្វើការជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមតំបន់ដាច់ស្រយាលនៅប្រទេសកម្ពុជា រួមមានស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ, ស្រុកវាលវែង ខេត្តពោធិ៍សាត់, ស្រុកមេមត់ ខេត្តត្បូងឃ្មុំ, ខេត្តកំពង់ចាម, ខេត្តព្រៃវែង និង ខេត្តតាកែវ។ ជំនួបនេះចាប់ពីថ្ងៃទី២៦ និង ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ ក្នុងគោលបំណងឲ្យអ្នកស្ម័គ្រកម្ពុជាស្គាល់ការិយាល័យកណ្ដាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅទីក្រុងភ្នំពេញ, បណ្ណាល័យសម្ដេចម៉ែ និងចូលរួមសិក្ខាសាលា «ការចងក្រងឯកសារ និងការបញ្ចូលទិន្នន័យ» ។

នៅថ្ងៃទីមួយនៃដំណើរទស្សនកិច្ចរបស់ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាដឹកនាំដោយលោក ព្រំ ដល្លា ជំនួយការគម្រោងសុខភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងលោក ឡុង ដានី នាយកមជ្ឈ-មណ្ឌលឯកសារកោះថ្មបានទៅទស្សនកិច្ចវិមានឈ្នះឈ្នះ ដែលស្ថិតនៅជាយក្រុងភ្នំពេញ។ នៅទីនោះអ្នកស្ម័គ្រចិត្តកម្ពុជា បានឈ្វេងយល់ពីអំពីសង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា ដោយក្រុមខុទ្ទាមខ្មែរក្រហមដែលបានទៅប្រមូលផ្តុំគ្នានៅតាមបណ្តោយព្រំដែន

ភាគខាងលិច បន្ទាប់ពីរបបនេះត្រូវបានផ្តួលរំលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រហូតដល់ដំណើរការចរចាបញ្ចប់សង្គ្រាមស៊ីវិលនៅប្រទេសកម្ពុជា និងការទទួលបាននូវសន្តិភាពទាំងស្រុងនៅចុងឆ្នាំ១៩៩៨ តាមរយៈគោលនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែនៗ នៅរសៀលថ្ងៃដដែល ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាបានទស្សនកិច្ច ព្រះបរមរាជវាំង ការិយាល័យកណ្តាលមជ្ឈមណ្ឌលឯកសារកម្ពុជា បណ្ណាល័យសម្តេចម៉ែ បន្ទាប់មកបានដើរទស្សនាអគារខ្ពស់ៗ ផ្សារទំនើប និងជីវភាពរស់នៅរបស់ប្រជាជននៅទីក្រុងភ្នំពេញ។

នៅថ្ងៃទីពីរ អ្នកស្ម័គ្រចិត្តកម្ពុជាបានចូលរួមសិក្ខាសាលាអំពី «ការចងក្រងឯកសារ និង ការបញ្ចូលទិន្នន័យ» ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។ អ្នកស្ម័គ្រចិត្តកម្ពុជាទាំងអស់ត្រូវបានទទួលស្វាគមន៍ និងរាក់ទាក់ពីលោកស្រី សូ ហ្វារីណា នាយិការងមជ្ឈមណ្ឌលឯកសារកម្ពុជា។

មុនចាប់ផ្តើមកម្មវិធីសិក្ខាសាលា ក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាបានឡើងណែនាំខ្លួន និងប្រាប់អំពីកិច្ចការដែលខ្លួនកំពុងអនុវត្តរៀងៗខ្លួនដោយមានការសម្របសម្រួលពីលោក ព្រំ ផល្លា។

បន្ទាប់មកលោករស់ សំពៅ នាយកបណ្ណាល័យសម្តេចម៉ែ និងជាប្រធានបណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានឡើងធ្វើបទបង្ហាញអំពីការប្រមែប្រមូលការចងក្រងការថែរក្សា និងការផ្សព្វផ្សាយ។ លោករស់ សំពៅ បានបន្ថែមថា ឯកសារនៅមជ្ឈ-មណ្ឌលឯកសារកម្ពុជាមានពីរប្រភេទធំៗគឺ ១) ឯកសារខ្មែរក្រហមចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និង ២) ឯកសារសិទ្ធិមនុស្ស គឺមុនឆ្នាំ១៩៧៥ និងក្រោយ ឆ្នាំ១៩៧៩ ដែលនៅក្នុងឯកសារធំៗ ទាំងពីរខាងលើនេះ បែងចែកចេញជាប្រភេទឯកសារតូចៗផ្សេងទៀតដែលមជ្ឈមណ្ឌលឯកសារកម្ពុជាប្រមូលបាន និងបានមកពីការបរិច្ចាករបស់សប្បុរសជនដែលសរុបទាំងអស់មានចំនួនជាង១លានទំព័រ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារត្រូវបានផ្តល់ទៅសាលាក្តីខ្មែរក្រហមដើម្បីជាភស្តុតាងកាត់ទោសមេដឹកនាំខ្មែរក្រហម

តមកលោក ឆេង វ៉េង គឺជាប្រធានបណ្ណាល័យនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបានឡើងធ្វើបទបង្ហាញ








មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជុំក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាដែលធ្វើការនៅតំបន់ដាច់ស្រយាលនៅប្រទេសកម្ពុជា រយៈពេលពីរថ្ងៃ គឺថ្ងៃទី២៦ និង ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ នៅការិយាល័យកណ្តាលនៅ ទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជុំក្រុមអ្នកស្ម័គ្រចិត្តកម្ពុជា ដែលធ្វើការនៅតំបន់ដាច់ស្រយាលនៅប្រទេសកម្ពុជា រយៈពេលពីរថ្ងៃ គឺថ្ងៃទី២៦ និង ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ នៅការិយាល័យកណ្ដាលនៅទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អំពីការគ្រប់គ្រងសៀវភៅ និងចុះបញ្ជីសៀវភៅថា បណ្ណាល័យនេះបានបង្កើតឡើងនៅឆ្នាំ១៩៩៨។ ដំបូងបណ្ណាល័យមជ្ឈមណ្ឌលឯកសារកម្ពុជាមានសៀវភៅតែ២០០ក្បាលតែប៉ុណ្ណោះ ប៉ុន្តែបច្ចុប្បន្នសៀវភៅ បានកើនឡើងជាង៣០០០ក្បាល។ ការចុះបញ្ជីសៀវ ត្រូវបានបែងចែកជា១០ក្រុមធំៗ និងកំណត់ដោយលំដាប់លេខ ដូចតទៅគឺ៖ ១) ស្នាដៃទូទៅ ពីលេខ០០០-០៩៩, ២) ទស្សនវិទ្យា និងចិត្តវិទ្យា ពីលេខ១០០ ដល់លេខ១៩៩, ៣) សាសនា ពីលេខ២០០ ដល់លេខ២៩៩, ៤) វិទ្យាសាស្ត្រសង្គម ពីលេខ ៣០០ ដល់ លេខ ៣៩៩, ៥) ភាសា ពីលេខ៤០០ ដល់លេខ ៤៩៩, ៦) វិទ្យាសាស្ត្រធម្មជាតិ និងគណិតវិទ្យា ពីលេខ ៥០០ ដល់លេខ ៥៩៩, ៧) បច្ចេកវិទ្យា ពីលេខ៦០០ ដល់លេខ ៦៩៩, ៨) សិល្បៈ ពីលេខ ៧០០ ដល់លេខ ៧៩៩, ៩) អក្សរសាស្ត្រ និងវោហាសាស្ត្រ ពីលេខ ៨០០ ដល់លេខ ៨៩៩ ១០) ប្រវត្តិសាស្ត្រ - ជីវប្រវត្តិ និងភូមិសាស្ត្រ ពីលេខ ៩០០ ដល់លេខ ៩៩៩

លោក ឆេង វ៉េង លើកឡើងថា ការចុះបញ្ជីសៀវភៅគឺជាកិច្ចដែលត្រូវយកចិត្តដាក់ព្រោះអ្នកចុះបញ្ជីត្រូវអានខ្លឹមសារនៅក្នុងសៀវភៅ ទាំងអស់ដើម្បីងាយស្រួលចុះលេខរៀងទៅតាមក្រុមសៀវភៅ។ ការយល់ដឹងអំពីការចុះបញ្ជីសៀវភៅ គឺមានសារសំខាន់ណាស់ជាពិសេសសម្រាប់អ្នកសរសេរសៀវភៅ អ្នកសិក្សាស្រាវជ្រាវ និងនិស្សិតដែលកំពុងសិក្សានៅតាមសាកលវិទ្យាល័យនៅក្នុងស្រុក និងនៅបរទេស។

**ខាងក្រោមនេះគឺជាការយល់ឃើញរបស់អ្នកស្ម័គ្រចិត្តកម្ពុជា នៅតាមបណ្ដាខេត្តដាច់ស្រយាលដែលបានចូលរួមសិក្ខាសាលា ៖**

ខ្ញុំឈ្មោះ សុទី អាស៊ីរ៉ស់ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តកំពង់ចាម។ ខ្ញុំមានអាយុ១៧ឆ្នាំ រៀនថ្នាក់ទី១២ នៅវិទ្យាល័យកោះសូទិន។ ខ្ញុំបានចូលរួមការងារស្ម័គ្រចិត្តរបស់គម្រោងសុខភាពបានរយៈពេល២ខែមកហើយ។ ថ្ងៃនេះខ្ញុំបានចូលរួមកម្មវិធីសិក្ខាសាលាអំពី«ការថែរក្សាឯកសារ និង ការបញ្ចូលទិន្នន័យ» ធ្វើឲ្យខ្ញុំទទួលបានចំណេះដឹងច្រើនអំពីប្រភេទឯកសារ ការរៀបចំឯកសារ និងរក្សាទុកឯកសារ ដែលពីមុនមកខ្ញុំមិនបានដឹងថាឯកសារ

សំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានអ្វីខ្លះនោះទេ។ ខ្ញុំសប្បាយចិត្តដែលបានចូលរួមផ្ទាល់ ហើយក៏សូមអរគុណដល់វាគ្មិនដែលបានពន្យល់ពីប្រភេទឯកសារដែលខ្ញុំមិនបានដឹងពីមុនមក។

ខ្ញុំឈ្មោះ ធី គីម ហុង គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា នៅស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំទើបតែរៀនចប់ថ្នាក់ទី១២ ហើយខ្ញុំមានឱកាសធ្វើជាអ្នកស្ម័គ្រចិត្តកម្ពុជាលើគម្រោងសុខភាព និងបានជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន២០នាក់។ ពេលខ្ញុំចូលរួមសិក្ខាសាលាអំពី«ការចងក្រងឯកសារ និងការបញ្ចូលទិន្នន័យ» ធ្វើឲ្យខ្ញុំដឹងអំពីប្រភេទឯកសារសំខាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងបានដឹងថាមជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ឯកសារដល់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។

ខ្ញុំឈ្មោះ លី ស៊ី មានអាយុ១៩ឆ្នាំ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តត្បូងឃ្មុំ។ ខ្ញុំបានចូលធ្វើការងារស្ម័គ្រចិត្តបានរយៈពេល២ខែហើយ។ ខ្ញុំចូលចិត្តការងារស្ម័គ្រចិត្តនេះព្រោះខ្ញុំបានជួបជាមួយចាស់ទុំនៅក្នុងភូមិ និងបានស្តាប់រឿងរ៉ាវរបស់គាត់។ ថ្ងៃនេះ ខ្ញុំបានចូលរួមកម្មវិធីសិក្ខាសាលាអំពី«ការចងក្រងឯកសារ និងការបញ្ចូលទិន្នន័យ»។ ដំបូងខ្ញុំមិនរំពឹងថាទទួលបានបទពិសោធ៍ថ្មីៗទេ ប៉ុន្តែខុសពីការរំពឹងទុកពីមុន គឺខ្ញុំទទួលបានចំណេះដឹងថ្មីបទពិសោធ៍ថ្មីៗ ស្គាល់ឯកសារសំខាន់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងឯកសារសិទ្ធិមនុស្ស ដែលធ្វើឲ្យខ្ញុំស្រឡាញ់កិច្ចការងារស្ម័គ្រចិត្តនេះ។

ខ្ញុំឈ្មោះ មឿន ស្រីនាង គឺជាអ្នកស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារ ខេត្តតាកែវ។ ខ្ញុំរៀននៅវិទ្យាស្ថានសន្តិប៉ូល ឆ្នាំទី២ ផ្នែកក្សេតសាស្ត្រ។ ខ្ញុំបានធ្វើការជាអ្នកស្ម័គ្រចិត្តបានរយៈពេលប្រហែលជា២ខែហើយ។ ខ្ញុំបានជួបសម្ភាន៍ចាស់ៗចំនួន៩ នាក់នៅក្នុងភូមិ ហើយចាស់ទុំមួយចំនួនបានបាត់សាច់ញាតិរបស់ខ្លួននៅសម័យខ្មែរក្រហម។

ខ្ញុំឈ្មោះ យ៉េត លាងស្រេង អាយុ១៧ឆ្នាំ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តព្រៃវែង។ ខ្ញុំបានចូលរួមធ្វើការងារស្ម័គ្រចិត្តបានរយៈពេល១ខែ។ ខ្ញុំសប្បាយរីករាយ និងទទួលបានចំណេះដឹងថ្មីៗអំពីការងារឯកសារនៅមជ្ឈមណ្ឌលឯសារកម្ពុជាបន្ទាប់ពីខ្ញុំបានចូលរួមសិក្ខាសាលា «ការចងក្រងឯកសារ និងការបញ្ចូលទិន្នន័យ» ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានៅរាជធានីភ្នំពេញ។

ខ្ញុំឈ្មោះ ភួន សុរីន អាយុ ២០ឆ្នាំ គឺជាអ្នកស្ម័គ្រចិត្តកម្ពុជាមកពីមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ តាមរយៈសិក្ខាសាលានៅថ្ងៃនេះ ខ្ញុំទទួលបានចំណេះដឹងច្រើនអំពីរបៀបរក្សាទុកឯកសារ និងដឹងថាឯកសារមានប៉ុន្មានប្រភេទនៅមជ្ឈមណ្ឌលឯកសារកម្ពុជា រួមទាំងការរៀបចំចុះបញ្ជីសៀវភៅនៅបណ្ណាល័យមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ក្រោយបញ្ចប់សិក្ខាសាលា អ្នកស្ម័គ្រចិត្តកម្ពុជានៅតាមបណ្តាខេត្ត នឹងត្រូវបានជ្រើសរើសឲ្យមកបំពេញការងាររយៈពេលមួយខែនៅមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្រុងភ្នំពេញ។





មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជុំក្រុមអ្នកស្ម័គ្រចិត្តកម្ពុជាដែលធ្វើការនៅតំបន់ដាច់ស្រយាលនៅប្រទេសកម្ពុជារយៈពេលពីរថ្ងៃ គឺថ្ងៃទី២៦ និង ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ នៅការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រឿងរ៉ាវរបស់ជនពិការក្នុងរបបខ្មែរក្រហម នៅខេត្តកំពង់ចាម

***សាំង ចាន់ធូ***

ចន្លោះពីថ្ងៃទី១០ ដល់ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ អ្នកស្ម័គ្រចិត្តកម្ពុជា ប្រចាំខេត្តកំពង់ចាម ជំនាន់ទី៦ ដឹកនាំដោយ សាំង ចាន់ធូ ចុះជួបនិងស្តាប់បទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការ។ ខាងក្រោមនេះគឺជារឿងរ៉ាវសង្ខេបរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនពិការចំនួន៤នាក់ ៖

## ទេព សារី



ទេព សារី ភេទប្រុស អាយុ៧១ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលពិការភ្នែកទាំង២ ប្រាប់អំពីបទពិសោធន៍របស់ខ្លួនថា «ខ្ញុំកើតនៅឆ្នាំ១៩៥២ ក្នុងគ្រួសារកសិករនៅភូមិពន្លៃចក ឃុំមៀន ស្រុកអូររាំងឪ ខេត្តកំពង់ចាម។ កាលនៅវ័យកុមារ ខ្ញុំមានសភាពធម្មតាដូចកុមារដទៃទៀតនៅក្នុងភូមិ។ នៅអាយុ៦ឆ្នាំ ខ្ញុំពិការភ្នែកទាំងសងខាង ពីព្រោះខ្ញុំមានជំងឺពិសអាចម៍កុកនៅពេលនោះ។ ខ្ញុំមិនអាចទៅរៀនបានទេ គឺនៅផ្ទះជាមួយឪពុកម្តាយ។ នៅអាយុ១០ឆ្នាំ ខ្ញុំចាប់ផ្តើមរៀនប្រើប្រាស់ឧបករណ៍ភ្លេងបុរាណខ្មែរ គឺជំនាញផ្នែកទ្រអ៊ូ និងទ្រសោ។ បន្ទាប់ពីរៀនអស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំអាចដើរលេងភ្លេងបានដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ។ ពេលនោះ គឺនៅក្នុងសម័យសង្គមរាស្ត្រនិយម។

បន្ទាប់ពីមានរដ្ឋប្រហាររបស់ លន់ នល់ នៅឆ្នាំ១៩៧០មក ភូមិរបស់ខ្ញុំគឺជាសមរភូមិប្រទាញប្រទង់រវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ហើយក្រោយមកត្រូវបានខ្មែរក្រហមរំដោះបាន។ នៅពេលនោះខ្ញុំមានអាយុ១៨ឆ្នាំ។ ខ្ញុំបានស្ម័គ្រចិត្តចូលរួមជាមួយខ្មែរក្រហម ហើយរត់ចូលព្រៃម៉ាក់គីតស៊ូជាមួយអ្នកភូមិផ្សេងទៀត។ ដោយសារតែពិការភាព និងជំនាញសិល្បៈរបស់ខ្ញុំ ខ្ញុំត្រូវបានដាក់ឲ្យបម្រើក្នុងកងសិល្បៈខ្មែរក្រហម។ ខ្ញុំអាចដើរចុះឡើងបានដោយប្រើប្រាស់ដំបងឈើ ហើយមានពេលខ្លះសមមិត្តនៅក្នុងកងសិល្បៈជាមួយគ្នាជួយដឹកដៃ។ រហូតដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការនៅសហករណ៍នៅម្តុំស្អួង។ ទាំងនេះគឺជាការចាប់ផ្តើមដែលខ្ញុំទទួលរងទុក្ខលំបាក ព្រោះខ្ញុំត្រូវធ្វើការនៅក្នុងកងសិល្បៈផង និងនៅវាលស្រែផង។ ខ្ញុំត្រូវបានកំណត់ឲ្យដឹកដីដូចអ្នកដទៃទៀតដែរ។ ចំណែកឯរបបអាហារវិញគឺមិនគ្រប់គ្រាន់ទេ។ ខ្ញុំបានរួចផុតពីសេចក្តីអត់ឃ្លាន បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅដើមឆ្នាំ១៩៧៩»។

## អ៊ុង រិទ្ធ

អ៊ុង រិទ្ធ ភេទប្រុស អាយុ៥៦ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលពិការជើងទាំងពីរ រៀបរាប់អំពីដំណើរជីវិតរបស់ខ្លួនថា «ខ្ញុំឈ្មោះ អ៊ុង រិទ្ធ អាយុ៥៦ឆ្នាំ រស់នៅភូមិបឹងស្នាយ សង្កាត់



សំបួរមាស ក្រុងកំពង់ចាម ខេត្តកំពង់ចាម។ ខ្ញុំមានឪពុកឈ្មោះ អ៊ុង និងម្តាយឈ្មោះ អាត ហើយខ្ញុំគឺជាកូនទី៦ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន ៧ នាក់។

នៅក្នុងសម័យខ្មែរក្រហម ខ្ញុំត្រូវបានដាក់ក្នុងកងកុមារ ដើររើសអាចម៍គោ ដេញចាប និងឃ្វាលគោ។ ខ្ញុំកំពុងតែឃ្វាលគោ ចៃដន្យបានឃើញយោធាខ្មែរក្រហមបណ្តើរមនុស្ស ទាំងជួរៗមិនដឹងយកទៅ ទីណាឡើយ។ រយៈពេល១ម៉ោង ទៅ២ម៉ោង ក្រោយមក ខ្ញុំឃើញយោធាត្រឡប់មកវិញ ប៉ុន្តែខ្ញុំមិនឃើញប្រជាជនដែលត្រូវបានបណ្តើរចូលទៅក្នុងព្រៃនោះត្រឡប់មកវិញទេ។ ខ្ញុំបានឮគេនិយាយថា ខ្មែរក្រហមឲ្យប្រជាជនទៅកាប់ព្រៃ និងធ្វើផ្ទះស្នាក់នៅ ទីនោះ។ ថ្ងៃមួយ ប្រធានកងឲ្យខ្ញុំទៅរកខសយកមកទុកដាំបាយ ដាំបបរ ប៉ុន្តែចៃដន្យខ្ញុំឃើញខ្មោចដែលខ្មែរក្រហមកប់មិនជិត។ ខ្ញុំឃើញក្បាល និងជើងដៃ នៅកណ្តាលវាល។ ខ្ញុំរន្ធត់ ហើយនាំគ្នារត់ត្រឡប់មកវិញ។ ខ្ញុំជួបរឿងរ៉ាវនេះជាច្រើនលើក។

ក្រោយមក ខ្ញុំបានធ្លាក់ខ្លួនឈឺ និងនៅជាមួយបងស្រី។ ថ្ងៃមួយមេកងប្រើឲ្យបងស្រីខ្ញុំបើកឡានម៉ាក GMC កង់១០ ដឹកមនុស្សយកទៅនៅភូមិថ្មី ក្នុងខេត្តកំពង់ធំ ហើយដោយសារខ្ញុំនៅក្មេង ខ្ញុំបានយំទៅតាមបងស្រីខ្ញុំ។ ពេលនោះមេកងឲ្យបងស្រីយកខ្ញុំទៅជាមួយ ដោយដាក់ខ្ញុំនៅក្នុងកាប៊ីន ឡានជិតកន្លែងគាត់។ បងស្រីបើកឡានទៅដល់ទំនប់ ១ មករា ដែលស្ថិតនៅក្នុងខេត្តកំពង់ធំ ហើយពេលនោះខ្មែរក្រហមបានធ្វើបាបប្រជាជនដែលដឹកទៅ ទាំងនោះ។ បងស្រីខ្ញុំបានយកដៃបាំងភ្នែកខ្ញុំកុំឲ្យមើលឃើញទិដ្ឋភាពទាំងនោះ។ ចាប់តាំងពីពេលនោះមក ខ្ញុំឈប់ទៅតាមបងស្រីខ្ញុំទៀតហើយ។ ខ្ញុំឃើញឡានបងស្រី ខ្ញុំខ្លាចនិងរត់គេចចូលក្នុងព្រៃ។ ម្តាយរបស់ខ្ញុំនិយាយប្រាប់ខ្ញុំថា ឈប់ទៅតាមបងស្រី ប្រយ័ត្នយក្សខាំ និងខ្លាខាំ។

ខ្ញុំធ្លាប់ឃើញប្រជាជនរងទុក្ខលំបាកវេទនា និងរងការកាប់សម្លាប់។ ខ្ញុំនៅក្នុងកងកុមារ ប្រធានចុងភៅឲ្យហូបបបរមួយកូនវែក។ អ្នកខ្លះទ្រាំហូបបបរលាយបេកខ្ចីដែលមានរសជាតិចត់ៗដើម្បីចម្អែតក្រពះ។ ប៉ុន្តែរបបអាហារខ្ញុំគ្រាន់បើជាងអ្នកនៅកងចល័តដែលមានអាយុ១៥ឆ្នាំឡើងទៅ ព្រោះកងចល័តទាំងនោះមិនអាចរកអាហារហូបបានទេ គឺគាត់ដឹងតែធ្វើការងារ។ ខ្ញុំនៅកងកុមារអាចរកអាហារហូបក្រៅបាន។ ពេលដេញចាប ឃ្វាលគោ ខ្ញុំអាចចាប់ក្តាមយកមកដុតហូប ប៉ុន្តែខ្ញុំលួចលាក់មិនឲ្យខ្មែរក្រហមឃើញឡើយ។ នៅពេលយើងឃើញប្រធានកងដើរមក យើងកើបភក់មកកប់ភ្លក់ភ្លើង ហើយដេញគោទៅឆ្ងាយ។ នៅពេលប្រធានកងទៅបាត់ យើងកាយយកក្តាមខ្យងទៅលាងទឹក ហើយនាំគ្នាហូប»។

## ដាំ ឃីម



ដាំ ឃីម ភេទស្រី អាយុ ៧១ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលពិការភ្នែកទាំងសងខាង និយាយអំពីបទពិសោធន៍របស់ខ្លួនថា «ខ្ញុំឈ្មោះ ដាំ ឃីម សព្វថ្ងៃរស់នៅភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំពិការភ្នែកទាំងពីរ ហើយសព្វថ្ងៃខ្ញុំនៅចាំផ្ទះ។ ខ្ញុំគឺជាស្ត្រីមេម៉ាយ។ ឪពុករបស់ខ្ញុំមានប្រពន្ធពីរ ហើយខ្ញុំមានបងប្អូន១០នាក់ គឺស្រី៣នាក់ និងប្រុស៧ នាក់។ រឿងរ៉ាវដែលខ្ញុំចងចាំកាលពីសម័យខ្មែរក្រហម គឺខ្មែរក្រហមប្រើខ្ញុំឲ្យស្ទូង ដកលីសែងស្រូវដោយមិនគិតថាប្រុសឬស្រីឡើយ។ ខ្មែរក្រហមប្រើខ្ញុំឲ្យធ្វើការទាំងកូនខ្ចី ដោយអត់បាយអត់ទឹក។ ប្រធានកងប្រើខ្ញុំឲ្យស្ទូងស្រូវក្នុងមួយហិកតា ១២នាក់។ មានអ្នកខ្លះសន្លប់ និងខ្យល់គរនៅតាមផ្លូវ ព្រោះហូបចុកមិនគ្រប់ និងធ្វើការហួសកម្លាំង។

## ប៉ោង ព្រីន



ប៉ោង ព្រីន ភេទប្រុស អាយុ៧៥ឆ្នាំ គឺជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលពិការជើងស្តាំ និយាយអំពីរឿងរ៉ាវជីវិតក្នុងរបបខ្មែរក្រហមថា «ខ្ញុំឈ្មោះ ប៉ោង ព្រីន មានទីកន្លែងកំណើតនៅភូមិដីដុះ ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិគគរ២ ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ខ្ញុំនៅផ្ទះ និងមិនមានមុខរបរទេ។ ខ្ញុំពោះម៉ាយ ព្រោះប្រពន្ធរបស់ខ្ញុំឈឺស្លាប់បោលយូរហើយ។ ខ្ញុំមានកូនសរុបចំនួន៤នាក់ ប្រុស២នាក់ និងស្រី២នាក់។ ឪពុករបស់ខ្ញុំឈ្មោះ គួង ប៉ោង និងម្តាយឈ្មោះ អួង សារី។ ខ្ញុំគឺជាកូនទី២ ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៤នាក់។ ខ្ញុំនៅចាំបានថា ខ្មែរក្រហមបានប្រើខ្ញុំឲ្យអារខសដាក់ក្នុងរោងបាយ។ ពេលនៅរោងបាយ ខ្ញុំបានឃើញឈ្លបខ្មែរក្រហមចាប់មនុស្សធំ និងកូនក្មេង ព្រោះខ្ញុំបានទៅសុំឈ្លបខ្មែរក្រហមនោះអុជបារីជក់ ប៉ុន្តែឈ្លបបានបក់ដៃឲ្យខ្ញុំចេញពីទីនោះ។ ពេលដែលខ្ញុំដើរចេញដល់របងផ្ទះ ខ្ញុំឃើញឈ្លបចាប់អ្នកទាំងពីរយកទៅវាយចោលនៅក្រោយផ្ទះក្បែរគុម្ពឫស្សី ខ្ញុំសព្វថ្ងៃ។ នៅពេលឃើញហេតុការណ៍នោះ ខ្ញុំបានដឹកដៃកូនខ្ញុំរត់កាត់ភក់ចេញពីកន្លែងនោះ ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ដែរ»។



ផ្ទះរបស់ប្រជាជននៅតាមដងទន្លេមេគង្គ ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សមកពីសាលាអង្គការតារាម៉ាណា ដែលមានជីវភាពខ្វះខាត ទស្សនកិច្ច បណ្ណាល័យសម្តេចម៉ែ

*សោម ប៊ុនថន*





សិស្សបឋមសិក្សាមកពីសាលាអង្គការតារាម៉ាណាដែលមានជីវភាពខ្វះខាត ទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ កាលពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣។ (ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣ សិស្សបឋមសិក្សាចំនួន៥០នាក់ដែលមានជីវភាពខ្វះខាត មកពីសាលាអង្គការតារាម៉ាណា ដែលមានទីតាំងស្ថិតនៅខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ បានមកទស្សនកិច្ចនៅបណ្ណាល័យសម្តេចម៉ែ។ សិស្សសាលាទាំងនេះភាគច្រើនត្រូវបានជ្រើសរើសចេញពីក្រុមគ្រួសារដែលមានជីវភាពក្រលំបាក រស់នៅតាមបណ្តោយផ្លូវរថភ្លើង ក្នុងទីក្រុងភ្នំពេញ និងមួយចំនួនទៀតជ្រើសចេញពីក្រុមគ្រួសារដែលមានឪពុកម្តាយធ្វើការនៅតាមរោងចក្រ និងធ្វើជាកម្មករ ដែលគ្មានលទ្ធភាពថែទាំកូន និងបញ្ជូនកូនឲ្យទៅសិក្សារៀនសូត្រ។

បើតាម វណ្ណ វរៈបុត្រ គឺជាគ្រូបង្រៀននៅសាលាអង្គការតារាម៉ាណា ដែលបានដឹកនាំសិស្ស រួមទាំងបុគ្គលិកជនជាតិបារាំង មកទស្សនកិច្ចនៅបណ្ណាល័យសម្តេចម៉ែ បានឲ្យដឹងថា សាលាអង្គការតារាម៉ាណាមានកម្រិតសិក្សាត្រឹមថ្នាក់បឋមសិក្សា និងមានសិស្សសរុបទាំងអស់ប្រមាណជាង១០០នាក់។ លោកបន្តថា ក្រៅពីសិក្សាភាសាខ្មែរ សាលាបានផ្តល់ឱកាសឲ្យសិស្សសិក្សាភាសាបារាំង និងបានទៅទស្សនកិច្ចនៅតាមបណ្តាស្ថាប័នសិក្សាស្រាវជ្រាវ និងអប់រំផ្សេងៗ ដើម្បីឲ្យសិស្សបានស្គាល់ និងសិក្សាឈ្វេងយល់បន្ថែម។



សិស្សបឋមសិក្សាមកពីសាលាអន្តរជាតិម៉ាណា ដែលមានជីវភាពខ្វះខាត ទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែ កាលពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២៣។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)







យោងតាមច្បាប់ ស្តីពីការអប់រំ នៅប្រទេសកម្ពុជា ត្រង់មាត្រា១៧ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ បានចែងថា «ការអប់រំចំណេះដឹងទូទៅ» គឺជាការចាំបាច់ដែលធ្វើឲ្យអ្នកសិក្សាមានការរីកចម្រើនចំណេះដឹង សីលធម៌ បុគ្គលិកលក្ខណៈល្អ ដោយលើកកម្ពស់សមត្ថភាពខាងផ្លូវចិត្ត បញ្ញាឲ្យចេះប្រើចំណេះដឹង និងបំណិនមូលដ្ឋានៗ ការអប់រំចំណេះដឹងទូទៅរួមមាន៖

- ការអប់រំបឋមសិក្សា ឬ ភូមិសិក្សាទី១ ចាប់ពីថ្នាក់ទី១ (មួយ) ដល់ទី៦ (ប្រាំមួយ) នៃកម្មវិធីអប់រំក្នុងប្រព័ន្ធ ឬការអប់រំកម្រិតសមមូល
- ការអប់រំមធ្យមសិក្សា ឬ ភូមិសិក្សាទី២ ចាប់ពីថ្នាក់ទី៧ (ប្រាំពីរ) ដល់ថ្នាក់ទី១២ (ដប់ពីរ) ការអប់រំសិក្សាមានពីរដំណាក់កាល ដំណាក់កាលទី១ (មួយ) មធ្យមសិក្សាបឋមភូមិ ចាប់ពីថ្នាក់ទី៧ (ប្រាំពីរ) ដល់ទី៩ (ប្រាំបួន) និងដំណាក់កាលទី២ (ពីរ) មធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ (ដប់) ដល់ថ្នាក់ទី១២ (ដប់ពីរ)។

# ចាន់ ដាន ៖ ពិការជើងដោយសារជាន់មីននៅខ្សែព្រំដែនកម្ពុជា-ថៃ

ធី គីមហុង



ចាន់ ដាន អាយុ៧៧ឆ្នាំ រស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (ឡុង អូន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ចាន់ ដាន ភេទប្រុស អាយុ៧៧ឆ្នាំ រស់នៅភូមិស្ទឹងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ចាន់ ដាន មានស្រុកកំណើតនៅភូមិនីពេជ ឃុំនីពេជ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ កាលពីកុមារ ចាន់ ដាន បានសិក្សារៀនសូត្រ និងបួសរយៈពេល៧ព្រះវស្សានៅវត្តក្នុងភូមិនីពេជ។ មុនពេលរដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សហីនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ចាន់ ដានបានសឹក និងចូលធ្វើកងទ័ពបដិវត្តន៍ខ្មែរក្រហមស្ថិតនៅក្នុងព្រៃខ្សែរភូមិកំណើតរបស់ខ្លួន។ បន្ទាប់មកនៅឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ ចាន់ ដាន ត្រូវបានខ្មែរក្រហមបញ្ជូនមកវាយជាមួយទាហាន លន់ នល់ ក្នុងយុទ្ធនាការចេនឡាទី១ និងចេនឡាទី២ តាមផ្លូវជាតិលេខ៦ ខ្សែរភ្នំសន្ទុក និងកំពង់ថ្ម។ នៅឆ្នាំ១៩៧៣ ចាន់ ដាន ត្រូវបញ្ជូនមកវាយជាមួយ ទាហាន លន់ នល់ នៅក្នុងស្រុកបារាយ និងស្រុកខ្ទុង្គទៀត។

ចាប់ពីឆ្នាំ១៩៧៤ និង១៩៧៥ អង្គភាពរបស់ចាន់ដានត្រូវបានដំឡើងជាកងពលទី១របស់ភូមិភាគឧត្តរ និងត្រូវចូលវាយសមរភូមិទីក្រុងភ្នំពេញតាមភ្នំប្រាសិទ្ធ និងផ្លូវជាតិលេខ៥។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ចាន់ ដាន រួមជាមួយអង្គភាពរបស់ខ្លួនបានចូលមកដល់ទីក្រុងភ្នំពេញតាមផ្លូវជាតិលេខ៥ និងជួបជុំគ្នានៅគល់ស្ពានជ្រោយចង្វារ។ បន្ទាប់មកអង្គភាពរបស់ ចាន់ ដានបានផ្លាស់ទៅឈរជើងនៅទួលគោក ដើម្បីជួយសម្រួលការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងត្រូវខ្មែរក្រហមចាត់តាំងឲ្យដើរបោសសម្អាត និងប្រមូលទ្រព្យសម្បត្តិនៅតាមផ្ទះប្រជាជនយកទៅដាក់ក្នុងឃ្លាំង។ រយៈពេលពីបីខែក្រោយមក ខ្មែរក្រហមបានចាត់តាំង ចាន់ ដាន ឲ្យមកធ្វើស្រែនៅម្តុំវត្តឃ្មួញ។ នៅឆ្នាំ១៩៧៦ ចាន់ ដាន ត្រូវបានជ្រើសរើសឲ្យមកបម្រើការងារកងអាកាសនៅពោធិ៍ចិនតុង។ ចាន់ ដាន ធ្លាប់បានចូលរួមដឹកជញ្ជូនកងទ័ពខ្មែរក្រហមទៅរៀននៅប្រទេសចិនចំនួន២ដង គឺដឹកពីពោធិ៍ចិនតុងទៅ ទីក្រុងប៉េកាំងប្រទេសចិន។ ក្នុងចំណោមកងទ័ពខ្មែរក្រហមដែលបញ្ជូនទៅរៀននៅប្រទេសចិនក៏មានកូនប្រុស អៀង

សារី ឈ្មោះ អៀង វុធ ដែរ។

នៅឆ្នាំ១៩៧៧ ពេលដែលមេដឹកនាំភូមិភាគឧត្តរត្រូវបានចោទប្រកាន់ថាក្បត់អង្គការ និងចាប់ខ្លួន ចាន់ ដាន ត្រូវបានខ្មែរក្រហមបញ្ជូនទៅធ្វើការងារនៅព្រលានយន្តហោះកំពង់ឆ្នាំង។ ពេលនោះ ចាន់ ដាន ត្រូវចាត់តាំងឲ្យយាមកម្មករនារីលាងខ្សាច់ សម្រាប់យកមកសាងសង់ព្រលានយន្តកំពង់ឆ្នាំង។ កន្លែងលាងខ្សាច់នៅក្នុងស្រុកបរិបូណ៌។ មានជនាញការចិនចំនួនពីរនាក់ប្រចាំការ និងធ្វើការងារនៅទីនោះ។ ពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ចាន់ ដាន និងកងទ័ពខ្មែរក្រហមដទៃទៀតបានភៀសខ្លួនទៅព្រំដែនភាគខាងលិច។ នៅឆ្នាំ១៩៨៥ ចាន់ ដានបានពិការជើងដោយសារជាន់មីនដែលអង្គភាពរបស់ខ្លួនបានដាក់នៅតាមព្រំដែនកម្ពុជា-ថៃ។

នៅពេលកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ អង្គភាពរបស់ ចាន់ ដានបានមករស់នៅតំបន់សំឡូតវិញ។ រហូតដល់កងកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មចុះចូលជាមួយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៩៦ ចាន់ ដាន បានចូលរួមជាមួយអង្គភាពរបស់ គឹម ពៅ និងមករស់នៅក្នុងស្រុកវាលវែងរហូតមកដល់សព្វថ្ងៃ។



ចាន់ ដាន (ខាងស្តាំ) កំពុងផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលផ្សះផ្សា វាលវែង។ (ឡុង អូន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ជាង ទឹម ៖ កងការពារស្ថានទូតអេហ្ស៊ីប ក្នុងរបបខ្មែរក្រហម

ចាន់ ណារិទ្ធ



ជាង ទឹម អាយុ៦៥ឆ្នាំ រស់នៅភូមិស៊ីងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (ឡុង អូន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាង ទឹម ភេទប្រុស អាយុ៦៥ឆ្នាំ រស់នៅភូមិស៊ីងថ្មី ឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ជាង ទឹម មានស្រុកកំណើតនៅភូមិអន្លង់ភេ ឃុំអន្លង់ភេ ស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែង។ កាលពីកុមារ ជាង ទឹម រស់នៅជាមួយឪពុកម្តាយដែលប្រកបមុខរបរធ្វើស្រែចម្ការ។ ជាង ទឹម មិនបានរៀនសូត្រទេ។ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាង ទឹម ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យធ្វើការងារលើកទំនប់ ជីកប្រឡាយ និងជួយធ្វើស្រែនៅតាមកងចល័តភូមិ។

នៅក្នុងឆ្នាំ១៩៧៦ ជាង ទឹម និងយុវជននៅក្នុងភូមិអន្លង់ភេ៤នាក់ទៀត ត្រូវខ្មែរក្រហមជ្រើសរើសឲ្យមកបម្រើការងារជាកងការពារមន្ទីរ៨៧០ នៅទីក្រុងភ្នំពេញ។ ពេលមកដល់ទីក្រុងភ្នំពេញ ជាង ទឹម និងយុវជនដទៃត្រូវបានចូលរៀនវគ្គនយោបាយ និងយុទ្ធសាស្ត្រកងទ័ពនៅអង្គភាពកងការពារនៃមន្ទីរ៨៧០រយៈពេល៤ខែ។ បន្ទាប់មក ជាង ទឹម និងយុវជន៣នាក់ទៀត ត្រូវចាត់តាំងឲ្យយាមការពារនៅស្ថានទូតអេហ្ស៊ីប នៅម្តុំបឹងកក់។

មុនពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ មេដឹកនាំខ្មែរក្រហមបានបញ្ជូ ជាង ទឹម និងកងការពារដទៃទៀតយករថយន្តដឹកបុគ្គលិកស្ថានទូតអេហ្ស៊ីប និងបុគ្គលិកស្ថានទូតចិន ចាកចេញពីទីក្រុងភ្នំពេញទៅប៉ោយប៉ែត ចំនួនពីរលើក។ នៅពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និង កងទ័ពវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ ជាង ទឹម បានដើរតាមព្រំដែនពីប៉ោយប៉ែតមកប៉ៃលិន និងបន្តមកសំឡូតជួបមេដឹកនាំខ្មែរក្រហម។ ជាង ទឹម បន្តធ្វើជាកងការពារមេដឹកនាំខ្មែរក្រហមនៅអង្គភាព១៩ នៅតំបន់សំឡូត-កោះកុង រហូតដល់ចុងឆ្នាំ១៩៨៤។ នៅឆ្នាំ១៩៨៥ ជាង ទឹម បានជាន់មីនដែលកងទ័ពវៀតណាមដាក់នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ពិការជើងម្ខាង។ ពេលកងទ័ពវៀតណាមដកចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៨៩ អង្គភាពរបស់ជាង ទឹមបានមករស់នៅតំបន់សំឡូត។ មុនពេលកងកម្លាំងខ្មែរក្រហមធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជានៅ១៩៩៦ ជាង ទឹម បានចូលរួមជាមួយអង្គភាពរបស់ គីម ពៅ ហើយផ្លាស់មករស់នៅក្នុងស្រុកវាលវែងរហូតមកដល់សព្វថ្ងៃ។

# ប៉ក់ សារ៉ន ៖ អតីតយោធាខ្មែរក្រហម

*ឈុំ រ៉ា*



ប៉ក់ សារ៉ន អាយុ៦៥ឆ្នាំ បច្ចុប្បន្ននៅភូមិកូនក្រពើ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប៉ក់ សារ៉ន ភេទប្រុស អាយុ៦៥ឆ្នាំ មានស្រុកកំណើតនៅភូមិស្វាយមាស ឃុំកណ្ដោលជ្រុំ ស្រុកពញាក្រែក ខេត្តកំពង់ចាម។ បច្ចុប្បន្នខ្ញុំរស់នៅភូមិកូនក្រពើ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ប៉ក់ ស្លាប់មុនឆ្នាំ១៩៧០ ចំណែកម្ដាយឈ្មោះ អ៊ុក ស្លាប់ក្នុងឆ្នាំ១៩៧០ អំឡុងពេល លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ។ ខ្ញុំមានបងប្អូនចំនួន៤នាក់ ហើយខ្ញុំគឺជាកូនទី២។ កាលពីក្មេងខ្ញុំចូលរៀននៅវត្តមួយក្នុងឃុំកណ្ដោលជ្រុំ។ ខ្ញុំរៀនធម៌បាលី និងអក្សរសាស្ត្រខ្មែរ ដោយពេលព្រឹកព្រះសង្ឃបង្រៀនអក្សរសាស្ត្រខ្មែរ និងពេលយប់បង្រៀនធម៌។ ខ្ញុំរៀនធម៌បេះខ្លះហើយ ទើបព្រះចៅអធិការឲ្យបួសក្នុងអំឡុងឆ្នាំ១៩៦៩។ បន្ទាប់មកខ្ញុំសឹកវិញនៅឆ្នាំ១៩៧០ ព្រោះប្រទេសជាតិកំពុងតែមានភាពចលាចលខ្លាំង។

នៅឆ្នាំ១៩៧០ មានបាតុកម្មកើតឡើងនៅក្នុងស្រុកពញាក្រែកបន្ទាប់ពី លន់ នល់ ធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ព្រោះប្រជាជនមិនពេញចិត្តក្នុងការធ្វើរដ្ឋប្រហារនេះទេ។ នៅភូមិស្វាយមាសក៏មានប្រជាជននាំគ្នាធ្វើបាតុកម្មច្រើន ប៉ុន្តែអ្នកភូមិគ្មានកាំភ្លើងទេ ចំណែកទាហាន លន់ នល់ មានកាំភ្លើងកាន់គ្រប់គ្នា បណ្ដាលឲ្យអ្នកភូមិស្លាប់និងរបួសជាច្រើននាក់។ នៅឆ្នាំ១៩៧១ ខ្ញុំចូលធ្វើកងទ័ពបដិវត្តន៍ខ្មែរក្រហម មុនពេលចូលសមរភូមិខ្ញុំត្រូវហាត់រៀនយុទ្ធសាស្ត្រសង្គ្រាមជាមុន។ ខ្ញុំចូលកងពលលេខ១៨ ដែលមានឈ្មោះ ចន្ទ្រា គឺជាប្រធាន និង ឈ្មោះ ភ័ណ្ឌ គឺជាប្រធានទី២ ហើយឈ្មោះ សារិត គឺជាប្រធានក្ដាប់រួម។ ខ្ញុំចូលហ្វឹកហ្វឺននៅកងពលលេខ១៨អស់រយៈពេល១ឆ្នាំ ទាំងការបាញ់កាំភ្លើង បោកគ្រាប់បែក ហាត់លូនក្រាប របៀបវាយប្រហារ និងរបៀបធ្វើសង្គ្រាម។ នៅឆ្នាំ១៩៧៣ ខ្ញុំឡើងវាយតទល់ជាមួយទាហាន លន់ នល់ ជាច្រើនកន្លែង ហើយនៅខាងខេត្តស្វាយរៀងក៏ខ្ញុំធ្លាប់ទៅវាយដែរ។ ចំណែកវាយខ្លាំងជាងគេគឺនៅជីពោធិ៍ ស្រុកត្បូងឃ្មុំ ហើយខ្ញុំក៏ធ្លាប់បាក់ទ័ពរត់កាត់ព្រៃត្រែងដើម្បីគេចខ្លួនដែរ។

នៅឆ្នាំ១៩៧៥ ខ្ញុំឡើងវាយនៅទីក្រុងភ្នំពេញរហូតទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បន្ទាប់ពីរំដោះទីក្រុងភ្នំពេញ យោធាខ្មែរក្រហមស្រាវជ្រាវដើម្បីចាប់អ្នកដែលធ្លាប់ធ្វើទាហាន លន់ នល់ អ្នកពាក់ស័ក្តិ១ និងស័ក្តិ២ឡើងទៅ និងអ្នកដែលធ្លាប់ធ្វើជាមន្ត្រីដោយចោទថាជនក្បត់ ហើយបាញ់សម្លាប់ចោល។ បន្ទាប់មកយោធាខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញឲ្យទៅនៅតាមខេត្តនានា។

នៅឆ្នាំ១៩៧៦ ខ្ញុំត្រូវបានអង្គការហៅទៅរៀបការ។ ខ្ញុំសុំច្បាប់អង្គភាពចំនួនមួយសប្តាហ៍ទៅរៀបការនៅស្រុកកំណើត។ កាលនោះអង្គការរៀបការឲ្យខ្ញុំ និងប្រជាជនដែលមានចំនួនសរុប៣០គូ។ ខ្ញុំរៀបការនៅភូមិខ្នារ ឃុំខ្នារ ស្រុកត្បូងឃ្មុំ ខេត្តត្បូងកំពង់ចាម។ នៅក្នុងចំណោម៣០គូ មានតែប្តីប្រពន្ធមួយគូប៉ុណ្ណោះ ឡើងលើវេទិកាធ្វើការប្តេជ្ញាចិត្តស្មោះត្រង់ជាមួយគ្នា ស្មោះត្រង់ជាមួយអង្គការទោះមានរឿងអ្វីគឺមិនបោះបង់គ្នាឡើយ។ ក្រោយពីធ្វើការប្តេជ្ញារួចហើយ កម្មវិធីក៏ត្រូវបានរំសាយ។ ខ្ញុំក៏ត្រឡប់ទៅផ្ទះប្រពន្ធដែលទើបតែរៀបការ និងបានរស់នៅជាមួយគ្នាបានរយៈពេល៣ថ្ងៃ ទើបខ្ញុំត្រឡប់មកភ្នំពេញវិញ។

មកដល់ឆ្នាំ១៩៧៨ កងទ័ពបដិវត្តន៍ខ្មែរក្រហមវាយប្រយុទ្ធគ្នាឯង ហើយកងទ័ពភូមិភាគកណ្តាលវាយចូលមកភ្លាមៗ។ ខ្ញុំឈប់កាន់កាំភ្លើងហើយរត់មកនៅភូមិដីមាន់ ជាមួយតាចា ឡាន គឺជាមេឃុំ ហើយបានជួបប្រពន្ធខ្ញុំវិញ។ រហូតកងទ័ពវៀតណាម និងកងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជារំដោះបានទីក្រុងភ្នំពេញ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបខ្ញុំត្រឡប់ទៅនៅស្រុកខាងប្រពន្ធ និងបានប្រកបរបររកស៊ីនៅទីនោះ។



ប៉ក់ សារ៉ែន និង ឈុំ វ៉ា បុគ្គលិកមជ្ឈមណ្ឌលឯកសារកោះថ្ម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមប្រឹក្សាយុវជនកាយរិទ្ធ កាកបាទក្រហម

## និងស.ស.យ.ក ស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារកោះថ្ម និងធ្វើទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦

*ឈុំ រ៉ា*



នៅព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ ដល់យុវជនកាយរិទ្ធ កាកបាទក្រហម និង ស.ស.យ.ក ចំនួន១៥០នាក់ នៅតាមសាលាមធ្យមសិក្សានៅក្នុងស្រុកចំនួនពីរគឺស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ ដល់យុវជនកាយរិទ្ធកាកបាទក្រហម និង ស.ស.យ.ក ចំនួន១៥០នាក់ នៅតាមសាលាមធ្យមសិក្សានៅក្នុងស្រុកចំនួនពីរគឺស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ។ វេទិកាថ្នាក់រៀននេះផ្តោតសំខាន់លើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងការបង្កើតកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាថ្ងៃទី១២ ខែសភា ឆ្នាំ១៩៧៨ ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជា៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។




ជាកិច្ចចាប់ផ្តើមកម្មវិធី លោកស្រី ទី លីហ៊ាន់ អភិបាលរងស្រុកមេមត់ ខេត្តត្បូងឃ្មុំ មានប្រសាសន៍បើកកម្មវិធី និងផ្តាំផ្ញើដល់យុវជនដែលមានវត្តមាននៅទីនេះត្រូវយកចិត្តទុកដាក់ស្តាប់ការធ្វើបទបង្ហាញរបស់គ្រូខ្ទេសអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩) និងការបង្កើតកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ។ ម៉្យាងទៀត ប្អូនៗត្រូវពង្រីងសមត្ថភាពរបស់ខ្លួនឲ្យក្លាហាន បេះទំនាក់ទំនងគ្នា និងជឿជាក់លើសមត្ថភាពខ្លួនឯង។ លោកស្រីអភិបាលរងក៏បានអរគុណដល់ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម ដែលបានចំណាយពេលដ៏មានតម្លៃរៀបចំកម្មវិធីមួយនេះ។



នៅព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ ដល់យុវជនកាយរិទ្ធ កាកបាទក្រហម និង ស.ស.យ.ក ចំនួន១៥០នាក់ នៅតាមសាលាមធ្យមសិក្សានៅក្នុងស្រុកចំនួនពីរគឺស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ។ (បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មកលោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានដឹកនាំយុវជនដើរទស្សនាពិព័រណ៍រូបថតអំពីសង្គ្រាមកាលពីចុងទសវត្សរ៍ឆ្នាំ១៩៦០ រូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ រូបថតអំពីភស្តុតាងបទឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៤រូបទៀតទៅប្រទេសវៀតណាមកាលថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីស្នើសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើងដោយមានសមមិត្ត ហ៊ុន





នៅព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រ យោធាកោះថ្ម អ៊ិច-១៦ ដល់យុវជនកាយរិទ្ធ កាកបាទក្រហម និង ស.ស.យ.ក ចំនួន១៥០នាក់ នៅតាមសាលាមធ្យមសិក្សានៅក្នុងស្រុកចំនួនពីរគឺស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ។ (បណ្ណសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា)

សែនគឺជាស្ថាបនិក។ ចាប់ពីខែឧសភា ដល់ចុងខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរីកធំធាត់ និងកើនចំនួនរហូតដល់២៣ កងវរសេនាតូច និងប្រមាណ១០០ក្រុមប្រតិបត្តិការប្រដាប់អាវុធ ដែលមានកងកម្លាំងសរុបប្រមាណជាង១ម៉ឺននាក់។ បន្ទាប់មកកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាមវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត រំដោះប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

តមក លោក ឡុង ដានី បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រខ្មែរក្រហម (១៩៧៥-១៩៧៩) លើប្រធានបទ «គោលនយោបាយ៨ចំណុចរបស់ខ្មែរក្រហមបន្ទាប់ពីទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដូចខាងក្រោម៖

១) ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីប្រជុំជន

២) បំបាត់ផ្សារ និងរូបិយវត្ថុ

៣) កម្ទេចវត្តអារាម និងផ្សឹកព្រះសង្ឃ

៤) បិទសាលា និងគ្រឹះស្ថានសិក្សា

៥) បង្កើតសហករណ៍

៦) ផ្តាច់ទំនាក់ទំនង និងបំបែកបំបាក់ក្រុមគ្រួសារ

៧) ការសម្លាប់បញ្ញវន្ត មន្ត្រីរដ្ឋការ និងប្រជាជនស្លូតត្រង់

៨) ការបណ្តេញជនជាតិវៀតណាម និងធ្វើសង្គ្រាមជាមួយវៀតណាមនិងផលប៉ះពាល់មកលើ

ប្រជាជន និងសង្គមជាតិក្រោយរបបនេះដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

នៅក្នុងឱកាសនោះ ប្រធានមន្ទីរអប់រំយុវជន និងកីឡាខេត្តត្បូងឃ្មុំ លោក អ៊ិន ពៅសម្បត្តិ បានមានប្រសាសន៍បន្ថែមថា ចាប់តាំងពីចំណុចផ្ដើមរបស់សម្ដេចតេជោ ហ៊ុន សែន លោកបានចាប់ផ្ដើមពីចំណុចណា? មានប៉ុន្មានចំណុច? ចាប់តាំងពីចំណុចផ្ដើមរហូតមានការរំដោះប្រទេសជាតិ។ នៅក្នុងដំណើររបស់សម្ដេចតេជោ ហ៊ុន សែន គឺចាប់ផ្ដើមពីសាលាបឋមសិក្សាប៊ុនរ៉ានី ហ៊ុន សែន កោះថ្មនេះ។ កាលពីមុនសាលានេះ គឺជាបន្ទាយទាហាន ហើយសម្ដេចបានធ្វើដំណើរឆ្លងកាត់ព្រៃក្រាស់ មានទាំងសត្វកាចសាហាវរួមទាំងមានគ្រាប់មីនថែមទៀត។ ចេញដំណើរនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ប្រហែល ១០គីឡូម៉ែត្រ រួចធ្វើដំណើរឆ្លងព្រំដែនប្រទេសវៀតណាម។ សរុបមក គឺជាដំណើរតស៊ូដើម្បីរំដោះប្រជាជន និងប្រទេសកម្ពុជា ដោយការលះបង់សាច់ស្រស់ ឈាមស្រស់ និងចាកចេញឆ្ងាយពីក្រុមគ្រួសារប្រពន្ធកូនជាទីស្រឡាញ់របស់ខ្លួន។ យើងបានសុខសាន្តរហូតមកទល់សព្វថ្ងៃនេះ ដោយសារសម្ដេចតេជោ ហ៊ុន សែន យកអាយុជីវិតធ្វើជាដើមទុន។ កាលពីមុននៅទីនេះគ្មានភ្លើងប្រើប្រាស់ គ្មានគ្រូបង្រៀន ប៉ុន្តែឥឡូវនេះប្រទេសជាតិមានសុខសន្តិភាព ប្រទេសជាតិមានការអភិវឌ្ឍន៍ដោយសារគោលនយោបាយឈ្នះឈ្នះ។ ដូច្នេះប្អូនៗទាំងអស់ត្រូវតែខិតខំរៀនសូត្រដើម្បីកសាងប្រទេសជាតិ សង្គមជាតិយើងឲ្យមានសុខសន្តិភាពជារៀងរហូត។

ជាចុងក្រោយ ខ្ញុំសូមអរគុណដល់គ្រូខ្មែរ ឡុង ដានី និងក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនស្ដីអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងបង្ហាញរូបភាពនៅមជ្ឈមណ្ឌលឯកសារកោះថ្មដែលបានឆ្លុះបញ្ចាំងអំពីរបបខ្មែរក្រហម។ ប្រជាជនដែលរស់នៅក្រោមរបបខ្មែរក្រហមពិតជាលំបាកវេទនា។ ខ្ញុំសូមជូនពរក្រុមការងារ លោកគ្រូនាយកសាលាគណៈប្រតិភូ និងយុវជនទាំងអស់ឲ្យមានសេចក្ដីសុខចម្រើន និងខិតខំរៀនសូត្របន្ថែមទៀត។

បន្ទាប់ពីចប់វេទិកាថ្នាក់រៀនស្ដីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម យុវជនទាំង១៥០នាក់ បានធ្វើដំណើរទៅទស្សនកិច្ចសិក្សាតំបន់ប្រវត្តិសាស្ត្រតេជោ អ៊ិច-១៦ និងស្តូបវិមាន២ធ្នូ ដែលស្ថិតនៅក្នុងស្រុកស្នួល ខេត្តក្រចេះ។






នៅព្រឹកថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនស្ដីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ ដល់យុវជនកាយរិទ្ធ កាកបាទក្រហម និង ស.ស.យ.ក ចំនួន១៥០នាក់ នៅតាមសាលាមធ្យមសិក្សានៅក្នុងស្រុកចំនួនពីរគឺស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុវជនជំនាន់ក្រោយយល់ដឹងកាន់តែច្បាស់ អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅ

## របស់ខ្មែរក្រហម បន្ទាប់ពីទស្សនកិច្ចសិក្សាទីតាំងសម្លាប់មនុស្ស និងតម្កល់អដ្ឋិធាតុទួលជ្រៃ

*ភា វស្ទី*



សិស្សានុសិស្សមកពីវិទ្យាល័យមេសាងទស្សនកិច្ចទីតាំងសម្លាប់មនុស្ស និង តម្កល់អដ្ឋិធាតុទួលជ្រៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដឹកនាំសិស្សានុសិស្សចំនួន៣៣នាក់ ក្នុងចំណោមនោះស្រី១៥នាក់ ទស្សនកិច្ចសិក្សាទៅកាន់កន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហមមួយកន្លែង ស្ថិតនៅក្នុងបរិវេណវត្ត ទួលជ្រៃ ក្នុងភូមិទួលជ្រៃ ឃុំបារបោង ស្រុកពាមរក៍ ខេត្តព្រៃវែង ដែលមានចម្ងាយប្រមាណ២៥គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង តាមកំណាត់ផ្លូវជាតិលេខ១១ ឆ្ពោះទៅកាន់ទីប្រជុំជនអ្នកលឿង។ ការធ្វើទស្សនកិច្ចសិក្សានេះ គឺដើម្បីឆ្លើយតបទៅនឹងសំណួររបស់ក្មេងប្រុសម្នាក់ឈ្មោះ ហ៊ាប សំណាង ជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ មេសាង ដែលបានសួរថា «តើសកម្មភាពក្នុងរបបខ្មែរក្រហមនៅតាមមូលដ្ឋាន ពិតដូចការរៀបរាប់នៅក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែរឬទេ? សំណួរនេះបានបង្ហាញពីអារម្មណ៍និងភាពមិនទាន់ជឿជាក់ច្បាស់ក្នុងចិត្តនៅឡើយថា តើពិតជាមានអំពើព្រៃផ្សៃកើតមាននៅក្នុងរបបខ្មែរក្រហមដែរឬយ៉ាងណា។

អំឡុងពេលនោះ លោក ដេង ពង្សរ៉ាស៊ី ដែល







សិស្សានុសិស្សមកពីវិទ្យាល័យមេសាងទស្សនកិច្ចទីតាំងសម្លាប់មនុស្ស និង តម្កល់អដ្ឋិធាតុទួលជ្រៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាគ្រូខេត្តរក្នុងកម្មវិធីវេទិកាថ្នាក់រៀនចុងសប្ដាហ៍ បានពន្យល់លម្អិតទាក់ទងនឹងព្រឹត្តិការណ៍សំខាន់ៗ ដែលកើតមានក្នុងរបបខ្មែរក្រហម ព្រមទាំងបានលើកឧទាហរណ៍មួយចំនួនស្ដីពីការជួបសម្ភាសន៍ និងសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រាប់ទៅកាន់សិស្សានុសិស្ស។ ដើម្បីឲ្យយុវជនឈ្មោះ សំណាង ឈ្វេងយល់កាន់តែច្បាស់ពីរឿងរ៉ាវកើតមានក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ លោក ដេង ពង្សរ៉ាស៊ី សន្យាថានឹងនាំ សំណាង និងយុវជនទាំងអស់ ទៅជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទៅពិនិត្យមើលដោយផ្ទាល់ភ្នែកនូវទីតាំងតម្កល់អដ្ឋិធាតុជនរងគ្រោះ ដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅទួលជ្រៃ។ ក្រោយមក ក៏មានដំណើរទស្សនកិច្ចនេះឡើង ដោយមានការអញ្ជើញអ្នករស់រានមានជីវិតចំនួនប្រាំនាក់ មករៀបរាប់ពីបទពិសោធន៍របស់ខ្លួនឆ្លងកាត់របបខ្មែរក្រហម និងប្រវត្តិទីតាំងទួលជ្រៃ ដែលជាទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហម ប្រាប់ដល់សិស្សានុសិស្សទាំងនោះ។

ពេលមកដល់ទួលជ្រៃ យុវជនទាំងអស់ ខ្លះឈរ ខ្លះអង្គុយ ស្ដាប់យ៉ាងយកចិត្តទុកដាក់ចំពោះរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងឈ្វេងយល់កាន់តែច្បាស់ថែមទៀតពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅទីនេះ។ អាចារ្យវត្តទួលជ្រៃ ឈ្មោះ សុខឃាង បានរៀបរាប់យ៉ាងលម្អិតពីរឿងរ៉ាវដែលបានកើតឡើងនៅបរិវេណភូមិទួលជ្រៃតាំងពីឆ្នាំ១៩៧០ គឺក្រោយពេលកើតមានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រហូតដល់ចុងឆ្នាំ១៩៧៨។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ទៀតឈ្មោះ ឡុក រៀបរាប់ពីជីវិតដ៏លំបាកនៅក្នុងរបបខ្មែរក្រហម និងប្រាប់ពីហេតុការណ៍ដែលគាត់បានឃើញផ្ទាល់ភ្នែកនូវសាកសពមនុស្សយ៉ាងច្រើន និងរណ្ដៅសាកសពពាសពេញនៅលើទួលជ្រៃ។ ឡុក បានបន្ថែមថា លោកយាយតែងតែឃើញ

ស្រស់ៗនូវព្រលឹងសាកសពមនុស្សដែលស្លាប់នៅទួលជ្រៃ និងបានបញ្ជាក់ថាព្រលឹងទាំងនោះ ហាក់តាមថែរក្សាជីវិតរបស់គាត់ទៀតផង។ ឡុក បានមករស់នៅលើទីទួលជ្រៃដំបូងគេក្រោយឆ្នាំ១៩៧៩។ មុនដំបូងគាត់មានអារម្មណ៍ខ្លាចខ្មោចដែរ ប៉ុន្តែក្រោយមកពេលដែលគាត់ឧស្សាហ៍ឃើញវិញ្ញាណនៅនឹងភ្នែកញឹកញាប់ពេក ទើបគាត់លែងខ្លាចខ្មោចរហូតមកដល់សព្វថ្ងៃនេះ។

ចំណែក អាចារ្យវត្តទួលជ្រៃម្នាក់ទៀត ឈ្មោះ ទេព កុន បានយំសោកនៅចំពោះមុខសិស្សានុសិស្ស ដោយសារគាត់បាត់បង់សាច់ញាតិបងប្អូនរបស់គាត់ទាំងអស់នៅទួលជ្រៃនេះ។ គាត់មិនបានរៀបរាប់ច្រើនក្រៅពីនេះទេ ដោយសារតែគាត់រន្ធត់និងសោកសង្រេង។ សូមបញ្ជាក់ថា ទួលជ្រៃគឺជាទីទួលមួយដែលពុំមានមនុស្សរស់នៅឡើយកាលពីមុនរបបខ្មែរក្រហម។ មានតែផ្ទះរបស់អ្នកភូមិមួយចំនួនតូចប៉ុណ្ណោះដែលស្ថិតនៅក្បែរទីទួលនេះកាលពីរបបលន់ នល់។ នៅក្នុងរបបខ្មែរក្រហម ទីទួលនេះបានប្រែក្លាយទៅជាកន្លែងកប់សាកសពទាហាន លន់ នល់, សាកសពយោធា និងកម្មាភិបាលខ្មែរក្រហមជំនាន់សោ ភឹម និងសាកសពប្រជាជនដែលត្រូវខ្មែរក្រហមសម្លាប់ពីបទប្រព្រឹត្តកំហុសតិចតួចដូចជាលួចអាហារហូបជាដើម។

ក្រោយឆ្នាំ១៩៧៩ រណ្តៅកប់សាកសពស្ទើរតែទាំងអស់ត្រូវបានប្រជាជនគាស់ដើម្បីរកមាស និងវត្ថុមានតម្លៃដែលស្ថិតនៅជាប់នឹងខោអាវសាកសព។ ឆ្អឹងសាកសពជាច្រើនត្រូវបានលើកចេញពីរណ្តៅ និងនាំយកមកដាក់តម្កល់នៅក្នុងវត្តពាម ដែលស្ថិតនៅចម្ងាយប្រមាណពីរគីឡូម៉ែត្រពីទីទួលនេះ។ ដោយសារតែខ្វះការថែទាំ អដ្ឋិធាតុភាគច្រើន ត្រូវបានបំផ្លាញដោយសត្វពាហនៈ និងមនុស្ស ហើយអដ្ឋិធាតុមួយចំនួនតូចដែលនៅសេសសល់ ត្រូវនាំយកមកដាក់តម្កល់នៅក្នុងចេតិយមួយនៅក្នុងបរិវេណវត្តទួលជ្រៃ បន្ទាប់ពីវត្តនេះត្រូវបានកសាងឡើងនៅឆ្នាំ២០១៣។ ហ៊ាប សំណាង បានស្តាប់យ៉ាងយកចិត្តទុកដាក់។ យុវជន សំណាង ដែលកំពុងឈរនៅក្នុងចំណោមសិស្សានុសិស្សទាំង៣៣នាក់ មកពីវិទ្យាល័យ មេសាង ស្តាប់ការរៀបរាប់របស់អ្នករស់រានមានជីវិតទាំងអស់ បានសម្តែងឲ្យឃើញទឹកមុខស្រពាប់ស្រពោន មិននិយាយស្តី និងហាក់ដូចជាជឿជាក់លើពាក្យសម្តីពិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះ។ អាចារ្យ សុខ ឃាង បានបញ្ជាក់ថា រឿងរ៉ាវដែលគាត់ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាននិយាយនៅពេលនេះ គឺជារឿងរ៉ាវពិតដែលបានកើតមានចំពោះអ្នកភូមិទួលជ្រៃប្រាកដមែន។ លោកបន្តថា អ្នកភូមិទាំងអស់ដែលមានវ័យចំណាស់ៗ គឺសុទ្ធសឹងតែមានប្រវត្តិរឿងរ៉ាវស្រដៀងគ្នាចំពោះការបាត់បង់សមាជិកគ្រួសារនៅក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីអ្នករស់រានមានជីវិតទាំងអស់បញ្ចប់ការចែករំលែករឿងរ៉ាវជីវិតរបស់ខ្លួនរួចមក យុវជនទាំងអស់ត្រូវបាននាំទៅកាន់ចេតិយមួយកន្លែងស្ថិតនៅភាគខាងត្បូងព្រះវិហារ។ ទីនោះគឺជាកន្លែងតម្កល់អដ្ឋិធាតុដែលនៅសេសសល់បន្តិចបន្តួច។ លោក សុខ ឃាង បានពន្យល់ដល់ក្មេងៗទាំងអស់ពីដើមហេតុដែលនាំឲ្យមានការនាំយកអដ្ឋិធាតុមកតម្កល់នៅទីនេះ និងបានប្រាប់ថា ជារៀងរាល់ឆ្នាំឲ្យតែមានពិធីបុណ្យផ្សេងៗ គឺមានប្រជាជនរស់នៅជុំវិញបរិវេណទួលជ្រៃ និងប្រជាជនមកពីទីជិតឆ្ងាយចូលមកធ្វើបុណ្យដើម្បីឧទ្ទិសកុសលជូនសាច់ញាតិដែលបានស្លាប់នៅទីនោះ។



សិស្សានុសិស្សមកពីវិទ្យាល័យមេសាងទស្សនកិច្ចទីតាំងសម្លាប់មនុស្ស និងតម្កល់អដ្ឋិធាតុទួលជ្រៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ទស្សនកិច្ចសិក្សាស្តីអំពី «សន្តិភាព និងសិទ្ធិមនុស្ស» នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

ស្ងួត វិចិត្រ



នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី«សន្តិភាព និងសិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្តីអំពី«សន្តិភាព និងសិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣។ ទស្សនកិច្ចសិក្សានេះ មានគោលបំណងលើកកម្ពស់ការយល់ដឹងទៅលើផ្នែកប្រវត្តិសាស្ត្រដល់យុវជនការកសាងសន្តិភាព និងការផ្សះផ្សា។

បណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើការសម្របសម្រួល និងធ្វើបទបង្ហាញទៅកាន់សិស្សានុសិស្ស ដោយផ្តោតសំខាន់ទៅលើបរិបទប្រវត្តិសាស្ត្រជុំវិញការកកើតរបបខ្មែរក្រហម សោកនាដកម្មក្រោមអំពើឃោរឃៅ និងការបិទបញ្ចប់នូវទំព័រប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា។ បណ្ឌិត លី សុខឃាង ក៏បានលើកយកនូវប្រវត្តិសាស្ត្រតំបន់អន្លង់វែងមកធ្វើការពិភាក្សា និងឆ្លុះបញ្ចាំងដល់សិស្សានុសិស្សអំពីវត្តមានរបស់មេដឹកនាំខ្មែរក្រហមនៅតាមព្រំដែន និងព្រឹត្តិការណ៍ចុងក្រោយនៃជម្លោះផ្ទៃក្នុងរវាងមេដឹកនាំខ្មែរក្រហមនៅតំបន់អន្លង់វែង។ ក្នុងឱកាសនោះ សិស្សានុសិស្សបានចោទសួរសំណួរមួយចំនួនហេតុអ្វីបានជាមេដឹកនាំខ្មែរក្រហមប្រមូលផ្តុំគ្នានៅតំបន់អន្លង់វែង? ហេតុអ្វីបានជា តាម៉ុក និង ប៉ុល ពត ដែលជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមានជម្លោះនឹងគ្នារហូត

ដល់បែកបាក់គ្នា និងមានសង្គ្រាម? បន្ទាប់មក សិស្សានុសិស្សនាំគ្នាទស្សនាពិព័រណ៍ស្ដីពី«សង្គ្រាម និងអំពើប្រល័យពូជសាសន៍» ដែលដាក់តាំងបង្ហាញនៅការិយាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ព្រមទាំងទីតាំងប្រវត្តិសាស្ត្រមួយចំនួនទៀត ដូចជា ទីតាំងបូជាសព ប៉ុល ពត, ទីតាំងបូជាសព សុន សេន និងក្រុមគ្រួសារ, ចេតិយតាម៉ុក និងសារមន្ទីរតាម៉ុក ដើម្បីយល់ដឹងថា តើនៅពេលចលនាខ្មែរក្រហមបានដុតរលត់ទៅ រឿងរ៉ាវនិងកស្តុតាងសេសសល់នៅសហគមន៍អន្លង់វែងបានបង្រៀន និងផ្ដះបញ្ចាំងដល់យុវជនយ៉ាងដូចម្ដេចខ្លះ? ទស្សនកិច្ចសិក្សានេះបានបញ្ចប់នៅពេលរសៀល។

ខឿន សុម៉ារី សិស្សថ្នាក់ទី១០ និងជាប្រធានក្រុមដឹកនាំសិស្សានុសិស្សមកទស្សនកិច្ចបានបង្ហាញចំណាប់អារម្មណ៍ និងយល់ឃើញថា «នេះជាលើកទីមួយរបស់ខ្ញុំដែលបានសិក្សាឈ្វេងយល់ពីប្រវត្តិ-សាស្ត្រនៅតំបន់អន្លង់វែង គឺជាទីកន្លែងដែលយើងមិនគួរមើលរំលង។ ក្នុងនាមខ្ញុំជាយុវជន ខ្ញុំគិតថាការរៀនសូត្រពីដើមចមនៃការកកើតប្រវត្តិសាស្ត្រខ្មែរក្រហម គឺពិតជាមានសារសំខាន់ខ្លាំងណាស់។ ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំទទួលបាននៅក្នុងថ្ងៃនេះ ខ្ញុំនឹងចែករំលែកបន្តទៅកាន់មិត្តភក្តិផ្សេងទៀត ដើម្បីរួមចំណែកដល់ការអប់រំនៅក្នុងសង្គម ជាពិសេសគឺទប់ស្កាត់របបនេះកុំឲ្យកើតឡើងម្ដងទៀត»។

សុន ស្រីមួយ យល់ឃើញថា «ការលើកស្ទួយវិស័យអប់រំ និងជំរុញឲ្យប្រទេសមានការអភិវឌ្ឍន៍ទៅមុខគឺធ្វើឲ្យការកកើតអំពើប្រល័យពូជសាសន៍មានកម្រិតទាប។






នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានរៀបចំទស្សនកិច្ចសិក្សាស្ដីអំពី«សន្តិភាព និងសិទ្ធិមនុស្ស» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៤០នាក់ មកពីវិទ្យាល័យ ហ៊ុន សែន ត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# សិស្សវិទ្យាល័យបឹងព្រះសិក្សាអំពី «ទំនាក់ទំនងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ» នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

*ភា វស្នី*



លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង កំពុងបង្រៀនសិស្សវិទ្យាល័យបឹងព្រះអំពី «ទំនាក់ទំនងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ»។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ទំនាក់ទំនងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យ» រយៈពេលពីរថ្ងៃ គឺពីថ្ងៃទី៨ ដល់ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣ ដោយមានការចូលរួមពីសិស្សានុសិស្សមកពីវិទ្យាល័យបឹងព្រះ ចំនួន៥១នាក់ (ស្រី៤១នាក់ និងប្រុស ១០នាក់)។ ជាកិច្ចចាប់ផ្តើមវេទិកា សិស្សានុសិស្សទាំងអស់បានពិភាក្សាពីចម្ងល់នានាដែលខ្លួនមានទាក់ទងនឹងប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យជាមួយលោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។

សំណួរសំខាន់ដែលសិស្សបានសួរមានដូចខាងក្រោម៖

១) ហេតុអ្វីបានជារបបសក្តិភូមិប្រឆាំងជាមួយកម្មុយនីស្ត?

២) តើកត្តាអ្វីខ្លះដែលធ្វើឲ្យខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥?

៣) តើការឡើងកាន់អំណាចរបស់ខ្មែរក្រហម ទាក់ទងជាមួយព្រះបាទ នរោត្តម សីហនុ ដែរឬទេ?

៤) ហេតុអ្វីបានជាប្រជាពលរដ្ឋខ្មែរចូលព្រៃម៉ាគីតាមការឃោសនារបស់សម្តេចឪ?

៥) តើព្រៃម៉ាគីគឺជាអ្វី?

៦) ហេតុអ្វីបានជាខ្មែរក្រហមស្អប់វៀតណាម?

៧) ហេតុអ្វីបានជា សា ឡុត ស សម្លាប់បងប្អូនជនរួមជាតិខ្មែររហូតដល់ជាង២លាននាក់?

៨) ឧត្តមសេនីយ៍ លន់ នល់ និង ប៉ុល ពត គឺជាមនុស្សស្អប់យួនដូចគ្នា។ ហេតុអ្វីបានជាអ្នកទាំងពីរមិនរួបរួមគ្នាដឹកនាំប្រទេស?

៩) តើការឡើងកាន់អំណាចរបស់ខ្មែរក្រហម និងការដួលរលំរបស់ខ្មែរក្រហម គឺជាផែនការរបស់វៀតណាមឬយ៉ាងណា?

១០) តើប៉ុល ពត ជាបុគ្គលស្នេហាជាតិឬក៏ក្បត់ជាតិ?

១១) តើ សុន សេន គឺជានរណា? មកពីណា?

បន្ទាប់ពីស្វែងរកចម្លើយចេញពីមាតិកាប្រវត្តិសាស្ត្ររួច លោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញជំពូក ទី១១៖ «ទំនាក់ទំនងការបរទេស» នៃសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ លោកផេង ពង្សរ៉ាស៊ី សង្ខេបថា របបកម្ពុជាប្រជាធិបតេយ្យមានចំណងមិត្តភាពជាមួយប្រទេសចិន ប្រទេសកូរ៉េខាងជើង ប្រទេសវៀតណាម ឡាវ រ៉ូម៉ានី យូហ្គោស្លាវី អាល់បានី និងអេហ្ស៊ីប។ ដោយឡែកប្រទេសចិនគឺជាប្រទេសតែមួយគត់ដែលមានសិទ្ធិដើរ ហើយច្រើនជាងស្ថានទូតនានាប្រចាំនៅកម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៧៨ របបកម្ពុជាប្រជាធិបតេយ្យ បានពង្រីកទំនាក់ទំនងការបរទេសរបស់ខ្លួនជាមួយបណ្ដាប្រទេសមួយចំនួនទៀត ដូចជា ប្រទេសថៃ ជប៉ុន សាំងហ្គាពួរ ម៉ាដាហ្គាស្កា កូរ៉េខាងត្បូង ហុងកុង និងបង់ក្លាដេស ដើម្បីពង្រីកការនាំចេញវិស័យកសិកម្ម និងឧស្សាហកម្ម ហើយខ្មែរក្រហមបាននាំចូលមកវិញនូវគ្រឿងសព្វាវុធ រថក្រោះ និងគ្រឿងចក្រសម្រាប់បម្រើក្នុងវិស័យកសិកម្ម។ លើសពីនេះទៀត ចិនបានជួយជួសជុលផ្លូវរថភ្លើងពីភ្នំពេញទៅកំពង់សោម និងជួយសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។ នៅក្នុងជំពូកនេះ ចិនក៏បានផ្ដល់អនុសាសន៍ឲ្យខ្មែរក្រហមធ្វើការចរចា និងឈប់បាញ់មួយជាមួយវៀតណាម ក្នុងពេលដែលខ្មែរក្រហមស្នើចិនឲ្យជួយខ្លួនក្នុងការប្រយុទ្ធប្រឆាំងទល់នឹងវៀតណាម។ កម្ពុជាប្រជាធិបតេយ្យបានប្រានបោលសំណើររបស់ចិន ហើយបានបន្តធ្វើសង្គ្រាមជាមួយវៀតណាម។

នៅខែមករា ឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យបានចាញ់សង្គ្រាម និងបានបាត់បង់ការគ្រប់គ្រងប្រទេសរហូតដល់បច្ចុប្បន្ន។ ដើម្បីជាជំនួយដល់ការសិក្សាមេរៀននេះ លោក ផេង ពង្សរ៉ាស៊ី បានចាក់បញ្ចាំងខ្សែភាពយន្តឯកសារខ្លីមានចំណងជើង «ទំនាក់ទំនងចិន និងរបប ប៉ុល ពត ខ្មែរក្រហម»។

នៅចុងបញ្ចប់នៃវេទិកាថ្នាក់រៀនចុងសប្ដាហ៍ គឺការវាស់ស្ទង់ចំណេះដឹងរបស់សិស្សដែលបានចូលរួមវេទិកានៅថ្ងៃនេះ។ សំណួរចំនួនពីរត្រូវបានសួរទៅកាន់សិស្សគឺ សំណួរទី១) តើប្អូនរៀនអ្វីខ្លះអំពីទំនាក់ទំនងការបរទេសកម្ពុជាប្រជាធិបតេយ្យ? សំណួរទី២) តើប្អូនយល់យ៉ាងដូចម្ដេចចំពោះទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យ និងចិន?

**ខាងក្រោមនេះ ជាចម្លើយរបស់សិស្សម្នាក់ៗ ៖**

**១) សុខ សាចចក្រ**



ខ្ញុំឈ្មោះ សុង សាចចក្រ ភេទប្រុស មានអាយុ១៨ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យបឹងព្រះ។ ខ្ញុំបានដឹងពីទំនាក់ទំនងយ៉ាងស្អិតស្អាលរវាងកម្ពុជាប្រជាធិបតេយ្យ និងចិន។ ចិនបានជួយជួសជុលផ្លូវរថភ្លើងពីភ្នំពេញទៅកំពង់សោម។ ចិនបានជួយសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ព្រមទាំងផ្ដល់ជំនួយឲ្យកម្ពុជានូវគ្រឿងសព្វាវុធរថក្រោះបច្ចេកទេស និងគ្រឿងបរិក្ខាពេទ្យ។ ចំពោះទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យនិងចិន ខ្ញុំយល់ថាប្រទេសទាំងពីរល្អចំពោះគ្នាទៅវិញទៅមក ប៉ុន្តែមិនល្អទាំងអស់នោះទេ។ មានចំណុចខ្វះខាតមួយចំនួនត្រង់ថា ចិនមិនយល់ស្របក្នុងការបញ្ជូនកងទ័ពរបស់ខ្លួនជួយច្បាំងជាមួយវៀតណាម។ ចិនបានស្នើសុំមកវិញឲ្យកម្ពុជាមានការចរចា និងមានបទឈប់បាញ់គ្នា ប៉ុន្តែ ប៉ុល ពត បានខឹងនិងបានប្រានបោលសំណើរនេះ។ កម្ពុជាប្រជាធិបតេយ្យបានដឹកនាំទ័ពចេញច្បាំងរហូតដល់ចាញ់សង្គ្រាមជាមួយវៀតណាម។

## ២) មឿន មុន្នីរតនា



ខ្ញុំឈ្មោះ មឿន មុន្នីរតនា ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យបឹងព្រះ។ បន្ទាប់ពីបានសិក្សាពីមេរៀនដែលលោកគ្រូបានបង្រៀនមក ខ្ញុំបានដឹងថារបបកម្ពុជាប្រជាធិបតេយ្យមានទំនាក់ទំនងការទូតជាមួយប្រទេសចំនួន៨ និងមានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសចំនួន៩។ ទំនិញដែលកម្ពុជានាំចេញនាសម័យនោះ រួមមាន ស្រូវ ជ័រ កៅស៊ូ ឈើ និងសរីរាង្គសត្វដីកម្រ មានស្បែក ភ្លុក និងស្នែក។ ចំណែកទំនិញដែលនាំចូលមកវិញរួមមាន គ្រឿងសព្វាវុធ រថក្រោះ កាំភ្លើងធំ ម៉ាស៊ីនសម្រាប់ធ្វើស្រែចម្ការ ផលិតផលគីមី និងក្រណាត់។ កម្ពុជាប្រជាធិបតេយ្យទទួលបានជំនួយជាច្រើនពីចិន ហើយ ទំនាក់ទំនងរវាងកម្ពុជា និងចិនកាន់តែមានភាពស្អិតរមួត។ ចំណែកទំនាក់ទំនងជាមួយកម្ពុជាវៀតណាមកាន់តែអាក្រក់ទៅៗ។ ចិនបានផ្ដល់ជំនួយមកកម្ពុជាប្រជាធិបតេយ្យដោយការកសាងព្រលានយន្តហោះនៅកំពង់ឆ្នាំង និងបញ្ជូនអ្នកបច្ចេកទេសមកបង្រៀនដល់កម្ពុជា។ ចំពោះទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យនឹងចិន ខ្ញុំគិតថាល្អ ព្រោះចិនបានជួយដល់ខ្មែរច្រើន។ មួយវិញទៀត ចិន មិនចង់ឲ្យកម្ពុជាមានជម្លោះជាមួយវៀតណាមឡើយ ព្រោះចិនដឹងថាប្រទេសកម្ពុជាមិនអាចយកឈ្នះប្រទេសវៀតណាម។

## ៣) សាក់ និមល



ខ្ញុំឈ្មោះ សាក់ និមល ភេទស្រី អាយុ១៨ឆ្នាំ រៀនថ្នាក់ទី១២C នៃវិទ្យាល័យបឹងព្រះ។ ខ្ញុំបានយល់ដឹងអំពីរបប ប៉ុល ពត និងយល់ដឹងពីការរស់នៅរបស់ប្រជាជន។ ខ្មែរក្រហមមានទំនាក់ទំនងជាមួយបណ្ដាប្រទេសចំនួន៨។ ចិនបានផ្ដល់ជំនួយមកដល់ខ្មែរ ធ្វើឲ្យខ្មែរនិងចិនមានទំនាក់ទំនងល្អនឹងគ្នា។ ខ្មែរបានស្នើសុំកងទ័ពពីចិន ប៉ុន្តែចិនបានពន្យាពេល និងសុំឲ្យមានការចរចា ដែលជាហេតុធ្វើឲ្យខ្មែរក្រហមចាញ់សង្គ្រាម។ ចំពោះទំនាក់ទំនងរវាងកម្ពុជាប្រជាធិបតេយ្យនិងចិន ខ្ញុំយល់ថាចិនបានធ្វើឲ្យខ្មែរក្រហមមានមហិច្ឆិតាលោភលន់ដោយអាងចិននៅពីក្រោយ។

## ៤) សៅ ឌួប



ខ្ញុំឈ្មោះ សៅ ឌួប ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២A នៃវិទ្យាល័យបឹងព្រះ។ ចិនបានផ្ដល់នូវគ្រឿងសព្វាវុធដល់កម្ពុជាដូចជា គ្រាប់ផ្លោង គ្រាប់កាំភ្លើងរាប់តោន ហើយចិនបានផ្ដល់កម្លាំងចិត្តឲ្យខ្មែរក្រហមកាន់តែមានទំនុកចិត្តលើខ្លួនឯង។ ចំពោះទំនាក់ទំនងកម្ពុជាចិន គឺចិនបានផ្ដល់នូវការទុកចិត្តចំពោះខ្មែរក្រហមហើយខ្មែរក្រហមក៏បានពេញចិត្តចំពោះជំនួយរបស់ចិនផ្ដល់ឲ្យយ៉ាងច្រើនដែរ។ ខ្មែរក្រហមមានចិនដែលជាអ្នកគាំទ្រ ធ្វើឲ្យខ្មែរក្រហមហ៊ានធ្វើអ្វីៗគ្រប់យ៉ាង។

## ៥) ឈន់ សីលា



ខ្ញុំឈ្មោះ ឈន់ សីលា ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យបឹងព្រះ។

មេរៀនទំនាក់ទំនងកម្ពុជាចិន ដែលខ្ញុំបានរៀនរួមមានឥទ្ធិពលសង្គមរបស់ចិនមកលើកម្ពុជា។ ចិនគឺជាកម្លាំងមួយយ៉ាងសំខាន់សម្រាប់ភាពរឹងមាំនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ចិនជួយបានតែខាងអាវុធយុទ្ធភ័ណ្ឌ ប៉ុន្តែចិនមិនបានយកចិត្តទុកដាក់ចំពោះប្រជាជនកម្ពុជាដែលរងគ្រោះឡើយ។

# សិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប សិក្សាអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)»

## នៅមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម

ទូច វណ្ណេត



សិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដោយផ្តោតទៅលើប្រធានបទ «ការធ្វើការងារជាទម្ងន់នៅការដ្ឋានទំនប់ក្នុងរបបខ្មែរក្រហម» និងដំណើរទស្សនកិច្ចសិក្សាទៅកាន់ទីតាំងទំនប់ខ្មែរក្រហម ដោយមានការចូលរួមពីសិស្សចំនួន៥៥នាក់មកពីវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប។ វេទិកាថ្នាក់រៀននេះបង្កើតឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់សិស្សានុសិស្សអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការយល់ដឹងអំពីបទពិសោធន៍របស់ប្រជាជនដែលធ្វើការនៅតាមទំនប់ប្រឡាយក្នុងរបបខ្មែរក្រហម។

សិស្សដែលមកចូលរួមទាំងអស់ ត្រូវបានទទួលស្វាគមន៍ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងដឹកនាំទៅទស្សនាពិព័រណ៍រូបថតដែលដាក់តាំងបង្ហាញនៅខាងមុខបរិវេណមជ្ឈមណ្ឌល។ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារ





សិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខេត្តកំពង់ចាម បានពន្យល់អំពីផ្ទាំងពិព័រណ៍ទាំងនេះ រួមមាន ប្រវត្តិមេដឹកនាំខ្មែរក្រហម ការជម្លៀសប្រជាជន និងការធ្វើការងារនៅការដ្ឋាន និងទំនប់ៗ លោក ស៊ាង ចិន្តា បន្តដឹកនាំសិស្សទាំងអស់ទៅក្នុងសាលពិព័រណ៍នៅខាងក្នុងដែលមានការដាក់តាំងបង្ហាញព្រះឆាយាល័ក្ខណ៍ចំនួន១៨ផ្ទាំង ដែលជាផ្នែកមួយនៃពិព័រណ៍ "ក្តីសុបិនកម្ពុជា" ដែលត្រូវបានដាក់តាំងបង្ហាញដោយ «បណ្ណាល័យសម្តេចម៉ែ» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ បន្ទាប់មក សិស្សទាំងអស់ត្រូវបាននាំទៅកាន់បណ្ណាល័យខ្មែរក្រហមដែលមានតម្កល់សៀវភៅទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម និងបន្ទប់តម្កល់ឯកសារខ្មែរក្រហម។

ជាកិច្ចបន្ត លោក ស៊ាង ចិន្តា បានធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលផ្តោតសំខាន់ទៅលើ «ការធ្វើការងារជាទម្ងន់នៅការដ្ឋានទំនប់ក្នុងរបបខ្មែរក្រហម»។ នៅក្នុងឱកាសនោះ លោក ស៊ាង ចិន្តា បានចាក់បញ្ចាំងវីដេអូអំពីការធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ៗ បន្ទាប់មក លោក ស៊ាង ចិន្តា លើកឡើងអំពីនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងអំពើប្រល័យពូជសាសន៍ៗ ក្នុងអំឡុងពេលនៃការធ្វើបទបង្ហាញ សិស្សបានចោទសួរសំណួរទៅកាន់វាគ្មិនដើម្បីបកស្រាយចម្ងល់របស់ខ្លួនៗ មុនពេលបញ្ចប់បទបង្ហាញ លោក ស៊ាង ចិន្តា បានចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)» ជាភាសាខ្មែរ បោះពុម្ពលើកទី២ និងទស្សនាវដ្តីស្វែងរកការពិតដល់សិស្ស ដើម្បីទុកអាន និងសិក្សាបន្ថែមៗ

កម្មវិធីបន្ទាប់ គឺការចុះទៅទស្សនកិច្ចចេតិយរំឭកសម្រាប់សហគមន៍ស្ថិតនៅវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម និងទីតាំងទំនប់៥កុម្ភៈ ដែលត្រូវបានសាងសង់ក្នុងរបបខ្មែរក្រហម។ ។ នៅពេលទៅដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ សិស្សទាំងអស់បានជួបសន្ទនាផ្ទាល់ជាមួយ លោក គុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ លោក គុង សុភា តំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បានចែករំលែកបទពិសោធន៍ជីវិតផ្ទាល់ខ្លួន និងការសម្លាប់ប្រជាជននៅក្នុងឃុំគគរក្នុងរបបខ្មែរក្រហមទៅកាន់សិស្ស។ លោក គុង សុភា បានបាត់បង់ឪពុក និងតែងតែនឹករឭកដល់ឪពុកដែលត្រូវបានខ្មែរក្រហមចាប់យកទៅសម្លាប់។ ជំនួបសន្ទនាផ្ទាល់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅចេតិយរំឭកនេះបង្កើតឱកាសដល់សិស្សឈ្វេងយល់ដោយផ្ទាល់ពីបទពិសោធន៍ និងការចងចាំរបស់អ្នករស់រានមានជីវិតក្នុងមូលដ្ឋាន និងអាចសួរសំណួរដែលខ្លួនចង់ដឹងទាក់ទងនឹងរឿងរ៉ាវកើតឡើងក្នុងរបបខ្មែរក្រហម។

បន្ទាប់មក សិស្សបានបន្តចុះទៅកាន់ទីតាំងទំនប់៥កុម្ភៈ ស្ថិតនៅភូមិថ្មលំបែកកើត ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។ ទំនប់៥កម្ភៈ ត្រូវបានសាងសង់ក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ដើម្បីស្តុកទឹកទុកបញ្ចូលស្រែនៅរដូវប្រាំង។ ប្រជាជនត្រូវបានចល័តមកលើកទំនប់ និងទទួលរងការធ្វើការងារហួសកម្លាំង គ្មានអាហារហូបគ្រប់គ្រាន់ និងធ្លាក់ខ្លួនឈឺដោយគ្មានថ្នាំព្យាបាល។

ជឿន មីងហ័ង រៀនថ្នាក់ទី១១នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប លើកឡើងថា បន្ទាប់ពីខ្ញុំបានចូលរួមវេទិកាថ្នាក់រៀននេះ «ខ្ញុំបានទទួលចំណេះដឹង និងបទពិសោធន៍ថ្មីៗអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ វេទិកានេះបានធ្វើឲ្យខ្ញុំដឹងថា ប្រទេសកម្ពុជាបានឆ្លងកាត់វិនាសកម្មនៃសង្គ្រាម និងរបបប្រល័យពូជសាសន៍ខ្មែរក្រហមដែលបានបណ្តាលឲ្យប្រជាជនរស់នៅលំបាក និងស្លាប់បាត់បង់ជីវិត។ ខ្ញុំយល់អំពីតម្លៃនៃសន្តិភាព»។

ស្រេង លៀងស្រ៊ុង រៀនថ្នាក់ទី១១នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប រៀបរាប់ថា «ការចូលរួមវេទិកាថ្នាក់រៀននេះបានធ្វើឲ្យខ្ញុំយល់ដឹងបន្ថែមលើមេរៀនប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំឃើញរូបភាពឯកសារជាច្រើន។ ខ្ញុំមិនសប្បាយចិត្តពេលឃើញប្រជាជនត្រូវបានបង្ខំឲ្យធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់ និងគ្មានអាហារហូបចុកគ្រប់គ្រាន់។ ខ្ញុំបានចុះទៅកាន់ទីតាំងទំនប់៥កុម្ភៈដោយផ្ទាល់ ដែលជាទីកន្លែងប្រជាជនត្រូវបានដាក់ឲ្យធ្វើការជាទម្ងន់ ប៉ុន្តែបច្ចុប្បន្នគឺជាអាងស្តុកទឹក និងជាកន្លែងលេងកម្សាន្តក្នុងស្រុកចំការលើ»។

ញ៉ែម ស្រីកែវ រៀនថ្នាក់ទី១២នៃវិទ្យាល័យសម្តេចតេជោ ហ៊ុនសែន សង្កើបឲ្យដឹងថា «ខ្ញុំយល់ថាការរៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅចុងសប្តាហ៍នេះ គឺល្អសម្រាប់ខ្ញុំ និងមិត្តភក្តិផ្សេងទៀតដែលកំពុងរៀនថ្នាក់ទី១២។ ខ្ញុំទទួលចំណេះដឹងថ្មីចេញពីការពន្យល់របស់លោក ស៊ាង ចិន្តា ការស្តាប់ពីបទពិសោធន៍ និងការបាត់បង់ឪពុករបស់អ៊ំ គុងសុភា និងការចុះទៅកាន់ទីតាំងទំនប់ដោយផ្ទាល់។ ខ្ញុំនឹងនាំយកចំណេះដឹង និងបទពិសោធន៍ដែលខ្ញុំទទួលបានទៅចែករំលែកជាមួយមិត្តភ័ក្តិផ្សេងទៀត និងចូលរួមការពារកុំឲ្យរបបនេះវិលមកវិញម្តងទៀត»។



សិស្សវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន សង្កើប ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)
















# បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាកន្លែងប្រមូលផ្តុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ធនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យកងពលតូចថ្មើរជើងលេខ ៨១

បណ្ណាល័យប្រវត្តិសាស្ត្រយោធា ស្ថិតនៅក្នុងកងពលតូចថ្មើរជើងលេខ ៨១ ក្នុងស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ។

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានទីតាំងនៅភូមិអូរចំណៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពី ថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង២៖០០ដល់ម៉ោង៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង តាមរយៈទូរសព្ទលេខ៖ ០១២ ៥៧០ ៨៦៥ ឬ អ៊ីម៉ែល ៖
truthlysokkheang@dccam.org
សូមអរគុណ!











# «ទួលពិឃាដ» (ត)

# ១៣. ឆាកជីវិតក្រោយព្យុះសង្គ្រាបដិវត្តន៍ (ត)

## ព្រលឹងឪពុកម្ដាយនាំផ្លូវលើទួលយោគ

ខ្ញុំចេញដំណើរទៅទៀតហើយជិះលើខ្នងក្របីសំដៅទៅដើមប្រទៀងតាកុកៗ ចេញពីភូមិមានក្មេងជាច្រើនដែរទៅចាំទីនោះ។

មកដល់ខ្ញុំព្រលែងខ្សែអង្កត់ចេញពីកន្ទុះក្របី ហើយវាក៏ចូលទៅក្នុងព្រៃនាំមដើរស៊ីល្បាស់ព្រិចៗ ពួកយើងជាអ្នកគង្វាលគោក្របីបាននាំគ្នាឡើងលេងដើមប្រទៀងតាកុក ខ្លះដើរបេះផ្លែដង្កៀបក្ដាមនិងភ្នំភ្លែង ខ្លះដកដើមទាល់ និងដើរបាចត្រីតាមថ្លុកក្របីបុកតាមបៀររណ្ដៅគ្រាប់បេ៥២។

ថ្ងៃរសៀលជ្រាលជ្រេហើយ សត្វគោក្របីទាំងឡាយបានចេញពីព្រៃល្បាស់ ហើយម្ចាស់គេទាំងឡាយបានដឹកត្រឡប់ទៅភូមិវិញ។ គោក្របីពួកគេបានចេញពីព្រៃមកអស់នៅឡើយតែក្របីខ្ញុំមិនទាន់ចេញមក។ ពួកគេបានស្រែកមកខ្ញុំថា “អាវង្ស គ្នាទៅភូមិមុនហើយ” ខ្ញុំបានឆ្លើយថា “អុឺ! ទៅមុនចុះព្រោះក្របីខ្ញុំមិនទាន់ចេញពីព្រៃមកទេ”។

រង់ចាំវាយ៉ាងយូរមិនឃើញចេញមកទៀត ខ្ញុំមើលទៅពួកគេចូលភូមិអស់ហើយ ខ្ញុំគិតថា ចម្លែកម្ល៉េះថ្ងៃនេះម្ដេចក្របីខ្ញុំក្រចេញពីព្រៃម្ល៉េះ។

ថ្ងៃចាប់ផ្ដើមលិចបន្តិចម្ដងៗមេឃស្រទំខ្ញុំរសាប់រសល់ក៏ឡើងដើមប្រទៀងតាកុក មើលទៅក្នុងព្រៃមិនឃើញអ្វីសោះ ពុំតែសត្វព្រៃយំទ្រហឹងអឹងកងៗ មេឃក៏ងងឹតរកភ្លៀង ខ្ញុំមានអារម្មណ៍ចាប់ផ្ដើមភ័យខ្លាចព្រោះមានតែម្នាក់ឯងក្បែរមាត់ព្រៃស្ងាត់ជ្រងំ។ មេឃកាន់តែងងឹតខ្លាំងឡើងៗ ខ្ញុំអស់សង្ឃឹមថាក្របីប្រាកដជាត្រូវគេលួចបាត់ហើយ ព្រោះខ្ញុំធ្លាប់ដឹងថាអ្នកភូមិខ្លះបាត់ក្របីនិងគោនៅព្រៃស្ទឹងនេះ ព្រោះគោក្របីមានតម្លៃថ្លៃជាងមាស។

ខ្ញុំអស់សង្ឃឹមក្នុងខ្លួនល្ហិតល្ហៃដើង នឹកក្នុងចិត្តថាប្រាកដជាបង និងតាយាយស្ដីបន្ទោសយ៉ាងខ្លាំងមិនខាន។ ព្រោះគាត់បានយករបស់មានតម្លៃ និងជាកេរមរតករបស់ឪពុកម្ដាយមកដូរនឹងក្របីនេះ។ ម្យ៉ាងទៀតយើងពិតជាមិនមានអ្វីធ្វើស្រែបន្តទៀតទេ។ ក្នុងចិត្តអស់រលីងអ្វីៗពីក្នុងខ្លួន ទន់ខ្លួនល្វើយ ព្រោះក្របីមិនអាចស៊ីល្បាស់ក្នុងព្រៃហួតយប់ងងឹតដូច្នេះឡើយ។ ទឹកភ្នែកខ្ញុំចាប់ផ្ដើមហូរនឹកស្ដាយក្របីរបស់មានតម្លៃស្មើជីវិត ហើយដើរមកកាន់ទួលយោគ។ ខ្ញុំមើលខ្សែនិងកឡាប៊ីស្ពាយជាប់ខ្លួនចង់និយាយថា “ខ្សែអ្នកមិនមានអ្វីចងទៀតទេ កឡាប៊ីអ្នកមិនមានក្របីលាងទៀតឡើយ”។

ដើរមកដល់ចុងទួលយោគខាងកើត សម្លឹងរកមើលក្របីលើកចុងក្រោយ តែមេឃងងឹតខ្លាំងពេក ផ្លេកបន្ទោរនិងផ្គរលាន់រន្ទះខ្លាំងៗ។ នឹកមិនអស់ចិត្តខ្ញុំដើរថយក្រោយវិញ ដប់ម្ភៃជំហានមករកដើមចារមួយក្បែរនោះ រួចក៏ឡើងទៅដល់ចុងសម្លឹងមើលទៅក្នុងព្រៃស្ទឹងតាមពន្លឺផ្លេកបន្ទោរម្ដងៗ តែមិនឃើញអ្វីទាំងអស់។

មេឃជិតភ្លៀងហើយ ខ្យល់បក់មកខ្លាំង មើលទៅលើគ្របដណ្ដប់ដោយពពកខ្មៅងងឹតក្រាស់ឃ្មឹកចាក់ភ្នែកស្រែះមើលអ្វីពុំយល់។ ខ្ញុំចុះមកដល់ក្រោមដើមចារមើលទៅក្នុងព្រៃរនាមចុងក្រោយដោយអស់សង្ឃឹម។ សំឡេងឆ្កែចចកលូចេញពីព្រៃខ្ញុំព្រឺក្បាលខ្វាកៗ ខ្ញុំដើរសំដៅមកចុងទួលយោគយ៉ាងលឿន សំឡេងឆ្កែចចកលូជិតទៅៗ។ ខ្ញុំអស់សង្ឃឹមក៏ដើរចូលទួលយោគ។ មេឃចាប់ផ្ដើមភ្លៀងបង្អុរមកយ៉ាងខ្លាំងដូចជះទឹក។

គ្រាប់ភ្លៀងធ្លាក់មកនិងខ្យល់ខ្លាំងណាស់មិនអាចឲ្យខ្ញុំទៅមុខបានទេ ឃើញកូនគ្រោតមួយមានស្លឹកស៊ុបទ្រុប ទាញធាងគ្រោតមកគ្របពីលើ ងាកមកមើលព្រៃម្ដងៗខ្លាចឆ្កែចចក។ រួចសម្លឹងមើលទៅទួលស្លាំងឃើញភ្លើងពណ៌ស្វាយហោះចេញពីទួល។

ពេលនោះខ្ញុំពិតជាខ្លាចព្រឺក្បាលមែនទែន ព្រោះខ្ញុំមកចាំគោតែងតែឮចាស់ៗតំណាលនូវរឿងខ្មោចលងថា នៅពេលយប់បើសិនជាឃើញភ្លើងហោះចេញពីចេតិយ ឬផ្នូរខ្មោចនោះ

ពិតជាភ្លើងខ្មោចព្រាយបិសាចហោះចេញរកចំណី។ ខ្ញុំពិតជាខ្លាចព្រឺសម្បុរខ្វាក់ៗ បះសក់ម្ដងៗ ក្នុងចិត្តគិតរវើរវាយលែងរស់ហើយ។

ពេលមុនខ្លាចកងឈ្លបខ្មែរក្រហមតាមសម្លាប់ តែពេលនេះខ្លាចខ្មោចព្រាយបិសាចលងវិញម្ដងៗ។ ខ្ញុំខំប្រឹងតាំងអារម្មណ៍នឹកក្នុងចិត្តគិតថា មានតែព្រលឹងលោកឪពុក អ្នកម្ដាយទេដែលអាចជួយកូនបាន និងធ្វើឲ្យខ្ញុំស្ងប់អារម្មណ៍។ ខ្ញុំសម្លឹងទៅរកទួលស្វាំងហើយចាប់ផ្ដើមអង្គុយបត់ជើងផ្ទាល់ដីលើកដៃសំពះបែរទៅរកទួលស្វាំងហើយពោលខ្សឹបៗក្នុងចិត្តថា "សូមព្រលឹងលោកឪពុកអ្នកម្ដាយជួយកូនរកក្របីឲ្យឃើញ បើក្របីនៅក្នុងព្រៃ សូមឲ្យចេញមកក្រៅឆាប់ៗនេះ កូនអស់សង្ឃឹមហើយ។ មានតែឪពុកអ្នកម្ដាយទេដែលអាចជួយកូនបាន"។

ពេលគ្រាប់ភ្លៀងចាប់ផ្ដើមបន្ថយ ខ្ញុំចេញពីក្រោមដើមត្នោត ឈរសម្លឹងមើលទៅក្នុងព្រៃប៉ុន្តែមើលមិនឃើញអ្វីសោះ គឺស្ងាត់ជ្រងំសូន្យសុង។

ខ្ញុំឈរមើលវេរាមួយស្របក់ធំមើលទៅក្របីខ្ញុំពិតជាបាត់មែនទែនហើយ។ ខ្ញុំក៏ដើរចូលទៅក្នុងទួលសំដៅទៅផ្ទះព្រោះអស់សង្ឃឹមរលីង។ ក្នុងចិត្តដើរបណ្ដើរគិតបណ្ដើរក្នុងអារម្មណ៍ភ័យខ្លាច តែក្នុងចិត្តនៅតែនិយាយក្នុងចិត្តថា សូមពុកម៉ែជួយ នាំកូនឲ្យដើរដល់ផ្ទះកុំឲ្យជួបសត្វពស់ ខ្លែចចកឬសត្វសាហាវទាំងឡាយ។



រូបភាពបច្ចុប្បន្នឆ្នាំ២០២០៖ លើទួលយោគ។
( ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

---

# ឆាកប្រយុទ្ធក្នុងវិញ្ញាណ

## ពស់ថ្លាន់បន្ទាំងផ្លូវ

ដើរផងអមដំណើរដោយទឹកភ្នែកហូរសស្រាក់ៗមកក្បែរដំបូកមួយដូចជាឮសំឡេងស្រែកហៅ តែមិនច្បាស់ថាជាអ្វី? ខ្ញុំព្រឺក្បាលខ្វាក ពិតជាខ្មោចលងហើយ។ ខ្ញុំឈរវេរាមិនហ៊ានទៅមុខ មិនហ៊ានថយក្រោយ សម្លឹងមើលជុំវិញខ្លួនតែមិនឃើញមានអ្វីសោះ។

សំឡេងធ្លាក់ឮសូរក្រាកៗ ខ្ញុំភ័យលស់ព្រលឹងរត់ថយទៅចុងទួលយោគវិញ ព្រោះមានវាលងាយស្រួលមើល។ សំឡេងនោះធ្លាក់មកដល់ដីឮសូរជ្រាវលើស្លឹកត្នោត។ ខ្ញុំមិនហ៊ានមើលទៅកន្លែងធ្លាក់នោះទេ។ ផ្ដេកបន្ទោរផ្តេក ខ្ញុំលួចដៀងកន្ទុយភ្នែកមើលឃើញពស់ថ្លាន់មួយគួប៉ុនកំភួនជើងមនុស្សចាស់ វារគើមៗចេញពីកន្លែងនោះ ខ្ញុំរឹតតែភ័យរត់ចេញពីកន្លែងនោះយ៉ាងលឿន។

ឆាកប្រយុទ្ធក្នុងវិញ្ញាណ ភ័យខ្លាចព្រឺព្រួចដូចកំពុងជួបនូវឋានបាតាល លែងខ្វល់ខ្វាយពីការបាត់ក្របី គឺអារម្មណ៍ខ្លាចតែខ្មោចទៅវិញ ពិតជាចៃដន្យក្នុងចៃដន្យមែន។ ហេតុអ្វីរឿងរ៉ាវទាំងឡាយកើតឡើងផ្ទួនៗគ្នាយ៉ាងនេះ។ គិតមួយសន្ទុះខ្ញុំក៏ដើរផងរត់ផង លួចងាកមើលក្រោយម្ដងៗសំដៅទៅផ្ទះ។

ដើរមកដល់ក្បែរដំបូកដដែលឮដូចជាសំឡេងក្មេងគេវាយឮសូរណិងណុងៗចេញហៅពីព្រៃទៀតហើយ។ ឱ! ខ្មោច ព្រាយបិសាចកុំលងខ្ញុំអី ខ្ញុំទុចង៉ក់ ចាំស្ដាប់។ សំឡេងនោះកាន់តែច្បាស់ទៅៗ ខ្ញុំខំផ្ទៀងត្រចៀកស្ដាប់ហើយដើរគេចពីសំឡេងនោះដោយព្រឺក្បាល ដើរថយក្រោយបានបួនដប់ជំហាននៅតែមិនឃើញអ្វី ព្រោះមេឃងងឹត សំឡេងនោះកាន់តែមកជិតខ្ញុំ ហើយស្រាប់តែបាត់សំឡេងភ្លាមមួយរំពេច។ ខ្ញុំខំងាកមើលជុំវិញខ្លួនដោយព្រឺព្រួចមិនយូរប៉ុន្មានផ្ដេកបន្ទោរបញ្ចេញពន្លឺ ស្រាប់តែខ្ញុំឃើញ

អ្វីខ្មៅស្កុងៗតាមពន្លឺផ្លេកបន្ទោរ លរឹតតែធ្វើឲ្យខ្ញុំភ័យលស់ព្រលឹង។

ពន្លឺផ្លេកបន្ទោរផ្ទោច! ខ្ញុំភ្ញាក់ខ្លួនព្រើត។ ក្របីមួយនឹមនៅពីក្រោយខ្នងដោយវាឈរសម្ងឹងមករកខ្ញុំ។ តាមពិតគឺសំឡេងត្រដោកក្របីសោះ តែដោយសារមានខ្យល់បក់មកប៉ះស្លឹកត្នោតធ្វើឲ្យខ្ញុំស្តាប់មិនច្បាស់។ ចិត្តខ្ញុំពិតជារំភើបឥតឧបមា ហើយក៏ស្ទុះទៅចងខ្សែអង្គត់នឹងកន្ទុះ រួចឡើងជិះមីធំដឹកមីតូចតាមក្រោយ។ ក្របីស៊ីឆ្អែតពោះមូលតិល។ ខ្ញុំគិតថាប្រហែលជាវាប៉ះនឹងល្បាស់ខ្ចីបានធ្វើឲ្យវាស៊ីដក់ភ្លេចគិតថ្ងៃលិច។

មេឃងងឹតមើលផ្លូវមិនឃើញ។ ដោយភ័យខ្លាចខ្ញុំដេកក្រាបលើខ្នងក្របី ពឹងលើវាសនាវាចុះ។ ដោយធ្លាប់ឮចាស់ៗតំណាលថា សត្វគោក្របីវាអាចមើលឃើញខ្មោចព្រាយនៅពេលយប់។

ក្របីដើរផុតទួលយោគហើយដើរតាមផ្លូវរទេះឆ្លងកាត់ត្រពាំងវែង។ ទឹកជ្រៅវាក៏ហែលឆ្លងត្រពាំង ខ្ញុំហែលតោងកន្ទុយពីក្រោយមកដល់គោក។ ខ្ញុំជិះវាបន្តមកទៀតលើផ្លូវរទេះសំដៅមកខាងលិចត្រពាំងស្វាំងក្នុងចិត្តភ័យខ្លាច។ នៅតែឃើញភ្លើងពណ៌ស្វាយហោះចេញពីទួលស្វាំងមិនដាច់។

មកជិតឆ្លងទួលស្វាំង ក្នុងចិត្តពិតជាភ័យខ្លាច តែពេលនេះភ័យខ្លាចខ្មោច។ ខ្ញុំដេកក្រាបលើខ្នងក្របីបិទភ្នែកមិនហ៊ានមើលអ្វីទេ គឺស្កុងអារម្មណ៍ក្នុងភពខ្លាចខ្មោចលង។

កំពុងតែស្កុងអារម្មណ៍ ស្រាប់តែក្របីទុចង៉ក់ទាំងពីរក្បាល ផ្អើលប្រាលថយក្រោយ ខ្ញុំភ្ញាក់ព្រើត "តើមានអ្វីកើតឡើង!" គិតក្នុងចិត្តថាប្រាកដជាក្របីឃើញខ្មោចហើយ។ ខ្ញុំព្រឺសម្បុរ គឺផ្អាក់សក់បះព្រូងស្ទើរបាត់វិញ្ញាណ។ ខ្ញុំសូមអង្វរឱ្យព្រលឹងខ្មោចព្រាយបិសាចទាំងឡាយអើយ កុំចងចិត្តប្ុសព្រានឹងខ្ញុំអី ខ្ញុំជាមនុស្សសុំតែសុខទេ។

ខ្ញុំលួចបើកភ្នែកបន្តិចម្តងៗ មើលទៅមុខតែមិនឃើញអ្វីសោះ ក្របីនៅតែមិនដើរទៅមុខ។ ទោះជាខ្ញុំញាក់ខ្សែកន្ទុះ និងគោះជើងលើខ្លួនវាយ៉ាងណាក៏ដោយ វានៅតែងើយមកលើយកស្នែងមកឆ្កឹះជើងខ្ញុំ។ ខ្ញុំហាក់ដូចជាមានអ្វីមកពញ្ញាក់ចិត្តឲ្យដោះត្រដោកចេញពីកវា។

ខ្ញុំចាប់ស្រាយត្រដោកចេញហើយយកមកស្ពាយនឹងស្មា ស្រាយត្រដោករួចហើយវានៅតែមិនទៅមុខ តែបែរជាវាងាកស្តាំតាមភ្លឺស្រែឆ្ពោះទៅរកត្រពាំងភ្លុកវិញ។ ខ្ញុំបណ្តោយតាមវាមកដល់ទំនប់ត្រពាំងភ្លុក វាក៏សំដៅចូលទៅក្នុងភូមិ។

ភាពភ័យខ្លាចលួចងាកមើលក្រោយម្តងៗ ឃើញតែភ្លើងពណ៌ស្វាយហោះចេញពីទួលចេតិយតាសុខសំដៅទៅទួលស្វាំងហោះទៅវិញទៅមកគួរព្រឺព្រួច។ ការភ័យខ្លាចនៅតែលងអន្ទងក្នុងប្រាណជានិច្ច។

មកដល់ចម្ការតាម៉ុក មុនចូលក្នុងភូមិស្ងាត់ជ្រងំងងឹតសូន្យ។ ផ្ទះខ្លះនៅមានពន្លឺចង្កៀងខ្លាញ់ត្រីភ្លឺផ្លឹងៗក្នុងផ្ទះ និងសត្វអំពិលអំពែកហើរឆ្អែលចុះឆ្អែលឡើងគួរឲ្យស្រណោះខ្លួន។ ក្របីបាននាំខ្ញុំមកដល់ក្រោលផ្ទះធំតែម ខ្ញុំរុញរបាក្រោលវាយស្មៀត។

ធំតែមគាត់ដឹងថាខ្ញុំមកពីចាំក្របី គាត់អុជចន្លុះជ័រដើមឈើទាលចុះមកក្រោមផ្ទះបំភ្លឺ រួចស្ទុះមកសួរខ្ញុំដូចជាភ័យស្លន់ស្លោ។ នែក្មួយចាំក្របីថ្ងៃនេះ



ទិដ្ឋភាពៈ ខ្ញុំឃើញពស់ថ្លាន់មួយគូធ្លាក់ពីលើដើមជ្រៃ ពេលខ្ញុំឆ្លេឆ្លាដោយសារបាត់ក្របី។
( ឡុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

យូរម្ល៉េះ។ ខ្ញុំមិនទាន់តបទៅគាត់វិញផង គាត់សួរខ្ញុំទៀតថា ក្មួយមានជួបពួកកងចក្រទេ។ អម្បាញ់មិញពួកគេដើរតាមផ្លូវរទេះខាងក្រោយផ្ទះប្រហែលដប់ម្ភៃនាក់ មានស្ពាយកាំភ្លើង ឆ្នាំងបាននិងអង្ករផង ខ្ញុំឆ្លើយថាមិនបានជួបទេ។ គាត់សួរមកទៀត ចុះក្មួយមកតាមផ្លូវណា ខ្ញុំតបថាមកតាមទំនប់ត្រពាំងភ្លុក។ គាត់តបមកវិញថាអូរអ៊ីចឹងសំណាងល្អហើយក្មួយ ជ្រួសជាមួយពួកគេហើយ ខ្ញុំក៏លាគាត់ដើរមកផ្ទះ លុយទឹកដែលមានដក់នៅតាមផ្លូវ។

ផ្ទះណាក៏ដូចផ្ទះណាដែរ គឺពន្លត់ភ្លើងស្ទើរតែទាំងអស់។ មេឃងងឹតខ្លាំងពេកមិនអាចមើលឃើញផ្លូវច្បាស់ ដើរជាន់អាចម៍ក្របីប្រលាក់ពេញជើងធ្វើឲ្យកើតរមាស់ទឹកស៊ីតាមម្រាមជើងដេកអេះរាល់យប់។

**ឡុង វង្សសមិទ្ធ**

**(តទៅលេខក្រោយ)**

រូបក្របមុខ៖

ប្រជាជនកម្ពុជា ឈប់សម្រាកនៅតាមផ្លូវឆ្ពោះមកស្រុកកំណើត បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ
នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ប្រជាជនបានលើកខិតប័ណ្ណបង្ហាញអំពីការដឹកនាំថ្មីនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា
ដែលបានរំដោះប្រទេស និងប្រជាជនកម្ពុជាចេញពីការកាប់សម្លាប់នៃរបបខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

ប្រជាជនកម្ពុជា ប្រណិប័តន៍ព្រះសង្ឃ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 282, June 2023 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.